អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Mar-2012, 13:45
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ

**ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី៣៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូហ្គ័រ ហ្វីលីព *(Mr.Roger Phillip)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

កញ្ញា ហ្គូលរី កាហ៊ាមេន
*(Ms. Golriz GHAHRAMAN)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី គាំង ហ្គេកអ៊ាវ ហៅ ឌុច**

សួរបន្តដោយលោក សេង ប៊ុនឃាង ផ្តើមពី..........................................................ទំព័រ ០២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣៦]

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ យើងនឹងបន្តស្តាប់សក្ខីកម្មសាក្សីឈ្មោះ កាំង ហ្គេកអ៊ាវ ហៅឌុច។ ដោយដំណើរការនៃការសួរដេញដោល ដោយតំណាងសហព្រះរាជអាជ្ញា។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចូលមកកាន់បន្ទប់សវនាការ!

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៨:០៦]

អរុណសួស្តី លោក កាំង ហ្គេកអ៊ាវ! នៅព្រឹកនេះ យើងនឹងបន្តនីតិវិធីដោយបន្តការតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញា។ លោកពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុទាំងឡាយនៅក្នុងសំណុំរឿង០០២/០១ ដែលការចាប់ផ្តើម គឺពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ ហើយម្សិលមិញ ឃើញថាបានសួរនាំបានច្រើនសំណួរហើយ។ ឥឡូវនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តនូវការងាររបស់ខ្លួន។

សូមអញ្ជើញ!

សូមអញ្ជើញលោក កាំង ហ្គេកអ៊ាវ!

[០៩:០៨:៥២]

**លោក កាំង ហ្គេកអ៊ាវ៖**

លោកប្រធានជាទីគោរព! ខ្ញុំមានបញ្ហាមួយ សូមរាយការណ៍ជូនលោកប្រធាន។ ម្សិលមិញ តាមការសង្កេតរបស់ខ្ញុំ ផ្ទាល់លើខ្លួនខ្ញុំ។ ខ្ញុំសង្កេតឃើញថា បើសិនជាខ្ញុំអង្គុយឱន ដង្ហើមខ្ញុំផុតៗ មិនអាចនិយាយអាចឲ្យបានយឺត សមរម្យតាមសំណូមពរទេ។ បើសិនជាខ្ញុំអង្គុយផ្អែកទៅ ដង្ហើមវា ដើមទ្រូងវា

បើក ដង្ហើមហាក់ដូចជាម្ចាស់ការបាន និយាយយឺត។ ខ្ញុំជឿថា ប្រសិនបើខ្ញុំអង្គុយបែបនេះ មិនសូវជាសមរម្យប៉ុន្មាន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន អង្គុយបែបនេះ ដើម្បីឲ្យបាននិយាយបានស្រួល។ ទន្ទឹមនេះ ខ្ញុំតាមរយៈលោកប្រធាន ក៏សូមអនុញ្ញាតអធ្យាស្រ័យអំពីអង្គប្រជុំទាំងមូល អំពីចិត្តប្រជាជនកម្ពុជាទាំងមូលដែរ ឲ្យខ្ញុំសូមអង្គុយបែបនេះលមើលសិន។ សូមអរគុណ។

[០៩:០៩:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដែលផ្តល់ព័ត៌មាននេះ។ មិនអីទេណ៎ាលោក កាំង ហ្គេកអ៊ាវ សម្រួលៗអង្គុយរបៀបណាដើម្បីឲ្យលោកស្ថិតក្នុងស្ថានភាពអាចនិយាយបានត្រឹមត្រូវ ហើយនិងធូរស្រាលនៅក្នុងអារម្មណ៍របស់លោក ទាំងផ្នែកខាងរាងកាយ កម្លាំងកាយ ហើយនិងបញ្ញា ដើម្បីឲ្យលោកអាចនិយាយអាចផ្តល់សក្ខីកម្មបានកាន់តែល្អប្រសើរ កាន់តែច្បាស់លាស់នៅក្នុងកិច្ចដំណើរការសវនាការនេះ។ ពីព្រោះយើងដំណើរការវែងណាស់ មកពីលោកគិតថា ជាវប្បធម៌ ឬក៏ជាប្រពៃណីរបស់កម្ពុជាទេ ដែលអង្គុយប្រឹងៗខ្លួន ដើម្បីឲ្យរមទមនោះ។ ដោយសារអង្គុយយូរ យើងគ្រប់គ្នាអ៊ីចឹងគឺដូចគ្នា ដោយសារឥរិយាបថមានការប្រែប្រួល។ អ៊ីចឹងគឺអង្គជំនុំជម្រះអនុញ្ញាតនៅក្នុងលក្ខខណ្ឌនៃការសម្រួលឥរិយាបថឲ្យបានល្អប្រសើរ សម្រាប់ឲ្យលោកមានបញ្ញាស្មារតី ដើម្បីអាចស្តាប់នូវសំណួរ ហើយនិងឆ្លើយតបបានល្អ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:១១:០៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សួស្តីលោកកាំង ហ្គេកអ៊ាវ ថ្ងៃនេះខ្ញុំនឹងបន្តសំណួរពីម្សិលមិញទៀត។ ដូចដែលលោកបានជម្រាបអង្គសវនាការពីម្សិលមិញ លោកថា អ្នកទោសមួយចំនួនដែលបញ្ជូនមក ម-១៣ ហ្នឹង ក៏មានទាហានដែលចាប់មកពីសមរភូមិដែរ។ ថាតើទាហាននោះជាទាហានខាងណាដែរ លោកដឹងទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ទាហាននុំងគឺទាហានរបស់ លន់ នល់ ចេញពីវត្តអង្គព្រលឹង។ ប៉ុន្តែនិយាយវត្តអង្គព្រលឹងដែលលន់ នល់ គាត់យកវត្តអង្គព្រលឹងធ្វើបន្ទាយ។

**ស៖** ថាតើទាហានទាំងនោះត្រូវបាន ម-១៣ សម្រេចយ៉ាងម៉េចចំពោះពួកគាត់?

**ឆ៖** គេសម្រេចឲ្យកម្ទេច។ ខាងលើ ខាងភូមិភាគពិសេស វន វ៉េត សម្រេចឲ្យកម្ទេច។

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់បន្ថែមអំពីថាតើមានមនុស្សប្រភេទណាខ្លះទៀតដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាសត្រូវ ហើយត្រូវបានបញ្ជូនមក ម-១៣ នេះ?

[០៩:១២:៣១]

**ឆ៖** ដំបូងខ្ញុំសូមនិយាយពីរឿង ប៊ីហ្សូ ហើយនិងខ្មែរពីរនាក់ទៀត។ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ហ្នឹងមុខងារគាត់ជាភ្នាក់ងារអភិរក្សអង្គរ ទៅរកគម្ពីរនៅវត្តអូរ ដល់ទៅកងឈ្លបចាប់បានបញ្ជូនមកក្រោយ។ វន វ៉េត ឲ្យខ្ញុំសួរចម្លើយ។ គ្មានទារុណកម្មទេ ខ្ញុំសួរចម្លើយប៊ីហ្សូ ខ្មែរពីរនាក់ទៀតខ្ញុំទុក។ ដល់ក្រោយមកសារពីប៉ុល ពត ឲ្យដោះលែង ប៊ីហ្សូ ហើយឲ្យទុកខ្មែរពីរនាក់នុំង។ មួយឆ្នាំក្រោយមក សេចក្តីសម្រេចពីលើ បញ្ជាមក វន វ៉េត ឲ្យខ្ញុំកម្ទេចខ្មែរពីរនាក់ហ្នឹងទៅទៀត។ ពីរនាក់ហ្នឹងឈ្មោះ ឡាយ ហើយនិងឈ្មោះសុន។ ដូច្នេះប្រភេទបែបហ្នឹងមួយប្រភេទទៅ។ ម្សិលមិញខ្ញុំបានជម្រាបលោកសហព្រះរាជអាជ្ញាហើយមានមនុស្សប្រជាជនយើងហ្នឹង ដែលចូលមកតំបន់រំដោះ ហើយដែលគេស្មានថាគិញ ហ្នឹងជាទីមួយ។ ទីពីរទៀត នៅពេលដែលគ្រាប់បែក បេ-៥២ វាទម្លាក់នៅមន្ទីរភូមិភាគនិរតី តាម៉ុក ចាប់មនុស្សយកមកឲ្យ ម-១៣ សួរចម្លើយ។ ហ្នឹងមួយប្រភេទទៀត។

[០៩:១៣:៥៧]

អំមិញនេះខ្ញុំនិយាយដល់ប្រភេទទីបី គឺទាហានវត្តអង្គព្រលឹង។ ប្រភេទទីបួនគឺ ហ្វ្រង់ស្វ័រ ប៊ីហ្សូ។ ឥឡូវមួយប្រភេទទៀត គឺពួកកម្មាភិបាលខ្មែរដែលទៅរៀននៅភាគខាងជើងវៀតណាម ដែលគេហៅថាពួកហាណូយនុំងក៏បញ្ជូនមកដែរ។ ពួកនោះ ច្រើនតែបញ្ជូនមក ចាប់តាំងពីឆ្នាំ១៩៧៣។ សមាសភាពទាំងអស់ហ្នឹង វា-- អំ! នៅមួយប្រភេទទៀត។ មួយប្រភេទទៀតក្មេងនៅក្នុងជួរតែម្តង។ ពួកសិល្បៈរបស់តំបន់៣២ គ្នាវាប្រាំនាក់ ប្រុសពីរ ស្រីបី។ វានាំគ្នាដើរទៅបំផុសបំផុលថា វាមានតួនាទី ដើរលុបបំបាត់ព្រះពុទ្ធសាសនា ដើរផ្សឹកលោកសង្ឃ។ ដល់ទៅខាងភូមិភាគ-- បង ប៉ាល់ ខាងភូមិភាគបស្ចិម-- និរតី-- អង្គាល់នោះនៅជានិរតី។

[០៩:១៥:០៨]

**ស៖** បាទៗ សូមទោស អ៊ីចឹងជាសង្ខេបទៅថា ប្រភេទមនុស្សដែលបក្សចាត់ទុកថាជាសត្រូវ ហើយចាប់មកចូលក្នុង ម-១៣ ហ្នឹង គឺមានចំនួនប្រាំប្រភេទ អ៊ីចឹងមែនទេ? ដូចដែលលោកបានបញ្ជាក់អម្បាញ់មិញ។

**ឆ៖** មើល៍ៗ ទីមួយន៎ែ! ប្រជាជនយើងដែលចូលតំបន់រំដោះ។ ទីពីរ ប្រជាជនក្នុងមូលដ្ឋានបង្អែក ចាប់មកក្រោយគ្រាប់បែក បេ-៥២។ ទីបី ទាហានវត្តអង្គព្រលឹង។ ទីបួន ពួកហ្វ្រង់ស្វ័រ ប៊ីហ្ស៊ូ។ ទីប្រាំ ពួកហាណូយ។ ទីប្រាំមួយ ពួកក្មេងស្រីដើរទៅឃោសនាបំផុសបំផុលផ្សឹកលោកសង្ឃ បំបិទពុទ្ធសាសនាហ្នឹង ប្រាំមួយប្រភេទ។

[០៩:១៥:៥០]

**ស៖** បាទ សូមអរគុណ។ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់អំពីទីតាំង ម-១៣ ដែលលោកបានជម្រាបជូនអង្គសវនាការពីម្សិលមិញហ្នឹង។ ចង់ឲ្យលោកជួយបញ្ជាក់ថា តើទីតាំង ម-១៣ ហ្នឹងស្ថិតនៅក្នុងឃុំណា ស្រុកណា? ហើយលោកអាចចាំដល់ភូមិទៀតដែរទេ?

**ឆ៖** ន៎ែ! ដំបូង ដែលខ្ញុំទៅបោះទីតាំងដំបូងនៅក្រោយភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ទីតាំងទីពីររបស់ខ្ញុំដែលនាំមនុស្ស ដែលខ្ញុំជឿថាមិនមែនជាគិញយកទៅធ្វើស្រែ សាមសិបប្លាយនាក់ នៅវាលមួយ គេហៅថា "វាលទួលស្វាយមាស" ឬក៏ជាប់នឹងវាលមួយទៀតឈ្មោះ "តាលាវ" នៅជើងភ្នំពីសៗ ក្នុងឃុំអមលាំងដដែល។ ហើយដល់ក្រោយពីការបះបោរវ៉ៃគុក ខ្ញុំក៏មកតាំងទីតាំងនៅភូមិមួយឈ្មោះ-- តំបន់មួយឈ្មោះ ត្រពាំងច្រាប។ ត្រពាំងច្រាបហ្នឹង នៅក្នុងភូមិយីហោច ១"ភូមិចាស់" ក្នុងឃុំអមលាំងដដែល ជិតភូមិត្រពាំងត្រោប។ នេះទីតាំងខ្ញុំផ្លាស់បីកន្លែងប៉ុណ្ណឹង ម-១៣។ ឯចំណែក ម-១៣(ខ) នៅឯមុខនេះទេ។ នៅភូមិស្តុកស្រោត ឃុំស្តុកគោល ស្រុកដូចគេហៅស្រុកអង្គស្នួល កន្លែងនុ៎ង។

**ស៖** តើការផ្លាស់ទីតាំងម-១៣ របស់លោកហ្នឹង តើមានដែលពេលណាមួយស្ថិតនៅក្នុងឈ្មោះដែលគេហៅថាភូមិ ឬឃុំថា អមលាំងដែរទេ?

**ឆ៖** ម-១៣(ក) នៅអមលាំងទាំងអស់ៗ ប្តូរៗតែភូមិទេ។ រួចតាមពិតមិនមែននៅក្នុងភូមិប្រជាជនទៀត នៅពីក្រោយឆ្ងាយដាច់ពីភូមិប្រជាជនបន្តិច ព្រោះជាកន្លែងសម្ងាត់។

[០៩:១៨:៤០]

**ស៖** បាទ អរគុណ។ តើលោកធ្លាប់ស្គាល់កន្លែងធ្វើការមួយដែលមានឈ្មោះថា ប-៥ ដែរទេ នៅកាលណោះ?

**ឆ៖** គ្មានដែលឮឈ្មោះទេ ប-៥។

**ស៖** សូមឲ្យលោកជួយបញ្ជាក់បន្ថែមដែរ អំពីទីតាំងរបស់អ្នកគ្រប់គ្រងរបស់លោកដូចជា លោក ដូចជា វន វ៉េត ហើយនិង សុន សេន។ ថាតើទីកន្លែងដែលគាត់ធ្វើការហ្នឹងនៅៗទីណា? ស្ថិតនៅភូមិ ឃុំណា ស្រុកណាដែរ? លោកអាចបញ្ជាក់ឲ្យកាន់តែច្បាស់បានទេ ចំណុចនេះ?

**ឆ៖** ដំបូង ខ្ញុំសូមបញ្ជាក់ថា វន វ៉េត គាត់គ្រប់គ្រងភូមិភាគពិសេស ទាំងខាងជើងផ្លូវលេខ៤ ហើយនិងទាំងខាងត្បូងផ្លូវលេខ៤។ ទីតាំងគាត់មែនទែន ដំបូងគឺនៅភូមិក្រាំងបេង ឃុំពាមខាងត្បូង បច្ចុប្បន្ននេះគេហៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ ពីអង្កាល់នោះគេហៅ កំពង់ត្រឡាចលើ។ ដល់ឆ្នាំ៧៣ ចុងឆ្នាំ៧៣ ដើមឆ្នាំ៧៤ វន វ៉េត គាត់ទៅនៅឯខាងត្បូងបាត់ទៅហើយ ទៅនៅខាងស្អាង កោះធំ។ ខាងជើងនេះ សុន សេន គាត់មកជំនួស ក្នុងឋានៈគាត់ជាអនុលេខាភូមិភាគ ជាប្រធាន សេនាធិការ គាត់មកនៅខាងជើង។ សុន សេន គាត់មិនបោះទីតាំងនឹងនរដូច វន វ៉េត ទេ។ គាត់មានកូន រោងពីរ។ រោងមួយសម្រាប់នីរសារ រោងមួយសម្រាប់គាត់នៅ។ ហើយនៅត្រង់ម្តុំព្រៃគុម្ពោតៗ ក្បែរ ស្ថានីយរថភ្លើងដំណាក់ស្នាច់ ហើយគាត់មានឡានហ្ស៊ីបមួយប្រចាំនៅហ្នឹង អាចគាត់ចល័ត។ ហ្នឹងគឺទី តាំងគាត់អ៊ីចឹង របៀបហ្នឹង។

[០៩:២១:២១]

**ស៖** ទីតាំងដែលលោកបានបញ្ជាក់អម្បាញ់មិញថា នៅត្រពាំងត្រឡាចលើ ឬក៏សាមគ្គីមានជ័យ នោះ តើស្ថិតនៅក្នុងភូមិ ឬឃុំណាដែរ? លោកចាំច្បាស់ទេ? ហើយតើចម្ងាយពីទីតាំងនោះមកកន្លែង លោកធ្វើការដែលជា ម-១៣នេះ វាមានចម្ងាយពីគ្នាប៉ុន្មានណាដែរ លោកដឹងទេ?

**ឆ៖** កំពង់ត្រឡាចលើនេះជាស្រុក សាមគ្គីមានជ័យនេះជាស្រុក កំពង់ឆ្នាំងជាខេត្ត ពាមជាឃុំ ក្រាំងបេង ជាភូមិ។ ពីត្រពាំងគ្រោកទៅក្រាំងបេង ខ្ញុំពិបាកស្មានណាស់ ខ្ញុំ-- មិនតិចជាង២០គីឡូទេ។ ខ្ញុំ ជិះកង់ទៅធ្វើការ។

**ស៖** បាទ អរគុណ។ អម្បាញ់មិញលោកបានបញ្ជាក់ហើយថា លោក សុន សេន ៗគឺជា អនុសេនាធិការភូមិភាគ ហើយម្សិលមិញលោកក៏បានបញ្ជាក់ដែលថា សុន សេន គឺជាសមាជិកមជ្ឈិម បក្ស។ តើក្រៅពីតួនាទីទាំងពីរនេះ គាត់មានតួនាទីអ្វីផ្សេងទៀតដែរទេនៅពេលនុ៎ង?

[០៩:២២:៤១]

**ឆ៖** សុន សេន នេះ គាត់ជាសមាជិកមជ្ឈិមបក្ស វន វ៉េត ក៏ជាសមាជិកមជ្ឈិមបក្សដែរ។ នៅឆ្នាំ១៩៧៣ សុន សេន គាត់ចុះពីភូមិភាគឧត្តរទៅ ទៅនៅឯខាងត្បូងនុ៎ង។ គាត់ទទួលភារៈជាអនុលេខាភូមិភាគ មិនមែនអនុសេនាធិការទេ សេនាធិការជានាទីរបស់គាត់ វន វ៉េត ជ្រៀតជ្រែកអត់បានទេ។ គាត់មានតួនាទីជានាយអគ្គសេនាធិការ អ៎ យើងហៅតាមភាសានេះចុះ គេហៅ ប្រធានសេនាធិការ។ ចូលទៅនៅនុ៎ង គាត់ជាអនុលេខាភូមិភាគពិសេស។ ហ្នឹងតួនាទីហ្នឹងវានៅប៉ុននុ៎ង ទាំងពីរនាក់នុ៎ង។ ឯចំណែកតួនាទីរបស់ វន វ៉េត មានតួនាទីឧបកិច្ចមួយទៀត ក្នុងរាជរដ្ឋាភិបាលរួមរួបជាតិហ្នឹង វន វ៉េត មានតួនាទីឧបកិច្ចមួយទៀត គឺជាអនុរដ្ឋលេខាធិការក្រសួងសន្តិសុខ។ ប៉ុន្តែអត់ទេ គាត់នៅតែធ្វើលេខាភូមិភាគនុ៎ងឯង។ ក្រោយ៧៥ ទើបប្រែប្រួល តួនាទីបុគ្គលពីររូបហ្នឹង។

[០៩:២៤:១០]

**ស៖** បាទ ហើយកាលពីម្សិលមិញ លោកក៏បានជម្រាបជូនអង្គសវនាការរួចហើយដែរថា លោកក៏បានធ្លាប់ទៅកាន់មន្ទីររបស់អ្នកទាំងពីរនាក់នោះដែរ ហើយនៅមុនឆ្នាំ១៩៧៥ ហ្នឹង។ តើលោកបានទៅកាន់មន្ទីរទាំងនោះញឹកញាប់ដែរទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា ខ្ញុំទៅញឹក។ ក្នុងមួយខែខ្ញុំទៅធ្វើជីវភាពបក្សម្តង ទៀងទាត់។ ដោយឡែក ពេលណាមានការងារខាងចម្លើយសន្តិបាល ដែលគួរតែខ្ញុំប្រញាប់ទៅខ្ញុំត្រូវតែទៅ ជិះកង់ទៅ។ ដូច្នេះទៀងទាត់មួយខែម្តង ប៉ុន្តែមិនមែនជាមួយមេទេ ជាមួយអ្នកផ្សេង លេខាសាខា ជាមួយលេខាសាខា អាហ្នឹងមួយខែម្តង តែចំណែកជាមួយមេ គឺពេលណាអាស្រ័យការងារសន្តិបាលវាតម្រូវទៅ ខ្ញុំទៅ។

**ស៖** បាទ អរគុណ។ តើមានមូលហេតុអីផ្សេងក្រៅពីមូលហេតុទាំងនេះដែរឬទេ?

**ឆ៖** មានមូលហេតុដោយឡែកៗមួយ គឺនៅពេលគេវ៉ៃគុករត់រួច ខ្ញុំស្ទុះទៅ វន វ៉េត ទាំងយប់។

**ស៖** បាទ ឥឡូវខ្ញុំសួរទាក់ទងទៅនឹងទំនាក់ទំនងរបស់លោកជាមួយនឹង វន វ៉េត នៅក្នុងពេលនោះ។ ថាតើលោកជួប វន វ៉េត ដំបូងគេបង្អស់នៅពេលណាដែរ លោកចាំទេ?

[០៩:២៦:១៦]

**ឆ៖** ខ្ញុំជួប វន វ៉េត ដំបូងនៅភ្នំពេញ ឆ្នាំ១៩៦៧ ក្នុងខែ១០។ ជួបនៅមន្ទីរមួយ មន្ទីរសម្ងាត់មួយនៅខាងអង្គស្ងួល។ គឺគាត់ហ្នឹងហើយដែលអនុម័តឲ្យខ្ញុំចូលបក្ស ហើយនិងបញ្ជេញខ្ញុំទៅជនបទ។

ពេលនោះគាត់មានឋានៈជាលេខាក្រុងភ្នំពេញ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ថាលោកបានទៅជួបៗ វន វេត នៅមន្ទីរសម្ងាត់មួយនៅអង្គស្នួល តើមន្ទីរសម្ងាត់នោះមានឈ្មោះអ្វីដែរ? ហើយថាអ្នកណាខ្លះដែលមានតួនាទីនៅទីនោះ?

**ឆ៖** ថ្ងៃដែលគេយកខ្ញុំទៅជួប វន វេត នោះ ថ្ងៃនុ៎ង វន វេត គាត់នៅនុ៎ង។ ហើយមានអ្នកនៅចាំមន្ទីរនោះម្នាក់ មិនដឹងជាឈ្មោះអីទេ។ ខ្ញុំទៅមួយយប់ ដេកនុ៎ងមួយយប់។ ហើយពេលនុ៎ង ណាត មិនទាន់បញ្ចេញទៅទេ។ ណាត ស-២១ នៅនុ៎ងដែរ។

**ស៖** អ៊ីចេះ ចង់ដឹងថាមន្ទីរសម្ងាត់ដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ មន្ទីរនោះមានឈ្មោះអ្វីផ្សេងពីហ្នឹង ឬក៏មានតួនាទីអីដែរមន្ទីរហ្នឹង?

**ឆ៖** មន្ទីរនោះមិនដឹងជាឈ្មោះស្អីទេ ខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែមានម្នាក់នៅរកស៊ីរត់រ៉ឺម៉កម៉ូតូ ដើម្បីឲ្យវាមានរូបភាពសមរម្យស្របច្បាប់ ជារូបភាពចំហ។ នៅមន្ទីរនុ៎ង-- សរុបមកវិញនៅមន្ទីរហ្នឹងមិនដឹងឈ្មោះស្អីទេនៅខាងដូចហួសផ្សារអង្គស្នួលបន្តិច ប៉ុន្តែនៅតែក្នុងស្រែ។ មានអ្នកចាំមន្ទីរហ្នឹងម្នាក់មានម្នាក់ទៀតរកស៊ីរត់រ៉ឺម៉កម៉ូតូ ដើម្បីជារូបភាពចំហ ដើម្បីបិទបាំងសកម្មភាព។ ផ្ទះនុ៎ងសម្រាប់ឲ្យ វន វេត ធ្វើការ។

[០៩:២៨:៥៦]

**ស៖** បាទ សូមអរគុណ។ ចុះចំណែក សុន សេន វិញ តើលោកជួបគាត់ដំបូងគេបង្អស់ហ្នឹងនៅពេលណាដែរ លោកចាំទេ?

**ឆ៖** សុន សេន ខ្ញុំជួគាត់នៅពេលដែលខ្ញុំនៅរៀននៅក្នុងវិទ្យាល័យស៊ីសុវត្ថិនៅឡើយទេ។ ខ្ញុំទៅជួបគាត់ដោយសារល្បិចរបស់មិត្តភក្តិខ្ញុំចង់ឲ្យខ្ញុំទៅជួបគាត់ ដើម្បីឲ្យខ្ញុំបានជាប់ខ្សែជាមួយនឹងគាត់ តែខ្ញុំថាខ្ញុំអត់ទាន់ទេ ខ្ញុំចង់បានបាក់ឌុបសិន។ គឺកាលនុ៎ងគាត់ឈរនៅនឹងតារាងបាល់នៃវិទ្យាស្ថានជាតិគរុកោសល្យខាងត្បូងជាមួយ ឆាយ គឹមហ៊ ហៅ ហុក នេះ។ ឯចំណែកអ្នកដែលនាំខ្ញុំមកហ្នឹងឈ្មោះ ហួ ងារ បន្ទាប់មកចូលបដិវត្តន៍ហៅ សំ។ ដើរជាមួយគ្នាទៅជួបគាត់ ហើយនិយាយ ខ្ញុំនៅក្រៅរបងគាត់នៅក្នុងរបង។ ពេលនុ៎ង ដែលខ្ញុំ ហើយនិងគាត់ជួបគ្នា។

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេ ពេលណាដែល សុន សេន ហ្នឹងក្លាយជាអ្នកគ្រប់គ្រងផ្ទាល់របស់លោក?

**ឆ៖** សុន សេន ក្លាយមកជាមេខ្ញុំ គឺនៅឆ្នាំ១៩៧៤, ៧៣-៧៤ ចុង៧៣ ដើម៧៤។

**ស៖** ចុះ វន វ៉េត វិញ?

**ឆ៖** វន វ៉េត គាត់ដាច់ពីខ្ញុំហើយ ៧៣-៧៤ គាត់ដាច់ គាត់មកខាងក្រោម មកខាងស្អាង កោះធំ លើកដែក កៀនស្វាយ តំបន់២៥។ សុន សេន គាត់អនុលេខាភូមិភាគពិសេស នៅប្រចាំការតំបន់១៥។

**ស៖** ចង់សួរថា តើនៅពេលណាដែល វន វ៉េត ក្លាយជាអ្នកគ្រប់គ្រងផ្ទាល់របស់លោកៗនៅចាំបានទេ?

**ឆ៖** បាទ វន វ៉េត ជាអ្នកគ្រងផ្ទាល់របស់ខ្ញុំ។ អង្កាល់នៅភ្នំពេញ ដែលខ្ញុំទៅជួបគាត់ហ្នឹង គាត់ជាអ្នកគ្រប់គ្រងហើយ ហ្នឹងមួយ។ ទោះបីមួយយប់ក៏ដោយ ពីលើខ្ញុំ ពីលើ ឆាយ គឹមហ៊ា នោះមាន វន វ៉េត រួចទៅហើយ។

[០៩:៣១:២៤]

ហើយទីពីរ ចាប់ផ្ដើមពីខែប្រាំពីរ ខែប្រាំមួយ ខែប្រាំ ដែលខ្ញុំត្រឡប់ពីតំបន់២៥ទៅភូមិភាគនិរតី ខ្ញុំទៅជួប វន វ៉េត។ ដូច្នេះ ខែប្រាំ ឆ្នាំ១៩៧១ វន វ៉េត គាត់ចាប់ផ្ដើមគ្រប់គ្រងខ្ញុំផ្ទាល់ហើយ រហូតដល់ចុង៧៣ ដើម៧៤ ទើបដាច់ពីខ្ញុំ។ ខ្ញុំធ្លាក់ទៅក្នុងកណ្ដាប់ដៃ សុន សេន វិញ។

**ស៖** បាទ សូមអរគុណ។ ជាបន្តទៀតនេះ ខ្ញុំនឹងសួរទាក់ទងទៅនឹងតួនាទីរបស់បក្សកុម្មុយនីស្ដកម្ពុជានៅក្នុងតំបន់រំដោះ។ ហើយជាដំបូង ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារមួយចំនួនទាក់ទងទៅនឹងអំឡុងពេលនោះ ដើម្បីឲ្យសាក្សីជួយបញ្ជាក់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ លោកប្រធាន។ឯកសារដំបូងនេះ គឺមានលេខឯកសារ E3/147។ សូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារពីតំណាងសហព្រះរាជអាជ្ញាជាតិយកទៅជូនសាក្សី។

[០៩:៣៣:១៣]

សូមអញ្ជើញមេធាវី!

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ គ្រាន់តែសម្រួលការងារដល់ភាគី គឺថាកំណត់អត្តសញ្ញាណឯកសារ តើៗលោកសហព្រះរាជអាជ្ញាអាចបង្ហាញលេខឯកសារបានដែរឬទេ? ដើម្បីសម្រួលការងារដល់ភាគីទាំងអស់គ្នាលោកប្រធាន។

**លោក សេង ប៊ុនឃាង៖**

បាទ--

**ប្រធានអង្គជំនុំ៖**

បាទ នេះនឹងបន្តហើយ ពីព្រោះកាលណាដាក់ឯកសារចំពោះ-- ដេញដោលចំពោះមុខភាគី អ្នកដែលដាក់ឯកសារត្រូវតែបង្ហាញអត្តសញ្ញាណឯកសារនូវលេខសម្គាល់ជារួម ឬក៏លេខសម្គាល់ដែលលេខ ERN ជាបីភាសា។

**លោក សេង ប៊ុនឃាង៖**

បាទ ដូចដែលខ្ញុំបានបញ្ជាក់ហើយ ថាលេខឯកសារគឺ E3/147 ហើយដែលមានលេខ ERN ជាភាសាខ្មែរគឺ 00679782 សូមបញ្ជាក់ រហូតដល់ 00679802 ហើយ ERN ជាភាសាអង់គ្លេសគឺមានឯកសារលេខ 00168465 ដល់ 70។ នេះជាចំណុចដែលយើងសួរបញ្ជាក់ទៅសាក្សី ហើយជាភាសាបារាំង 00698444 ដល់ 50។ ជាបន្ត សូមលោក កាំង ហ្កេកអ៊ាវ សូមលោកពិនិត្យឯកសារនេះមើល៍ ថាតើឯកសារនេះ ជាអ្វីដែរ លោកដឹងទេ? នៅត្រង់ ERN ជាភាសាខ្មែរ 00679792 មានន័យថានៅទំព័រទី១១។

[០៩:៣៧:០២]

សូមបញ្ជាក់ដែរថា នៅក្នុងឯកសារនេះ មានចំណងជើងថា “សមមិត្ត នួន ជា ថ្លែងក្នុងទិវាខួបកំណើតកងទ័ពបដិវត្តន៍កម្ពុជា” តើលោកនឹកឃើញនូវបញ្ហានេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម។ បើសិនជាមីទ្ទិងនេះមានមែន ខ្ញុំអត់បានចូលរួមទេ។ ប្រសិនបើនិយាយពីថា តើខ្លឹមសារសុន្ទរកថានេះ អាចមានមែន ឬអត់? ខ្ញុំសន្និដ្ឋានថា ពិតជាមាន។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងទេថា នៅពេលណាមួយនោះ លោក នួន ជា ធ្លាប់ជានាយករដ្ឋមន្ត្រីស្តីទី នៃរបបកម្ពុជាប្រជាធិបតេយ្យដែរទេ នៅពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ការដែលលោក ប៉ុល ពត គាត់សម្រាក មានផ្សាយ

តាមវិទ្យុថា សុខភាព ហើយឲ្យលោក នួន ជា ទៅជំនួស។ ក្នុងឋានៈជារដ្ឋមន្ត្រីស្ដីទី-- នាយករដ្ឋមន្ត្រីស្ដីទី ហ្នឹងខ្ញុំដឹង ហើយខ្ញុំបានទទួលព័ត៌មានមួយក្រៅផ្លូវការទេ ក៏ប៉ុន្តែខ្ញុំជឿថាពិត។ ព័ត៌មាននោះនិយាយថា បង ប៉ុល សម្រាក ដើម្បីរៀបចំឯកសារប្រកាសបក្សជាចំហ ឲ្យបង នួន ទៅទទួលភារកិច្ចជំនួស។ នេះ ខ្ញុំដឹង។

[០៩:៣៩:១០]

**ស៖** បាទ សូមអរគុណ។ ហើយឯកសារបន្ទាប់ទៀត គឺមានលេខ E3/25 សូមអនុញ្ញាតជូនទៅសាក្សី ដើម្បីពិនិត្យឯកសារនេះ លោកប្រធាន។

សូមលោកពិនិត្យ ហើយលោកអាចដឹងទេ តើឯកសារនេះជាឯកសារអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា ឯកសារនេះជាទស្សនាវដ្ដីផ្ទៃក្នុងបក្សកុម្មុយ-នីស្ដកម្ពុជា ឈ្មោះថាទង់បដិវត្ត។

**ស៖** តើលោកធ្លាប់ឃើញឯកសារនេះពីមុនមកទេ?

**ឆ៖** ធ្លាប់ ហើយក៏អានយកចិត្តទុកដាក់មែនទែន។ វាជាការតម្រូវឲ្យបក្ខជនគ្រប់រូបរៀនសូត្រឯកសារនេះ។ ឯកសារនេះចេញប្រចាំខែ។

**ស៖** អរគុណ។ សូមលោកពិនិត្យនៅត្រង់ទំព័រលេខ៦៩ ដែលមានជាភាសាខ្មែរ ដែលមាន ERN លេខ 006-- ម្ដងទៀត ERN ជាភាសាខ្មែរ 00063039 ជាភាសាអង់គ្លេស 00491406។ លោកពិនិត្យទៅនៅក្នុងហ្នឹងមានឃើញពាក្យជាភាសាខ្មែរហ្នឹងនូវពាក្យ បន្ទាត់ទីពីរពីក្រោមទៅវិញ។ តើលោកមានឃើញពាក្យថា ដណ្ដើមប្រជាជនដែរទេ?

**ឆ៖** ទំព័រប៉ុន្មាន? នៅក្នុង ហ្សាយឡេប នេះផ្សេងហើយ។

**ស៖** ទំព័រទី ៦៩ ជាភាសាខ្មែរ នៅក្នុង ERN លេខ 00063039។

[០៩:៤៣:០៣]

**ឆ៖** 039 ខាងចុង? បាទៗ បន្ទាត់--

**ស៖** បន្ទាត់ទីពីរពីក្រោមទៅ តើលោកឃើញពាក្យថា ដណ្ដើមប្រជាជនដែរទេនៅក្នុងហ្នឹង?

**ឆ៖** អ៎! ឃើញៗ! នៅផ្នែកខាងទីពីរ។

**ស៖** សួរថា តើចំណុចនេះមានន័យថាយ៉ាងម៉េចដែរ លោកដឹងទេ?

**ឆ៖** ពាក្យដណ្ដើមប្រជាជនពីខ្មាំងនេះ អត្ថន័យនេះដូចកែសម្រួល កែលម្អនៅឆ្នាំក្រោយមក

ហើយទេ។ ដំបូងគឺនិយាយពីជម្លៀសប្រជាជន នៅពេលវ៉ៃទីតាំងណាក៏ដោយ ជម្លៀសប្រជាជន។ ឧទាហរណ៍ ខ្ញុំជួបផ្ទាល់ហើយ នៅឧដុង្គ ពេលវ៉ៃឧដុង្គបែក ជម្លៀសប្រជាជនឧដុង្គយកទៅទុកនៅពោធិសាត់។ ហ្នឹងហើយដែលហៅថា ដណ្តើមប្រជាជនពីខ្មាំង។

**ស៖** បាទ សូមអរគុណ។ ឥឡូវសូមលោកពិនិត្យនៅទំព័របន្ទាប់ទៀត គឺទំព័រទី៧០ បើកមកមួយទំព័រទៀត។ សូមលោកពិនិត្យមើលកន្លែងដែលមានឧទាហរណ៍ទាក់ទងទៅនឹងពាក្យថា បាណាម។ ខ្ញុំសូមអានជូនតែម្តងទៅ។

**ឆ៖** បាទៗ។

**ស៖** ឧទាហរណ៍វាយខាងបាណាមនៅឆ្នាំ៧៣ យកទាំងអស់ក្នុងក្រុងបាណាម បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលិស យកទាំងអស់ ពង្រឹងប្រជាជនពីខ្មាំង។

[០៩:៤៥:១០]

**ឆ៖** ពង្រឹង!

**ស៖** បាទ

**ឆ៖** ពង្រឹង លោក--

**ស៖** បាទ ពង្រឹងប្រជាជនពីខ្មាំង។ តើលោកអាចពន្យល់បញ្ហានេះបានទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា បាណាមនៅឯណា? ខ្ញុំអត់ច្បាស់ទេ។ ប៉ុន្តែជាគោលការណ៍ វ៉ៃទីតាំងកន្លែងណា ជម្លៀសប្រជាជនចេញទៅ។ ចិនក៏ជម្លៀស វៀតណាមក៏ជម្លៀស ទាហានក៏ជម្លៀស ប៉ូលិសក៏ជម្លៀស អ្នករកស៊ីក៏ជម្លៀស ៗចេញទាំងអស់ទៅ។ ហ្នឹងហៅថា “ពង្រឹងប្រជាជនពីខ្មាំង” មិនឲ្យខ្មាំងមានកម្លាំងសេដ្ឋកិច្ច មិនឲ្យខ្មាំងមានកម្លាំងយោធា។ នេះហៅថា “ពង្រឹងប្រជាជនពីខ្មាំង”។

**ស៖** បាទ សូមអរគុណ។ តើលោកបានដឹងទេ នៅមុនខែមេសា ឆ្នាំ១៩៧៥ហ្នឹង នៅក្នុងឆ្នាំ១៩៧៤ តើមានការដណ្តើមកាន់កាប់ឧដុង្គរបស់បក្សកុម្មុយនីស្តកម្ពុជាដែរទេ?

**ឆ៖** ខ្ញុំលើកឧទាហរណ៍ជូន លោកសហព្រះរាជអាជ្ញាអំមិញហើយ ដែលខ្ញុំដឹងដំបូង រឿងជម្លៀសប្រជាជនពីឧដុង្គយកទៅទុកនៅពោធិ៍សាត់។ ខ្ញុំដឹង ព្រោះថ្ងៃណោះ ដោយចេញមនុស្សម្នាក់ពី ម-១៣ គឺសាក្សី KW-30 យកទៅជាមួយនឹងអ្នកទាំងអស់នុំងដែរ។

[០៩:៤៦:៥២]

**ស៖** បាទ សូមអរគុណ។ អឺ! ឥឡូវខ្ញុំសូមតមកសំណួរថ្មីមកទៀត សួរថាតើនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកនៅកន្លែងណាដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយ ឌុច! សូមអញ្ជើញលោកមេធាវី!

[០៩:៤៧:២៦]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអភ័យទោស ដែលខ្ញុំរំខាន ខ្ញុំឮសួរមានការយោងទៅលើសាក្សី TCW-30 នេះ បាទ KW-30 សូមឲ្យបញ្ជាក់ពីបញ្ហានេះ។

ខ្ញុំអាចសូមសួរសាក្សីដោយផ្ទាល់ក៏បាន ឬក៏ថាលោកសហព្រះរាជអាជ្ញាអាចនឹងសួរក៏បានដែរ។

**លោក វីញ្ចៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន! KW-30 គឺសំដៅទៅលើសាក្សីនៅក្នុងសំណុំរឿង០០១។ ហើយយើងខ្ញុំមិនអាចលើកនូវឈ្មោះរបស់គាត់ បង្ហាញអត្តសញ្ញាណចំឈ្មោះរបស់គាត់បានទេក្នុងពេលនេះ។

[០៩:៤៨:២០]

**ប្រធានអង្គជំនុំ៖**

ករណីនេះ សាក្សីបានប្រើប្រាស់នូវរហស្សនាមរួចហើយ ហើយសហព្រះរាជអាជ្ញាបានបញ្ជាក់ហើយថា សាក្សីនោះគឺនៅក្នុងសំណុំរឿង០០១។ ដូច្នេះបើលោកមេធាវី ចង់ដឹងថាមេធាវី-- ថាសាក្សីនោះអ្នកណាគេនុ៎ង គឺស្វែងរក និងមើលសំណុំរឿងទៅបានហើយ។ ដោយសារយើងប្រើប្រាស់រហស្សនាមនៅទីនេះ។ មូលហេតុនៃការប្រើប្រាស់រហស្សនាមលោកជ្រាបហើយ អំពីការវិធានការការពារសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថា តើខ្ញុំនឹងអាចបើកចូលទៅមើលបាន ឬមិនបានទេ។ ខ្ញុំនឹងព្យាយាមរកមើល បើសិនជារកមិនឃើញទេ សឹមខ្ញុំលើកបញ្ហានេះម្តងទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តសំណួរ!

[០៩:៤៩:៣៦]

**សួរដោយលោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួរឡើងវិញ ថានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលនោះលោកនៅកន្លែងណាដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពេលនោះខ្ញុំនៅអមលាំង នៅក្នុងមន្ទីរម-១៣(ក)។

**ស៖** ហើយថាតើនៅពេលណាលោកចូលមកទីក្រុងភ្នំពេញ? លោកនៅចាំទេ?

**ឆ៖** ខ្ញុំត្រូវមេខ្ញុំ សុន សេន គាត់ហៅខ្ញុំឲ្យមករៀនជាមួយនឹងគេ។ ខ្ញុំចេញពីអមលាំងនៅថ្ងៃ២០ ខែមិថុនា ១៩៧៥។

**ស៖** មានន័យថា លោកមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ២០ មិថុនា ៧៥?

**ឆ៖** បាទ។

**ស៖** ហើយពេលដែលលោកមកដល់ទីក្រុងភ្នំពេញដំបូងហ្នឹង តើលោកស្នាក់នៅឯកន្លែងណាដែរ? លោកនៅចាំទេ?

**ឆ៖** មេចាត់តាំងឲ្យខ្ញុំនៅមន្ទីរនីរសាររបស់គាត់ ដែលគាត់ប្រើជាកន្លែងទទួលភ្ញៀវផង គឺនៅស្ថានីយរាជាយស្ម័យយានភ្នំពេញ។

**ស៖** តើពេលនោះមានអ្នកណាខ្លះដែលរស់នៅជាមួយលោកនៅកន្លែងនុ៎ង?

**ឆ៖** មេហៅមករៀន ខ្ញុំមកមិនដឹងជាប៉ុន្មាននាក់ទេ ដូចភ្លេចទៅ។ ប៉ុន្តែខ្ញុំចាំច្បាស់ គឺពួកបក្ខជនទាំងអស់ មានខ្ញុំ អនុប្រធានរបស់ខ្ញុំឈ្មោះ ហូ គឹមអេង ហៅ ស៊ុំ ហើយប្រហែលជាបង ម៉ម ណៃ មួយទៀត ហើយប្រហែលជាមានមិត្ត មាស មួយទៀតផង មករៀនវគ្គសិក្សា។

[០៩:៥២:០៧]

**ស៖** លោកបានជម្រាបថា មេហៅលោកមករៀន តើមេនោះជានរណាដែរលោក?

**ឆ៖** មេខ្ញុំ គឺ សុន សេន។

**ស៖** បន្ទាប់មកទៀត តើលោកទៅនៅកន្លែងណាទៀត ចេញពីស្ថានីយរថភ្លើងនោះ?

**ឆ៖** ដល់រៀនវគ្គចប់ មេប្រគល់មកឲ្យខ្ញុំនៅជាមួយ ណាត។ កន្លែងនៅរបស់ ណាត អគ្គសេនាធិការរបស់ លន់ នល់ របស់ សូស្តែន។

**ស៖** តើនៅពេលណាដែលលោកចាប់ផ្ដើមការងាររបស់លោក នៅមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្ដកម្ពុជាដែលមានឈ្មោះលេខកូដថា “២១” នោះ?

**ឆ៖** ថ្ងៃ១៥ ខែសីហា ១៩៧៥ មេខ្ញុំហៅខ្ញុំទៅជួបជាមួយ ណាត នៅស្ថានីយរាជាយស្ម័យយានហ្នឹង ជាន់ខាងលើ។ ហើយគាត់ឧទ្ទេសនាមថា យើងបង្កើតមន្ទីរនគរបាលមួយ ប៉ុន្តែឥឡូវយើងឈប់ហៅនគរបាលហើយ យើងហៅសន្តិបាល។ ហើយលេខ “២១” មួយនេះ ណាត ទាមទារដាក់យកលេខ *តេអូ* បានកើតទៅជាមន្ទីរសន្តិសុខស-២១ ហ្នឹង។ ប៉ុន្តែមេឲ្យខ្ញុំប្រមូលយកកម្លាំងពីអមលាំងមកចូលភ្នំពេញសិន។ ហើយដល់កម្លាំងហ្នឹងចូលមកដល់ភ្នំពេញហើយ ទើបប្រើឲ្យខ្ញុំដើររើតាមផ្ទះអ្នកធំ មានផ្ទះលន់ នល់ ផ្ទះ សូស្ដែន ផ្ទះ វ៉ាន់ សរ កុងស៊ីខាងគិញអីហ្នឹង ប្រមូលឯកសារ។ ដល់ខែ១០ ពាក់កណ្ដាលខែ ១០ ទើបបានខ្ញុំកាន់ការនៅនុំង ក្នុងឋានៈជាអនុលេខាមន្ទីរស-២១ ឬហៅថា “អនុប្រធានមន្ទីរស-២១”។

[០៩:៥៤:៣៧]

**ស៖** តើតំណែងរបស់លោកដែលជាអនុប្រធានមន្ទីរស-២១ នេះ មានការប្រែប្រួលដែរទេបន្ទាប់មក?

**ឆ៖** ដល់ខែបី ប្រហែល១ មេដកយក ណាត ចេញទៅ ឲ្យខ្ញុំឡើងជាប្រធានមន្ទីរស-២១។ ខ្ញុំក៏ឡើងជាប្រធានមន្ទីរស-២១ ពីខែបីរហូតមក។

**ស៖** បាទ អរគុណ។ ជាបន្ត សូមលោកជួយរៀបរាប់អំពីតួនាទី និងភារកិច្ចរបស់មន្ទីរស-២១ នេះតើវាមានអ្វីខ្លះ?

**ឆ៖** មន្ទីរស-២១ នេះ វាមានតួនាទីពីរ ហើយតួនាទីហ្នឹងវាកំណត់តាំងពីកកើតដំបូង ដែលនៅជាមន្ទីរនគរបាលរបស់កងពល៧០៣ ម៉្លេះ។ វាមានកន្លែងមួយនៅព្រៃស វាមានកន្លែងមួយទៀតរបស់ ណាត នៅពេទ្យឆ្កួត នៅពេទ្យតាខ្មៅហ្នឹង។ ហើយដល់ក្រោយមកបានចាប់អ្នកសំខាន់ៗ ណាត ហ្នឹងទៅយកភូមិគ្រិះរបស់ស៊ីសុវត្ថិ មុនីរ៉េត ហ្នឹង ទុកមនុស្សសំខាន់ៗនៅទីនុំង។ ដល់ពេលខ្ញុំចូលទៅដល់នេះ ប្ដូរៗ មកនៅខាងលិចសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះបន្តិច។

[០៩:៥៦:២២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ដឹងថា តើមុខងារភារកិច្ចរបស់មន្ទីរស-២១ ហ្នឹងមានអ្វីខ្លះ? សូមលោកជួយរៀបរាប់អំពីមុខងារភារកិច្ចនេះ?

**ឆ៖** តាមទីតាំងនៅភ្នំពេញវាប្ដូរអីចឹង ក៏ប៉ុន្តែទីតាំងគឺ-- ទីតាំងវាប្ដូរអីចឹង ប៉ុន្តែភារកិច្ចគឺយក

មនុស្សមកសួរចម្លើយ ហើយកម្ទេច។ នៅក្នុងសម័យ ណាត ច្រើនតែប្រមូលពួកមន្ត្រីចាស់ពីជនបទ ហើយនិងកម្មករទីក្រុងដែរ យកមកសួរចម្លើយ ហើយកម្ទេច។

**ស៖** បាទ អរគុណ។ ការសួរចម្លើយ ហើយបន្ទាប់មកកម្ទេច។ នៅពេលសួរចម្លើយមានធ្វើទារុណកម្មអីដែរទេនៅពេលនុ៎ង?

**ឆ៖** បញ្ហាទារុណកម្មនេះ ដូចខ្ញុំបានរាយការណ៍ម្សិលមិញហើយថា វាក្រឹត្យក្រមហូរហែតាំងពីសម័យឥស្សរៈរហូតមកសម័យ៧៩ ហើយអត់ទាន់កែទេ។ របៀបវ៉ៃសួរចម្លើយ ធ្វើទារុណកម្មសួរចម្លើយ។ ដូច្នេះនៅស-២១ ហ្នឹងក៏វាទៅតាមរបត់ហ្នឹង។

**ស៖** បាទ តើលោកអាចបញ្ជាក់បានទេថា មូលហេតុអ្វីបានជាត្រូវធ្វើការសួរចម្លើយ ធ្វើទារុណកម្ម ហើយកម្ទេចយ៉ាងដូច្នេះ?

**ឆ៖** សំណួរនេះ ខ្ញុំលំបាកឆ្លើយណាស់ សូមលោកព្រះរាជអាជ្ញារៀបចំឲ្យស្រួលយល់ ស្រួលឆ្លើយបន្តិច។

**ស៖** សំណួរគឺចង់សួរថា អ្នកដែលត្រូវបានចាប់មកចូលមកស-២១ តើហេតុអីបានចាំបាច់ត្រូវកម្ទេច?

[០៩:៥៨:៥៥]

**ឆ៖** បញ្ហាត្រូវកម្ទេចនេះ វាជាក្រឹត្យក្រម ជាគោលនយោបាយរបស់បក្សដែលតម្រូវឲ្យធ្វើអ៊ីចឹង។ ខ្ញុំមិនសូមលើកឧទាហរណ៍ដែលខ្ញុំជួបប្រទះទេ វែង ក៏ប៉ុន្តែមនុស្សដែលចាប់ចូលហើយ គឺកម្ទេច។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការធ្វើទារុណកម្ម ការកម្ទេចអីហ្នឹង តើមាននរណាជាអ្នកបញ្ជាលោកឲ្យធ្វើបញ្ហាហ្នឹងដែរទេ?

**ឆ៖** ខ្ញុំសូមញែកពាក្យថា "បញ្ជា" ហើយនិងពាក្យ "ភារកិច្ច"។ ភារកិច្ច កំណត់ម្តងជាការស្រេច។ បញ្ជាវាចំពោះមុខ ចំពោះកិច្ច។ បើនិយាយអំពីបញ្ហាបញ្ជាចំពោះកិច្ច គ្មានទេ។ ក៏ប៉ុន្តែបើនិយាយអំពីភារកិច្ចវាហូរហែ ជាក្រឹត្យក្រមហូរហែមក ដែលមន្ទីរនគរបាលណាក៏ធ្វើ។

**ស៖** តើនេះជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏អ្វីដែរ?

[០៩:៥៩:៥៩]

**ឆ៖** ប្រាកដជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហើយ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា អ្នកដែលគេចាប់ចូលមន្ទីរស-២១ នោះត្រូវបានគេចោទប្រកាន់ពីបទល្មើសអីដែរ បានគេចាប់ចូលទៅអ៊ីចឹង?

**ឆ៖** តាមការដែលខ្ញុំពិនិត្យឡើងវិញ មួយរយៈកាលដំបូងក្នុងរយៈកាលដែល ណាត គាត់នៅធ្វើប្រធាន ហាក់ដូចជាប្រមូលបញ្ញាជន ដូចដុកទ័រ រ័ត្ន គត់ គាត់មានធ្វើអីខុស? ប៉ុន្តែចាប់យកគាត់មកចូលមន្ទីរស-២១។ ទិព ម៉ម សាស្ត្រាចារ្យមហាបរិញ្ញា គាត់មានធ្វើអីខុស ចាប់គាត់យកមកចូល ស-២១។ ប្រពន្ធ ថាច់ ជា វាជារឿងធ្វើអីខុសផ្ទាល់? អត់ទេ តែចាប់យកមកសំដៅពួកនុ៎ងៗ។ នេះរយៈកាលដំបូងនៅពេលដែល ណាត គាត់ធ្វើប្រធាន។

[១០:០១:២៧]

**ស៖** បាទ អរគុណ។ ក្រៅពីប្រភេទមនុស្សដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះ តើមានប្រភេទមនុស្សណាខ្លះដែលត្រូវបានចាប់ចូលក្នុងមន្ទីរស-២១ នេះ?

**ឆ៖** អង្កាល់សម័យ ណាត មាន។ គង់ សុជាតិ ហៅ សឿន កូនរបស់ គង់ សុផល ហៅ កឺ មិនដឹងជាមានបាតុភាពស្អីទេ ចាប់មកចូលស-២១ សម័យ ណាត។ សុន សេន គាត់ប្រាប់ថា មិត្តកុំអាល់ទាន់វ៉ៃ ខ្ញុំទៅសុំយោបល់ខាងលើសិន ឲ្យដោះលែង ឬក៏ទុក? ដល់ក្រោយមក គាត់សម្រេចថា មិត្តវ៉ៃសួរចម្លើយ ហើយកម្ទេចទៅ។ សូមបញ្ជាក់ថា គង់ សុជាតិ ហៅ សឿន នេះ វាវរសេនាធំអង្កាល់នុ៎ង។ ដូច្នេះផ្ទៃក្នុងចាប់ផ្តើមមានពី គង់ សុជាតិ ហៅ សឿន ហ្នឹងហើយ ក៏ប៉ុន្តែផ្ទៃក្នុងដែលចូលមក ស-២១ គឺសម័យខ្ញុំដែលច្រើន។ សម័យដែលខ្ញុំធ្វើប្រធាន គឺច្រើន។

**ស៖** ចង់ៗឲ្យលោកជួយបញ្ជាក់អំពីប្រភេទៗមនុស្សដែលត្រូវបានចាប់បញ្ជូនចូលស-២១ ហ្នឹង តើលោកអាចញែកជាប្រភេទ តើប្រភេទមនុស្សយ៉ាងម៉េចខ្លះដែរទេ?

[១០:០៣:០៤]

**ឆ៖** អត់ដែលបានគិតទេ ដូច្នេះសូមសាកល្បងសរុបបញ្ហាចាស់ឡើងវិញ។ អង្កាល់សម័យ ណាត ទីមួយច្រើនឃើញបញ្ញាជន ទីពីរកម្មករ ដូចកម្មកររោងចក្រធ្វើក្រដាសចាក់អង្រែអ៊ីចឹង យកមកស្ទើរតែទាំងអស់។ ដោយសារបាតុភាពឆេះរោងចក្រ ហ្នឹងមួយប្រភេទទៀត។ មួយប្រភេទទៀត ដូចជាពួកអ្នកនេសាទរបស់ថៃ ឃើញតែបញ្ជីទេ ខ្ញុំមិនដឹងជាមកពីអង្កាល់ទេ? អាហ្នឹងមួយប្រភេទទៀត។ ខ្ញុំជឿថាបញ្ជីហ្នឹងវាមានហើយ អត់មានអ្នកណាទៅប្រឌិដ្ឋអីទេ ហ្នឹងពួកអ្នកនេសាទថៃមិនដឹងប៉ុន្មានទេ ដូច៣០០ អីអ៊ីចឹងមិនដឹង។ ហើយក្រោយមក លេចចេញបញ្ជីមួយទៀត ពួកមូស្លីមនៅភូមិអារ៉ាប់ៗ

ហ្នឹងរកស៊ីតែចិញ្ចឹមគោក្របីលក់ទេ ដល់ក្រោយមកឃើញបញ្ជីនៅនោះទៀត។ ខ្ញុំទទួលស្គាល់ថា ស-២១ បានកម្ទេចបញ្ហាហ្នឹងសម័យ ណាត។ ដូច្នេះ សរុបមកមានផ្ទៃក្នុងៗអាចមានច្រើនដែរ ប៉ុន្តែខ្ញុំចាំម្នាក់ ហើយពួករណសិរ្ស ហួត សម្បត្តិ ហួត អ៊ីហ្នឹង។ អ៊ី ស៊ុបគន្ធី, វត្ន សម្បត្តិ អ៉ំនែ ហួត សម្បត្តិ។

[១០:០៤:៤៥]

**ស៖** តើអ្នកទាំងនោះមានអ្នកណាខ្លះ ដែលជាកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែរទេនៅក្នុង--

[១០:០៥:០០]

**ឆ៖** កម្មាភិបាលជាន់ខ្ពស់ពិបាកនិយាយណាស់។ នៅក្នុងឆ្នាំ១៩៧៥ រវាងខែ១០ ខែអីហ្នឹង ដែល គង់ សុជាតិ ហៅ សឿន ហ្នឹង វាចូលមក វាៗជាកម្មាភិបាលជាន់ខ្ពស់ជាងគេហើយជំនាន់នុ៎ង។ ដល់ក្រោយមក សម័យខ្ញុំ សួ សុផាន អនុលេខាកងពល១៧០ ជាកម្មាភិបាលជាន់ខ្ពស់ជាងគេ។ ដល់ក្រោយមកទៀត កុយ ធួន គាត់ជាកម្មាភិបាលជាន់ខ្ពស់ជាងគេ មកជាប់នៅនុ៎ង។ ដូច្នេះ វាវិវត្តន៍ទៅតាមនុ៎ង។ កម្មាភិបាលនិយាយឲ្យចប់ សម្រិតសម្រាំងផ្ទៃក្នុង គឺចាប់ឡើងនៅពេលដែលលេចរឿង យឹម សម្បត្តិ បោកគ្រាប់បែកក្រោយវាំង នៅថ្ងៃ២ ខែមេសា ១៩៧៦។ ហើយនិងក្រោយពេលដែល កុយ ធួន ឆ្លើយសារភាពនៅ ស-២១ នៅថ្ងៃ២៩ ខែ-- បើមិនមករា ធ្នូ ១៩៧៥ ឬចិតសិប-- អ៉ំ! ៧៦ ឬ៧៧។ អត់ទេ គាត់ឆ្លើយសារភាពនៅថ្ងៃ២៩ ធ្នូ ១៩៧៦។ ចាប់ពួកឧត្តរចូលមក នុ៎ងសុទ្ធតែកម្មាភិបាលហើយ នៅថ្ងៃ១ មករា ១៩៧៧ ហ្នឹងចាប់ផ្តើមសម្រិតសម្រាំងផ្ទៃក្នុង។ ហ្នឹងដូច្នេះ ការសម្រិតសម្រាំងផ្ទៃក្នុងយើងអាចនិយាយបានថា ក្រោយផ្ទុះគ្រាប់បែកក្រោយវាំង ហើយនិងក្រោយពេលដែល កុយ ធួន សារភាព។ ហ្នឹងភាគច្រើនសុទ្ធផ្ទៃក្នុងហើយ។

[១០:០៧:០០]

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេថា នៅមន្ទីរស-២១ ហ្នឹង ទូទាំងពេញរយៈពេលហ្នឹង តើមានអ្នកដែលត្រូវគេចាប់ខ្លួន ហើយក្រោយមកត្រូវបានសម្លាប់ មានសរុបទាំងអស់ប៉ុន្មាននាក់ លោកនៅចាំទេ?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំអត់ចាំទេ ប៉ុន្តែបញ្ជីវាច្បាស់ហើយ។ ខាងការិយាល័យសហព្រះរាជអាជ្ញាហ្នឹង រៀបចំបញ្ជីហ្នឹង ១២.២៧៣នាក់។ ហើយបញ្ជីហ្នឹង ខ្ញុំអត់ដែលប្រកែកទេ ខ្ញុំទទួលស្គាល់។

**ស៖** បាទ ឥឡូវខ្ញុំសូមបន្តទៅអំពីតួនាទីរបស់លោកដែលជាប្រធានមន្ទីរស-២១ ហ្នឹង។ ថាតើ

លោកកាន់តំណែងជាប្រធានមន្ទីរស-២១ នេះ អ្នកណាគេជាអ្នកតែងតាំងលោកដែរ?

**ឆ៖** មេខ្ញុំ សុន សេន។

**ស៖** ចុះអ្នកដែលគ្រប់គ្រងលោកផ្ទាល់វិញ តើអ្នកណា?

**ឆ៖** ខ្ញុំសូមនិយាយញែកបញ្ហានេះជាពីរ។ ស-២១ នេះ វាជាវរៈសេនាធំឯករាជ្យរបស់កងទ័ពមជ្ឈិម។ ដូច្នេះ ខាងភស្តុភារ ខាងអាវុធយុទ្ធភណ្ឌ ខាងទៅរៀនសូត្រ ខាងព្យាបាលអី វានៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការសេនាធិការ។ គេចាត់ចែងតាមមុខងាររបស់គេ។ ដោយឡែក រឿងសំណុំរឿង ដែលជាចម្លើយសារភាពរបស់មនុស្សដែលទៅរងគ្រោះជាអ្នកទោសនៅស-២១ នោះ គឺខ្ញុំរាយការណ៍ផ្ទាល់ទៅ សុន សេន។ ហើយខ្ញុំរាយការណ៍ផ្ទាល់ទៅ សុន សេន ហ្នឹង រហូតដល់ថ្ងៃ១៥ ខែសីហា ១៩៧៨ ដែលគាត់មានភារកិច្ចទៅបោះទីតាំងនៅអ្នកលឿង។ ហើយបន្ទាប់ពីនោះមក ខ្ញុំជួបបងទីពីរ នួន ជា នេះ ដែលខ្ញុំឡើងចុះទៅរាយការណ៍ជូនគាត់។

[១០:១០:០០]

**ស៖** តើលោកក្នុងនាមជាប្រធាននៃមន្ទីរ ស-២១ លោកមានតួនាទីធ្វើអ្វីដែរ ភារកិច្ចរបស់លោកក្នុងមន្ទីរ ស-២១?

**ឆ៖** ភារកិច្ចរួមវាម្យ៉ាងហើយ ក៏ប៉ុន្តែភារកិច្ចចំពោះមុខ ដែលរវល់ជាប់រកពេលសម្រាកមិនបាន គឺអាន ហើយនិងសង្ខេបបន្តិចៗចម្លើយសារភាព ដើម្បីឱ្យមេស្រួលស្តាប់។ ចំណារខ្ញុំទាំងអស់ជាភស្តុតាងស្រាប់។ ដូច្នេះរវល់អារឿងហ្នឹងជាសំខាន់។ ហើយដល់ក្រោយមក រឿងយកមនុស្សយកអីទៅប្រគល់ឱ្យ ស-២១ មិត្តលីន គាត់ទៅត្រង់ៗដល់មិត្ត ហ៊ តែម្តង មិនបាច់ឆ្លងខ្ញុំទេ។ ពីលើកមុនទាល់តែឆ្លងខ្ញុំទៀត។ ហាក! គេឱ្យមកប៉ុណ្ណេះ ចាំទទួលអីៗ។ អានហ្នឹងឆ្លងខ្ញុំ។ ឯរឿងសម្រេចនាំអ្នកដែលសួរចម្លើយយកទៅកម្ទេចនៅបឹងជើងឯក។ មុនដំបូងមិត្ត ហ៊ គាត់អត្តនោម័តិ ហ្នឹងព្រោះហ្នឹងជាភារកិច្ចរបស់គាត់។ ប៉ុន្តែចាប់តាំងពីពេលដែលមិត្ត ហ៊ ច្រឡំយកម្នាក់ទៅកម្ទេចបាត់ទៅ សុន សេន ស្តីឱ្យ។ ដូច្នេះខ្ញុំក៏ត្រូវតែឱ្យគាត់សុំយោបល់ ថាយកទៅបានទេ? សួរចប់ហើយនៅ? ហ្នឹងភារកិច្ចរបស់ខ្ញុំប៉ុណ្ណឹង។

[១០:១១:៤៩]

ទីមួយ រាយការណ៍អំពីចម្លើយសារភាពជាប់ជាប្រចាំ។ ទីពីរ ត្រួតពិនិត្យមើលមនុស្សដែលគេសួរចប់បញ្ចេញយកទៅជើងឯក។ ទីបី រៀបចំទទួលមនុស្សដែលគេបញ្ជូនមក ចាត់ចែងឱ្យគេទទួលយ៉ាងម៉េចអីយ៉ាងម៉េច អ្នកណាអ្នកទទួលអី ទាល់តែឆ្លងខ្ញុំសិន។ ឯចំណែកក្រៅពីនោះ ដើម្បីឱ្យកិច្ចការ

ហ្នឹងវាដំណើរការបានល្អ កុំឱ្យចម្លើយហ្នឹងវាចេះតែវាលដាល ខ្ញុំក៏មានភារកិច្ចមួយទៀត គឺបង្រៀនមនុស្សឱ្យសួរ។ ឯកសារមានស្រាប់។

**ស៖** តើក្រៅពីការងាររបស់លោកដែលបានរៀបរាប់ជូនអង្គសវនាការអម្បាញ់មិញនេះ តើមានការងារអ្វីផ្សេងទៀត ដូចជាការបង្រៀន ឬក៏ការអប់រំគោលនយោបាយរបស់បក្សជូនដល់កម្មាភិបាលនៅមន្ទីរ ស-២១ ដែលមានដែរឬទេ?

**ឆ៖** ជារៀងរាល់ឆ្នាំ សេនាធិការហៅខ្ញុំទៅរៀន។ ខ្ញុំទៅគ្នាតែប៉ុន្មាននាក់ទេ។ ពីរបីនាក់ ឬក៏ដូចទៅតែខ្ញុំតែម្នាក់ឯងមួយសារទៅ។ ដល់ក្រោយមក ខាងមន្ទីរសេនាធិការនេះ គេប្រមូលពួកកម្មាភិបាលខាងក្រោមទៅរៀនមួយសាទៀត។ ឯចំណែកខ្ញុំប្រមូលយុទ្ធជន យុទ្ធនារីខាងក្រោមយកមកបង្រៀនរាល់ឆ្នាំ ជាទៀងទាត់។ ឯចំណែកដោយឡែក នៅពេលខ្លះសភាពការណ៍បន្ទាន់ ខ្ញុំក៏បើកវគ្គបង្រៀនដែរ អំពីគោលនយោបាយរបស់បក្ស។

**ស៖** តើការបង្រៀនអំពីគោលនយោបាយរបស់បក្ស ដែលលោកបានបង្រៀនហ្នឹង គឺលោកបង្រៀនទៅនរណាខ្លះបុគ្គលិករបស់លោក ហើយមាននរណាទៀតផ្សេងពីហ្នឹងដែរទេ? ដូចជាអ្នកទោសអីមានបង្រៀនទេ?

**ឆ៖** អ្នកទោសគ្នាគ្មានសិទ្ធិមករៀនទេ។ អត់ទេ។

**ស៖** បាទ សូមអរគុណ។ ហើយលោកចាំទេ ថានៅពេលណាដែលលោកឈប់ធ្វើការងារនៅមន្ទីរស-២១ ហ្នឹង?

**ឆ៖** រឿងឈប់គឺទាល់តែពេលដែលកងទ័ពវៀតណាមគេបើករថក្រោះមកដល់មុខផ្ទះខ្ញុំ ម៉ោងមួយដណ្ដប់ ថ្ងៃទី០៧ មករា ១៩៧៩។

**ស៖** ខ្ញុំសូមត្រឡប់មកការបង្រៀនរបស់លោកអម្បាញ់មិញ តើក្រៅពីគោលនយោបាយរបស់បក្ស លោកបានបង្រៀនអ្វីផ្សេងទៀតដែរទេ?

[១០:១៥:00]

**ឆ៖** ខ្ញុំ ក្រៅពីគោលនយោបាយរបស់បក្ស ខ្ញុំនិយាយអំពីរបៀបសួរ នេះម្យ៉ាង ហើយស្មារតីប្រុងប្រយ័ត្នក្នុងរឿងសួរ កុំឱ្យចេះតែបែកពាសវាលពាសកាល។ ភស្តុតាងគឺមាននៅក្នុងឯកសារ ក.ណ.ហ ១៦៦ ដែលបង ម៉ម ណៃ ចារទុក ទាំងវគ្គដែលគាត់ទៅរៀននៅសេនាធិការ ទាំងការដែលខ្ញុំបង្រៀននៅ ស-២១។ ឯកសារ ក.ណ.ហ ១៦៦។

**សះ** តើការបង្រៀនរបស់លោកហ្នឹងយ៉ាងម៉េចដែរ?

**ឆះ** ខ្ញុំមិនចេះឆ្លើយទេ សូមលោកមានប្រសាសន៍សួរឲ្យ--

**សះ** ចង់បានន័យថា អឺ! ការបង្រៀនរបស់លោកទៅកម្មាភិ-- បុគ្គលិករបស់លោកហ្នឹង តើ-- អឺចេះខ្ញុំសូមចូលសំណួរថ្មីមួយទៀតចោះ។ នៅពេលដែលលោកធ្វើការមន្ទីរ ស-២១ ហ្នឹង តើលោករៀបការហើយនៅពេលនុ៎ង? លោកនៅលីវ ឬក៏រៀបការហើយ?

**ឆះ** ខ្ញុំរៀបការនៅថ្ងៃ២០ ធ្នូ ១៩៧៥ នៅលង្វែក។ ប្រពន្ធខ្ញុំគាត់ជាមនុស្សខាងនិរតីរបស់តាម៉ុក។

[១០:១៦:៤៥]

**សះ** តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា អំពីកាលៈទេសៈដែលលោកឈានទៅដល់ការរៀបការហ្នឹង តើវាយ៉ាងម៉េចខ្លះ អីយ៉ាងម៉េចខ្លះ?

**ឆះ** ខ្ញុំចាប់ផ្ដើមគិតគូរអំពីបញ្ហាជ្រើសរើសគូស្រករប្រហែលជាអាចនៅក្នុងឆ្នាំ១៩៧៣ ហើយក៏ចាប់អារម្មណ៍ជាមួយនឹងប្រពន្ធខ្ញុំនេះ នៅក្នុងឆ្នាំ១៩៧៤។ ហើយក៏ឲ្យមិត្តភក្ដិខ្ញុំដែលគេកាន់កាប់ប្រធានមន្ទីរភូមិភាគនិរតី ឈ្មោះហៅ "មន្ទីរ២០១" ហ្នឹង ទៅសួរយោបល់ប្រពន្ធខ្ញុំ។ ដល់សួរយោបល់ប្រពន្ធខ្ញុំ ប្រពន្ធខ្ញុំគាត់ឆ្លើយ ថាស្រេចនឹងអង្គការ។ ដល់ហើយមិត្តនុ៎ង ក៏គេដោះស្រាយទៅ ទៅរាយការណ៍សុំយោបល់ តាម៉ុក, តាម៉ុក ក៏គាត់សុខចិត្ត។ ដល់ក្រោយមក បានខ្ញុំរាយការណ៍ជូនមេខ្ញុំ។ រួចថ្ងៃក្រោយមកហ្នឹង ណាត រៀបការឲ្យខ្ញុំក្រោយគាត់ទេ នៅថ្ងៃ២០ ខែធ្នូ ឆ្នាំ១៩៧៥នេះ។ ដូច្នេះជាបញ្ហា ប្រពន្ធខ្ញុំនេះ ខ្ញុំជ្រើសរើស អត់មានអង្គការណាបង្ខំទេ ខ្ញុំជ្រើសរើសដោយខ្ញុំស្រឡាញ់គាត់។ ហើយសូមបញ្ជាក់ថា ថ្ងៃការហ្នឹងម្ដាយខ្ញុំគាត់អញ្ជើញទៅឲ្យពរកូនទាំងពីរហ្នឹងដែរ។

[១០:១៨:១៦]

**សះ** តើការរៀបការរបស់លោកហ្នឹង លោកមានត្រូវសុំការអនុញ្ញាតពីខាងណា ឬក៏មានខាងណាអនុញ្ញាតឲ្យលោករៀបការហ្នឹងដែរទេ?

**ឆះ** ខ្ញុំបាននិយាយជម្រាបរួចហើយ គឺខាងកូនស្រី មិត្តសំ ឈ្មោះដើម ម៉ៃ សាខន នោះ ប្រធានមន្ទីរភូមិភាគនិរតីហ្នឹងទៅជម្រាប តាម៉ុក, តាម៉ុក គាត់អនុញ្ញាត។ ដល់ក្រោយមក ខ្ញុំជម្រាបមេខ្ញុំ សុន សេន ហ្នឹង ក៏គាត់អនុញ្ញាត។ បាន ណាត ហ្នឹងអ្នករៀបចំពិធីមង្គលការឲ្យខ្ញុំ។

**សះ** បាទ បន្ទាប់ពីលោករៀបការហើយ តើលោកមានកូនទេនៅពេលនុ៎ង?

**ឆ៖** ខ្ញុំមានកូនពីរ មុនរត់យួន។ កូនទីមួយកើតនៅថ្ងៃ២៧ ខែមេសា ១៩៧៧។ កូនទីពីរ ដូចកើតនៅថ្ងៃ១៤ ធ្នូ ១៩៧៨។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន! តើគួរបន្តទៅទៀត?

[១០:១៩:៤៣]

**ប្រធានអង្គជំនុំ៖**

តទៅដល់ម៉ោងដប់កន្លះ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បន្ទាប់ពីលោកចាកចេញពី ស-២១ នៅឆ្នាំ១៩៧៩ហ្នឹងហើយ តើលោកនៅតែជាបន្តជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាដដែល ឬយ៉ាងណា?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** បើនិយាយអំពីប្រជុំជីវភាពអត់មានទេ។ ក៏ប៉ុន្តែខ្ញុំរត់ទៅនេះ ទៅជ្រកនឹងគេដើម្បីបានអង្ករហូប។ រត់ចេញពីភ្នំពេញទៅ ទៅនៅបស្ចិម សូមជ្រកកោនជាមួយនឹងភូមិភាគបស្ចិម ដែលមានឈ្មោះប៉ាល់ ឈ្មោះដើម ហួត ហេង ហ្នឹងជាអនុលេខាភូមិភាគបស្ចិម។ ដល់ក្រោយមករត់តទៅទៀត ខ្ញុំទៅនៅពាយព្យ ទៅជ្រកកោននឹងបង សារុន អនុលេខារបស់ភូមិភាគពាយ័ព្យ។ សុំអង្ករគេហូប។ ដូច្នេះរឿងប្រជុំជីវភាព រឿងភារកិច្ច វែស្សូរចម្លើយអីអស់ហើយ គ្មានទេ។

[១០:២០:៥៨]

**ស៖** ប៉ុន្តែតើពេលនោះ លោកនៅតែជាបន្តជីវភាពរបស់លោកជាសមាជិកបក្សដែរឬទេ?

**ឆ៖** --ប្រជុំទេ ដូច្នេះតែដាច់ប្រជុំ គឺហៅថាអស់ជីវភាពបក្សហើយ។ ក៏ប៉ុន្តែជាគោលការណ៍ខ្ញុំដូចជានៅតែគេទទួលស្គាល់ថា ជាបក្ខជនដើងចាស់។ ជាពិសេសជាមួយមេខ្ញុំ ថ្ងៃ២៥ មិថុនា ឆ្នាំ១៩៨៦ មេខ្ញុំហៅយកទៅប្រើឡើងវិញ សុន សេន។

[១០:២១:៣៣]

**ស៖** សុន សេន ដែលហៅយកលោកយកទៅប្រើឡើងវិញ ប្រើលោកឲ្យធ្វើអ្វីដែរ លោកចាំទេ?

**ឆ៖** ដំបូងគាត់បញ្ជូនខ្ញុំឲ្យទៅបង្រៀនកូនសិស្សចិននៅប៉េកាំង តាមពិតអ្នកបញ្ជូនទៅហ្នឹងគឺមេធំផុតលេខនោះ បង ប៉ុល គាត់បញ្ជូនខ្ញុំទៅ។ ទៅបង្រៀនកូនសិស្សចិននៅប៉េកាំង ខាងភាសាខ្មែរ។

**ស៖** ហើយពេលណាលោកត្រឡប់មកប្រទេសកម្ពុជាវិញ?

**ឆ៖** ខ្ញុំទៅឆ្នាំ១៩៨៦ ឆ្នាំ១៩៨៨ ដូចថ្ងៃ៣០ មិថុនា អីចេះមិនដឹង ខ្ញុំត្រឡប់មកវិញ។ ខ្ញុំទៅពីរឆ្នាំ។

[១០:២២:៣១]

**ស៖** នៅពេលដែលលោកត្រឡប់មកវិញ តើលោកធ្វើការងារអីដែរ?

**ឆ៖** ខ្ញុំនៅមន្ទីរក-១៨ ក្រោមការគ្រប់គ្រងរបស់បង អាត គឺអ្នកបង យុន យ៉ាត ប្រពន្ធ សុន សេន នេះ ខាងសរសេរសៀវភៅ សិក្សា សៀវភៅបឋមសិក្សា។

**ស៖** តើនៅពេលហ្នឹង លោកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដដែល ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់បុគ្គល ដែលជាអតីតថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដដែល ព្រោះបក្សហ្នឹងប្រកាសរំសាយនៅឆ្នាំ១៩៧៣-- អំ ៨៣ រួចទៅហើយ។

[១០:២៣:៣៧]

**ស៖** តើលោកនៅចាំទេថា អ្នកគ្រប់គ្រងរបស់លោកនៅពេលនោះអ្នកណាខ្លះទៅ? មានអ្នកណាខ្លះ?

**ឆ៖** អ្នកគ្រប់គ្រងផ្ទាល់ខាងសរសេរសៀវភៅហ្នឹង គឺបងអាត, សុន សេន ប្រពន្ធ សុន សេន ហ្នឹងខាងសរសេរសៀវភៅ។ ក៏ប៉ុន្តែខាងជីវភាពខាងអី គឺមន្ទីរក-១៨ ហ្នឹង គេផ្គត់ផ្គង់។

**ស៖** បន្ទាប់ពីនោះមកទៀត តើលោកទៅរស់នៅកន្លែងណាដែរ? លោកចាំទេ? ជាពិសេសនៅដូចជានៅឆ្នាំ១៩៩២ អីហ្នឹង តើលោកទៅណាដែរពេលនុ៎ង?

**ឆ៖** ខ្ញុំ--

**ស៖** ប្រហែលជាមានការបកប្រែច្រឡំ ថ្ងៃខែឆ្នាំហ្នឹង គឺឆ្នាំ១៩៩២ បាទ។

[១០:២៥:០០]

**ឆ៖** ខ្ញុំ-- ប៉ុល ពត គេអត់-- ឱ្យចាត់តាំងទៅធ្វើសេដ្ឋកិច្ចនៅជនបទ។ ដល់ក្រោយមក មានសភាពការណ៍ខ្មែរក្រហមពហិការមិនព្រមបោះឆ្នោតសកលហ្នឹង ហើយវាមានការខាងរដ្ឋាភិបាលនេះគេវ៉ៃរំលាយមូលដ្ឋានរបស់ ប៉ុល ពត នៅក្តិបថ្ម ខ្ញុំក៏ជាប់នៅនុ៎ងទៅ។ ដូច្នេះ ៩២ ហ្នឹង ៩១, ៩២ ខ្ញុំទៅៗកោះផ្គាំភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

**សៈ** តើលោកនៅផ្គាំ ហ្នឹងរហូតដល់ពេលណាដែរ ហើយមូលហេតុអីបានលោកចាកចេញ?

**ឆៈ** ខ្ញុំនៅផ្គាំនេះ រហូតដល់ខែប្រាំពីរ ឆ្នាំមួយពាន់ប្រាំបួនរយកៅ-- ដូច៩៧ នៅពេលដែល រណឫទ្ធិ បះបោរតទល់ជាមួយ ហ៊ុន សែន ឆ្នាំ នុ៎ង។ ខ្ញុំចេញទៅសំឡូត។

**សៈ** ហើយបន្ទាប់មកទៀត លោករស់នៅសំឡូតហ្នឹង លោកធ្វើអ្វីដែរនៅពេលនុ៎ង?

**ឆៈ** នៅសំឡូតនេះ ខ្ញុំនៅតែបន្តមុខរបបរបស់ខ្ញុំជាគ្រូបង្រៀន ខាងស្រុកសំឡូតនេះ គេឲ្យខ្ញុំធ្វើជាប្រធានការិយាល័យអប់រំស្រុក។ ប៉ុន្តែមិនបានទទួលអនុក្រឹត្យតែងតាំងទេ ក៏ខ្ញុំមកនេះមក។

[១០:២៧:១៧]

**សៈ** លោកនៅសំឡូតហ្នឹងរហូតដល់ពេលណាដែរ?

**ឆៈ** មើលខ្ញុំគេយកមក ចេញមកដូចថ្ងៃ-- គេយកខ្ញុំចេញពីសំឡូតមកនៅថ្ងៃ៦ ខែឧសភា ឆ្នាំ ១៩៩៩។

**សៈ** តើអំឡុងពេល រយៈពេលដែលលោកនៅសំឡូតហ្នឹង រហូតមកដល់មុនថ្ងៃ ៦ ឧសភា ៩៩ តើលោកធ្វើអ្វី? នៅទីណាដែរ?

**ឆៈ** ប្រហែលជា៩៧ ហ្នឹងដែរ តាម៉ុក គាត់បះបោរប្រឆាំងនឹងរដ្ឋាភិបាល កៀងកេណ្ឌប្រជាជនពីខាងសំឡូត ខាងកោះកុងហ្នឹងយកទៅដីថៃ ប្រាថ្នាកសាងកម្លាំងវ៉ៃរដ្ឋាភិបាល ហ៊ុន សែន នេះឡើងវិញ។ ខ្ញុំក៏ត្រូវកេណ្ឌទៅនឹងគេ។ ខ្ញុំត្រឡប់មកវិញដូចក្នុងឆ្នាំ៩៨ មុនបោះឆ្នោតបន្តិច។ ហើយក៏បន្តការងាររបស់ខ្ញុំជាគ្រូបង្រៀន ជាប្រធានការិយាល័យអប់រំស្រុកដដែលឡើងវិញ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ឥឡូវឃើញថា ពេលវេលាដល់ម៉ោងដប់សាមសិបនាទីហើយ តើយើងគួរបន្ត ឬក៏សម្រាកសិនបាទ?

[១០:២៩:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាកហ្នឹង ហើយឲ្យនាំគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅ-- ឲ្យបានមុនអង្គជំនុំ-

ជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញ លោកមេធាវី!

[១០:២៩:៤៥]

**លោក អាង ឧត្តមៈ**

សូមអរគុណលោកប្រធាន។ ហើយសូមជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់។ ដោយសារមូលហេតុសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹងខ្នង និងជើង លោក អៀង សារី ស្នើសុំថ្ងៃនេះលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងសវនាការនេះ ក៏ប៉ុន្តែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោមសម្រាប់រយៈពេលមួយថ្ងៃនេះពេញតែម្តង។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាតតាមសំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំៈ**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលធ្វើឡើងតាមរយៈមេធាវីរបស់គាត់។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំ តែតម្រូវឲ្យក្រុមមេធាវីការពារជនជាប់ចោទប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬក៏ស្នាមម្រាមដៃជាក់ច្បាស់ពីលោក អៀង សារី។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់សវនាការថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជីៈ**

ក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥០ នាទី)*

[១០:៥០:៥០]

**ក្រឡាបញ្ជីៈ**

សូមអញ្ជើញក្រោកឈរ!

[១០:៥១:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ មុននឹងបន្ត សូមរម្លឹកដល់តំណាងសហព្រះរាជអាជ្ញាជាមួយនឹងភាគីដទៃទៀត សូមជម្រាបថា លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះក្នុងនាមសាក្សី។ ដូច្នេះការតាំងសំណួរ សូមឲ្យតាំងសំណួរណាដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលជាដំបូងនេះ គឺពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលបានធ្វើសវនាការរួចមកហើយ ប្រសិនបើសាក្សីដឹងនូវប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ហើយនិងអង្គហេតុនៅវគ្គពីរ ដែលយើងបានកំណត់រួចហើយ។ នេះជាមូលដ្ឋាននៃការសួរដេញដោលចំពោះសាក្សី ហើយប្រសិនបើសាក្សី គាត់ដឹងអំពីអង្គហេតុផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១នោះ អង្គជំនុំជម្រះនឹងអនុញ្ញាត។ ភាគីគួរតែត្រូវបានរៀបចំនូវសំណួរតាមលំដាប់លេខរៀងពីលេខតូចមកលេខធំនៃអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ នេះជាមធ្យោបាយដើម្បីចៀសវាងភាពច្របូកច្របល់ ច្រំដែល សាចុះសាឡើង ពិបាកក្នុងការគ្រប់គ្រង ឬក៏នាំឲ្យមានការខាតបង់ពេលវេលានៅក្នុងការសួរដេញដោល។

[១០:៥២:៥៧]

អង្គជំនុំជម្រះសង្ឃឹមថាភាគីទាំងអស់ដែលចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលនេះនឹងយកចិត្តទុកដាក់ក្នុងការរៀបចំតាំងសំណួរឲ្យបានល្អ ហើយសំណួរដែលសក្តានុពល ហើយមានប្រសិទ្ធភាពនៅក្នុងការស្វែងរកការពិត។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

បាទ ជាការពិតណាស់មានចំណុចមួយដែលខ្ញុំចង់លើកឡើង។ ខ្ញុំមានការកត់សម្គាល់ថា សហព្រះរាជអាជ្ញាបាន-- ត្រូវការពេលវេលារហូតដល់ប្រាំថ្ងៃឯណោះ ដើម្បីសួរសាក្សីរូបនេះ។ ដូច្នេះ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាឲ្យផ្តោតឲ្យការយកចិត្តទុកដាក់ទៅលើអង្គហេតុដែលពាក់ព័ន្ធ។ ខ្ញុំឈប់ហៅថា *មីនីត្រាល* សវនាការខ្នាតតូចទៀតហើយ គឺនិយាយអំពីវគ្គនៃសវនាការនៅក្នុងវគ្គនេះ ហើយខ្ញុំមិនបានឮសួរសួរសំណួរណាដែលពាក់ព័ន្ធទៅនឹងសវនាការក្នុងដំណាក់កាលដំបូងនេះទេ។ ចំពោះសាក្សីដែលខ្ញុំ

ចង់សួរឈ្មោះនោះគឺសាក្សី ឌុច ដែល-- គឺ KW-30 ដែល ឌុច គាត់បានលើកឡើងនោះ គឺសាក្សីឈ្មោះ អ៊ុច ស៊ុន ប្រសិនណាជាខ្ញុំអានមិនច្រឡំទេ។ អ៊ុច ស៊ន បាទ សូមអត់ទោសម្តងទៀត។ គឺជាសាក្សីដែលបានផ្តល់សវនាការនៅថ្ងៃទី១៩ មេសា ២០០៩ គឺថាមិនមានហេតុអីចាំបាច់និយាយឲ្យចំឈ្មោះ ចំពោះសាក្សីរូបនេះទេ។

[១០:៥៤:៥០]

សាក្សីរូបនេះ មិននៅក្នុងបញ្ជីសាក្សីរបស់យើងខ្ញុំទេ។ ដូច្នេះយើងខ្ញុំសូមថា ចំពោះសាក្សីរូបនេះ គឺថាសូមកុំប្រើរហស្សនាមអី មិនចាំបាច់ហៅរហស្សនាមអី នាំតែមានការច្រឡំនោះទេ។ ហើយចំណុចមួយចុងក្រោយ គឺដែលខ្ញុំចង់លើកតាំងពីម្សិលមិញនោះ ដែលខ្ញុំ គេបានប្រាប់ខ្ញុំថាចំពោះអាកប្បកិរិយារបស់ខ្ញុំ គឺថាមានការពាក់ព័ន្ធទៅនឹងបញ្ហា ក្រមសីលធម៌ ក្រមវិជ្ជាជីវៈ ដែលថាអង្គជំនុំជម្រះនឹងអាចចាត់វិធានការចំពោះរូបខ្ញុំ។ ខ្ញុំគឺជាសមាជិកនៃគណៈមេធាវីកម្ពុជា ក៏ដូចជាសមាជិកនៃគណៈមេធាវីនៅអាំស្ទែដាមដែរ។ ដូច្នេះ សកម្មភាព វិធានការទាំងឡាយណា ដែលអង្គជំនុំជម្រះអាចចាត់វិធានការហ្នឹងមកលើរូបខ្ញុំ គឺថាត្រូវឲ្យស្របទៅនឹងក្រមវិជ្ជាជីវៈរបស់គណៈមេធាវីកម្ពុជា ក៏ដូចជាក្រមវិជ្ជាជីវៈនៃក្រុងអាំស្ទែដាមដែរ។ ដូច្នេះ ខ្ញុំនឹងអាចធ្វើយ៉ាងម៉េចឲ្យអាកប្បកិរិយារបស់ខ្ញុំហ្នឹងគឺថាវាមានលក្ខណៈសមស្រប ហើយក៏សុំ និងថាតើដាក់បណ្តឹងទៅណា-- និងត្រូវដាក់បណ្តឹងទៅណា? នោះប្រសិនជាអង្គជំនុំជម្រះត្រូវចាត់វិធានការដាក់បណ្តឹងប្រឆាំងមកលើរូបខ្ញុំ។

បើសិនណាជាអង្គជំនុំជម្រះអាចធ្វើទៅបាន ក៏ដាក់បណ្តឹងប្រឆាំងរូបខ្ញុំចុះ ដើម្បីបើពាក់ព័ន្ធទៅនឹងបញ្ហានៃក្រមសីលធម៌ ឬក្រមវិជ្ជាជីវៈនេះ។ ហើយយើងនឹងសុំស្នើសុំឲ្យមានអ្នកជំនាញលើកឡើងថាតើអត្តចរិតរបស់ខ្ញុំហ្នឹងវាពាក់ព័ន្ធទៅនឹងបញ្ហាបែបនេះដែរ ឬក៏អត់នោះ? សូមអរគុណ។

[១០:៥៦:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៧:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ នេះគឺជាចំណុចចុងក្រោយ នេះជាបញ្ហាសម្រាប់អង្គជំនុំជម្រះទេ។

ទាក់ទងទៅនឹងចំណុចទីមួយ ទាក់ទងទៅនឹងការចោទតាំងសំណួរដោយសហព្រះរាជអាជ្ញា គឺថាយើងបានកត់ត្រា ដែលថាការសាកសួរនេះ គឺថាត្រូវតែមានភាពជាក់លាក់ឲ្យបានច្បាស់លាស់ ដូចអង្គជំនុំជម្រះបានជ្រាបហើយ ការសួរនេះ មានរយៈតែប្រាំថ្ងៃទេ ដែលយើងបែងចែកទៅជាផ្នែកផ្សេងៗ។ នៅរយៈពេលបួនម៉ោងចុងក្រោយ គឺថាយើងខ្ញុំដឹងថាពាក់ព័ន្ធទៅនឹងសាក្សីនៃកម្ពុជាប្រជាធិបតេយ្យ ដែលមានរយៈពេលយូរមកហើយ ថាតើគោលនយោបាយមុនឆ្នាំ៧៥នោះ វាមានរឿងមួយដែលមានសារៈសំខាន់ណាស់ ពាក់ព័ន្ធទៅនឹងប្រវត្តិសាវតារ។ ទើបយើងសួរសំណួរនេះ ពីឆ្នាំ៧៥ៗមក គឺថាវាមានហើយ យើងចង់ដឹងពីមុនឆ្នាំ៧៥។ ដូច្នេះ ដូចអង្គជំនុំជម្រះបានជ្រាបថា សាក្សីរូបនេះ ជាសាក្សីមួយដែលមានការបានយល់ដឹងច្រើន ហើយយើងចាត់ទុកថាគាត់មានតួនាទីសំខាន់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាទាំងមុខឆ្នាំ៧៥ ក៏ដូចជានៅក្នុងសវនាការមុនៗ ហើយក្នុងពេលនេះ គាត់ជាសាក្សីក្នុងសវនាការនេះ។ ដូច្នេះ គឺយើងធ្វើការកត់ត្រាពាក់ព័ន្ធទៅនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា។

[១០:៥៩:២២]

ហើយផ្នែកទីពីរ ដែលព្រះរាជអាជ្ញានឹងធ្វើនោះ គឺទាក់ទងទៅនឹងមនោគមន៍វិជ្ជា ក៏ដូចជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកំណត់ឡើងនៅក្នុងកថាខណ្ឌ១៥៦ ទៅដល់១៥៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សាក្សីនេះ មានតួនាទីសំខាន់ដែលអាចលើកឡើងអំពីគោលនយោបាយទាំងនោះនៅក្នុងសវនាការនេះ។ គឺគោលនយោបាយពាក់ពន្ធទៅនឹងរបបនោះ ហើយគាត់ក៏មានធ្វើការបណ្ដុះបណ្ដាលនៅក្នុងអំឡុងពេលទាំងមូលនៃរបបនោះដែរ។ ដូច្នេះ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធជាក់លាក់តែម្ដងនោះ គឺរចនាសម្ព័ន្ធចន្លោះពី៧៥ ទៅ៧៩ បន្ទាប់មកបាននិយាយអំពីរចនាសម្ព័ន្ធទំនាក់ទំនង និងបន្ទាប់មកទៀតតួនាទីរបស់ជនជាប់ចោទទាំងអស់។

ដូច្នេះ យើងខ្ញុំមិនមានការយល់ស្របជាមួយមេធាវីការពារក្ដីថា ការសាកសួរបួនម៉ោងមកនេះកន្លងមកនេះ គឺថាមិនមានការពាក់ព័ន្ធនោះ គឺជនជាប់ចោទ-- អ៎! សាក្សីរូបនេះគាត់មានលទ្ធភាពលើកឡើងអំពីរចនាសម្ព័ន្ធ អំពីប្រវត្តិសាវតារ។ ដូច្នេះយើងខ្ញុំជឿជាក់ថា សាក្សីរូបនេះ ប្រាកដជាអាចនឹងផ្ដល់ចម្លើយទាក់ទងទៅនឹងគោលនយោបាយ។ ហើយជាពិសេសពាក់ព័ន្ធទៅនឹងការនិយាយទៅដល់សាក្សី KW-30 នេះ ដែលយើងមិនចង់លុបឈ្មោះ ប៉ុន្តែហាក់ដូច-- ប៉ុន្តែមេធាវីការពារក្ដីរកឃើញថា សាក្សីរូបនេះមានរហស្សនាមហើយ។ សូមអរគុណច្រើន។

[១១:០១:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ហើយចំពោះសាក្សី ទោះបីសួរ-- សាកសួររួចហើយក៏ដោយ ក៏អង្គជំនុំជម្រះកំណត់ថា គប្បីប្រើប្រាស់នូវរហស្សនាម ប្រសិនបើសាក្សីនោះមានរហស្សនាមហើយ ហើយកិច្ចការសម្រេចកំណត់ថា ឲ្យប្រើប្រាស់រហស្សនាមនោះ គឺជាភារកិច្ច ជាតួនាទីរបស់អង្គជំនុំជម្រះកំណត់ឲ្យកិច្ចដំណើរការសវនាការធ្វើដូច្នេះ។ ហើយក៏អរគុណផងដែរ ចំពោះមេធាវីដែលបានលើកឡើងអំពីស្ថាប័ននានាដែលពាក់ព័ន្ធនឹងបណ្ដឹងប្រឆាំងជាមួយនឹងលោកនោះ។ យើងមិនឲ្យលោកនិយាយអ្វីទៀតទេ។ សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើការបន្តសំណួរ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ដូចដែលសហការីខ្ញុំបានជម្រាបជូនលោក លោកស្រីចៅក្រមរួចហើយថា ខ្ញុំបានចប់ផ្នែកទីមួយនៃការសួរសំណួរនេះ ហើយឥឡូវនេះខ្ញុំនឹងចូលទៅផ្នែកបន្ទាប់ទៀតដែលទាក់ទងជាមួយនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធទៅនឹងគោលនយោបាយ ហើយនិងទាក់ទងទៅនឹងការអនុវត្តការជម្លៀសដោយបង្ខំ ដែលមានយោងនៅក្នុងកថាខណ្ឌ១៥៦ ដល់ ១៥៩ នៃដីកាដំណោះស្រាយ។

[១១:០២:៥៣]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកកាំង ហ្គេកអ៊ាវ លោកបានជម្រាបជូនអង្គសវនាការរួចហើយថា លោកបានយល់ដឹងអំពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា តាំងពីពេលដែលលោកនៅរៀន ហើយក្រោយមកទៀត លោកក៏បានរៀន និងបង្រៀនអំពីមនោគមន៍វិជ្ជានេះជាច្រើនឆ្នាំផងដែរ។ នៅពេលនោះតើលោកបានដឹងទេថា ឯកសារសំខាន់ៗរបស់បក្សអ្វីខ្លះ ដែលនិយាយអំពីគោលបំណង ហើយនិងមនោគមន៍របស់បក្សនុ៎ង តើលោកដឹងទេនៅពេលនុ៎ង មានឯកសារអីខ្លះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ឯកសារជាមូលដ្ឋានមានពីរ។ ទីមួយ មាក៌ាជាយុទ្ធសាស្ត្រនៃការបដិវត្តន៍នៅកម្ពុជា។ សូមបញ្ជាក់ថា ចំណងជើងនេះ ខ្ញុំអាចនិយាយមិនចំពេកទេ។ ក៏ប៉ុន្តែក្នុងនុ៎ង ខ្លឹមសារនិយាយអំពីសម្ភារនិយមប្រវត្តិសាស្ត្រ ដែលសង្គមមនុស្សត្រូវតែវិវត្តន៍ពីសង្គមសម្ញហាភាពបុព្វកាល មកជាសង្គមទាសភាព។ វិវត្តន៍ពីសង្គមទាសភាព ទៅជាសង្គមសក្តិភូមិ។ វិវត្តន៍ពីសង្គមសក្តិភូមិ ទៅជាសង្គមមូលធននិយម

នាយទុននិយម ហើយបានវិវត្តន៍ទៅជាសង្គមសង្គមនិយម ចុងបំផុតវាទៅជាសង្គមកុម្មុយនីស្តនិយម។

តាមទ្រឹស្តីបដិច្ចសមុប្បាទសម្ភារនិយម-- អ៊ំនែ៎! ប្រវត្តិសាស្ត្រ ចលនាវិវត្តន៍នេះវាទៅដោយការតស៊ូវណ្ណៈ។ ដូច្នេះការធ្វើបដិវត្តន៍ វាគ្រាន់តែសម្រួលឲ្យការឆ្លងកាត់ពីសង្គមមួយទៅសង្គមមួយ នេះមានន័យប៉ុណ្ណឹង។ ហើយក្នុងឯកសារមាគ៌ាជាយុទ្ធសាស្ត្រនេះ បញ្ជាក់ថាបក្សកុម្មុយនីស្តកម្ពុជាអង្គាល់នឹងហៅថា“បក្សពលករ”នៅឡើយទេ។ បក្សពលករខ្មែរ បក្សយើង និងតស៊ូចប់ចុងចប់ដើម។ ការតស៊ូចប់ចុងចប់ដើមហ្នឹងមិនប៉ានប្រើពាក្យថា “សេរីនិយម”ទេ គឺទប់ទល់គេចមិនព្រមឲ្យត្រឡប់ទៅជាសេរីនិយមហ្នឹងបាន គឺមានន័យអ៊ីចឹង។ នេះមាគ៌ាជាយុទ្ធសាស្ត្រ។

ឯកសារទីពីរ មានចំណងជើងប្រហាក់ប្រហែលថា “មាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្សធំទូលាយវាយឈ្នះខ្មាំងក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ”។ គោលជំហរមួយជាមូលដ្ឋានគឺត្រូវបែងចែកខ្មាំងជាបីប្រភេទ។ មួយប្រភេទ អូសទាញមកធ្វើជាកម្លាំងយើង។ ហ្នឹងប្រភេទដែលល្អ។ ប្រភេទទីពីរ នៅប៉េលប៉ាល។ ដូច្នេះយើងត្រូវតែអព្យាក្រឹតកម្លាំងហ្នឹង កុំឲ្យបំផ្លាញយើងបាន។

[១១:០៦:៥៩]

ប្រភេទទីបី ឯកោខ្មាំងដែលឃោរឃៅ ហើយវាយកម្ទេច។ នេះគឺជាទ្រឹស្តីដែលមានចែងនៅក្នុងនុំង ក៏ប៉ុន្តែនៅក្នុងការអនុវត្ត ខ្ញុំរកយល់ការអនុវត្តមិនទាន់ឃើញ។ នេះជាមូលដ្ឋានមួយ។ មូលដ្ឋានទីពីរគឺនៅក្នុងឆ្នាំ១៩៧១ បក្សអប់រំឲ្យបែងចែកឲ្យច្បាស់លាស់ព្រំដែនវណ្ណៈរវាងខ្មាំងនិងយើង។ ប្រៀបធៀបនេះ គឺប្រៀបធៀបនឹងសមរភូមិនៅភាគខាងត្បូងវៀតណាម ភាគខាងត្បូងវៀតណាមគេឲ្យកម្លាំងតស៊ូហើយនិងកម្លាំងខ្មាំងនៅប្រទាក់ប្រទងគ្នាជាប់។ ឯចំណែកយើង ខ្មាំងដោយខ្មាំង យើងដោយយើង។ យើងនៅខាងដីរំដោះ ខ្មាំងនៅក្នុងដី លន់ នល់។ នេះម្យ៉ាង។ ម្យ៉ាងទៀត ស្អីដែលជាខ្មាំងយើងកុំធ្វើពុករលួយស្អីៗយើងកុំធ្វើ ហ្នឹងគឺបែងចែកអ៊ីចឹង។ នេះវាលេចចេញបញ្ហាហ្នឹងមួយទៀត។ គោលជំហរហ្នឹងហើយដែលខ្ញុំតែងតែសរសេរ គឺបក្សយកចិត្តទុកដាក់ណាស់បញ្ហានេះ។

[១១:០៨:២៣]

ខ្ញុំសូមលើកឧទាហរណ៍មួយជាក់ស្តែងទៅទៀតចុះ។ ក្នុងបញ្ហាជ្រើសរើសគូស្រករគេមិនហាមដាច់ខាតថា អ្ហែ! មិត្តឯកកុំទៅយកជនជម្លៀស គេមិនហាមអ៊ីចឹងទេ។ គេលើកបញ្ហានេះយូរហើយគេថាមួយនឹងមួយត្រូវបូកឲ្យឃើញទៅជាពីរ កុំឲ្យមួយនិងមួយបូកទៅសូន្យ។ ដូច្នេះ ការជ្រើសរើសគូស្រករប្តីប្រពន្ធត្រូវគិត។ គេអប់រំអ៊ីចឹងទៅវិញទេ។ ដូច្នេះ យើងឯណាទៅប៉ានជ្រើសរើសកូនក្រមុំ

អ្នកជម្លៀស ទោះបីស្អាតយ៉ាងណាក៏ដោយ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំពេញចិត្តដែរ ប្រពន្ធខ្ញុំគាត់ខ្មៅ ក៏ប៉ុន្តែគាត់ជាកសិករក្រ ហើយនៅមូលដ្ឋានបង្អែកបដិវត្តន៍ទៀត ហើយជាបក្ខជនទៀត។ ខ្ញុំជ្រើសរើសអ៊ីចឹង ដូច្នេះនេះហើយដែលហៅថាការបែងចែកច្បាស់លាស់រវាងខ្មាំងនិងយើង ហ្នឹងជាគោលនយោបាយនៅពេលដែលគេបង្រៀនយើង អំពីការបែងចែកច្បាស់លាស់រវាងខ្មាំងនិងយើង នេះជាមនោគមន៍វិជ្ជាច្បាស់ហើយ។ ហើយខ្ញុំនិយាយតទៅទៀតអំពីសីលធម៌១២ប្រការ។

[១១:០៨:៣៧]

សីលធម៌១២ ប្រការនេះ ផ្សព្វផ្សាយនៅក្នុងឆ្នាំ១៩៦៨។ សរុបមកគោលជំហរពីរដែលត្រូវមើលឲ្យឃើញសីលធម៌ប្រការទីមួយ គេនិយាយត្រូវគោរពស្រលាញ់ និងបម្រើប្រជាជនជានិច្ច។ នេះភាសាដែលមានចែង ខ្ញុំទន្ទេញចាំ។ ដល់សីលធម៌ប្រការទីពីរ គេថា "នៅទីណា ត្រូវបម្រើប្រជាជនកម្មករកសិករនៅទីនោះឲ្យអស់ពីចិត្តពីថ្លើម"។ ដូច្នេះ ប្រជាជនដែលគេប្រើ គេបម្រើហ្នឹងអ្នកណា? គេបម្រើតែកម្មករ កសិករទេ។ គេឲ្យតម្លៃតែកម្មករ និងកសិករទេ។ នេះខ្លឹមសារទីមួយនៃសីលធម៌បដិវត្តន៍។ ខ្លឹមសារទីពីរនៃសីលធម៌បដិវត្តន៍ មិនដឹងជាសីលធម៌ប្រការទីប៉ុន្មានទេ ខ្ញុំវង្វេងអស់ហើយ។ គេសរសេរថា "ត្រូវរាបសាជានិច្ចចំពោះប្រជាជន តែត្រូវចងកំហឹងឆាបឆេះជានិច្ចចំពោះខ្មាំង"។ ចងកំហឹងយ៉ាងម៉េច? ឧទាហរណ៍ គេចាប់ សោ ភឹម។ កុំណា! បក្សសម្រេចថាខ្មាំងហើយ ចងកំហឹងនឹងគេទៅ បក្សអត់ដែលខុសទេ។ អាហ្នឹងវាមានន័យអ៊ីចឹងៗ។ ដូច្នេះសីលធម៌១២ប្រការ សរុបមកវាមាននៅតែនុ៎ង។ នេះជាគោលជំហរគ្រឹះរបស់បក្សកុម្មុយនីស្តកម្ពុជាមួយហើយ។ បម្រើតែប្រជាជន កម្មករ កសិករ ចងកំហឹងឆាបឆេះជានិច្ចចំពោះខ្មាំង។ ដូច្នេះហើយ បានៗនេះ ជាគោលជំហរដែលគេបង្រៀន យើងត្រូវតែយល់ដើម្បីឲ្យស្គាល់ឲ្យថាបក្សកុម្មុយនីស្តកម្ពុជា គឺអ្វីត្រូវមើលអាហ្នឹង។

ខ្ញុំសូមឆ្លើយប៉ុណ្ណេចុះ នឹកឃើញប៉ុណ្ណឹងពេលនេះ។

**ស៖** បាទ អរគុណ។ តើលោកដឹងទេថា ទិដ្ឋភាពរបស់សង្គមកម្ពុជាបែបណាខ្លះដែលបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានបំណងចង់ផ្លាស់ប្តូរ តាម-- ដើម្បីឲ្យទទួលបាននូវមនោគមន៍វិជ្ជារបស់បក្សហ្នឹង?

[១១:១២:០១]

**ឆ៖** ការអប់រំ ការពន្យល់ គេទៅសន្សឹមៗ ចូនអីគេប្រើពាក្យអីមួយស្រាល។ ដូចកម្មាភិបាលខ្លះធ្លាប់និយាយថា អ្ហឺ!យើងចែកគ្នារស់ យើងក្រ យើងចែកគ្នារស់។ តាមពិតរបបអង្គរគេកំណត់ ក្នុងកងទ័ព កម្លាំងពិសេសពីរកំប៉ុងកន្លះ ពិសេសហើយ កំពុងសម្រុកការងារ។ ដល់កម្លាំងលេខមួយ ពីរកំប៉ុង

មាននៅក្នុងឯកសារស្រាប់រួចហើយ។ ហើយកម្លាំងក្នុងកសិករ ក្នុងប្រជាជន កម្លាំងពិសេសកំពុងរើសម្រុកពីរកំប៉ុង។ កម្លាំងលេខមួយ មួយកំប៉ុងកន្លះ។ ហើយដល់ពាក្យគេនិយាយ គេនិយាយថា អ្ហ៎!យើងចែកគ្នារស់ទៅ ធ្វើម៉េចយើងទើបតែចេញពីសង្គ្រាម។ ហ្នឹងគេនិយាយយ៉ាងអ៊ីចឹង។ ដល់ម្ដោះហើយយើងចេញតែទៅតាមគេ ប្រឆាំងម៉េចបាន។

[១១:១៣:០៤]

**ស៖** បាទ សូមអរគុណ។ តើលោកដឹងពីគោលគំនិតរបស់បក្សកុម្មុយនីស្ដកម្ពុជា ទាក់ទងទៅនឹងអាបញ្ហាសេដ្ឋកិច្ច ឬក៏ពាណិជ្ជកម្ម តើបក្សកុម្មុយនីស្ដកម្ពុជាចង់បានយ៉ាងម៉េចដែរ?

**ឆ៖** មិនដឹងទេ ទាល់តែក្រោយមក យើង-- បានខ្ញុំសរុបបាន។ ពីអង្កាល់ដែលគេធ្វើ គឺអត់ដឹង។ ឆ្នាំ៧៥ គេបោះពុម្ពលុយ។ យើងគិតថា តើបក្សរៀបចំយ៉ាងម៉េច? មួយរៀលតម្លៃស្មើនឹងប៉ុន្មាន។ យើងជាបញ្ញាជន យើងចេះតែគិតហើយ។ ខាងអធន យើងចេះតែគិតហើយ។ មួយរៀលបែបជាគិតនឹងរបបហូបចុក ជីវភាពប្រជាជនកម្ពុជាមួយថ្ងៃ។ ចុះឡើង១ វាគ្រាន់តែ-- លុយហ្នឹង គឺគ្រាន់តែជារបសឧបកិច្ចដល់ចុងបញ្ចប់ គេមកអនុវត្តការបែងចែកផលទៅតាមសេចក្ដីការចាំបាច់។ សេចក្ដីត្រូវការចាំបាច់ស្អី? មួយថ្ងៃអង្ករពីរកំប៉ុងសម្រាប់កម្លាំងស្រួច គ្មានសេវាសុខាភិបាល គ្មានសិក្សាធិការទេ។ អាហ្នឹងការចាំបាច់។ គេអត់និយាយ គេនិយាយថា ប៉ា!យើងទើបតែចេញពីសង្គ្រាម ចែកគ្នារស់។

ដូច្នេះ របបសេដ្ឋកិច្ច យើងសរុបបានក្រោយមកទេ គេធ្វើរួចទៅហើយទេ។

[១១:១៤:៣៣]

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងបញ្ហាគ្រួសារ តើបក្សកុម្មុយនីស្ដកម្ពុជាហ្នឹងមានគោលបំណងយ៉ាងណាចង់ឲ្យសង្គមគ្រួសារហ្នឹងមានតួនាទីអ្វីខ្លះដែរក្នុងពេលនុំង?

**ឆ៖** គ្រួសារយ៉ាងម៉េច? ជាឪពុកកូន ឬក៏ប្ដីប្រពន្ធ?

**ស៖** ទាំងអស់។

**ឆ៖** ប្ដីប្រពន្ធ ដូចខ្ញុំបានជម្រាបសហព្រះរាជអាជ្ញារួចមកហើយ គឺគេចង់ឲ្យមួយបូកមួយពីរ មិនឲ្យបូកមួយ១ទៅសូន្យ នេះប្ដីប្រពន្ធ។ ឯចំណែកកូន ចៅ ខ្ញុំមិនបានជាគិតទេ ប៉ុន្តែចេះតែឆ្ងល់ អ្នកខ្លះថ្នាក់ធំ១ដែរ ឲ្យកូនហៅឪពុកម្ដាយ អ៊ំ ឬក៏មីង ពូ ថ្នាក់អចិន្ត្រៃយ៍មជ្ឈិមបក្សហើយណ៎ា។ ខ្ញុំចេះតែឆ្ងល់នេះម្យ៉ាង។ ម្យ៉ាងទៀត មុនឆ្នាំ១៩៧៥ គុណមាតាបិតា គេមិនសូវនាំអាទិ៍និយាយទេ មិននាំអាទិ៍អី មិនដែលអ្នកណានឹកនាឲ្យនិយាយផង តែម្ដាយមិនឲ្យនិយាយផង។ ដល់ក្រោយឆ្នាំ១៩៧៥ លេចចេញ

ចម្រៀងមួយ ផ្សាយតាមវិទ្យុ ចម្រៀងនេះនៅ ប្រហែលជាមានអ្នកថតទុកជាឯកសារបាន។ ម៉ែឪរំដោះមនុស្ស-- អំនែ បង្កើតមនុស្សបានតែម្នាក់ទេ អង្គការបដិវត្តន៍រំដោះមនុស្សបានមួយនគរ។ ដូច្នេះ ម៉ែឪអត់មានតួនាទីទេ អង្គការជាម៉ែឪ។ ហ្នឹងក្រុមគ្រួសារគេចែករបៀបហ្នឹង។

[១១:១៦:២៣]

**ស៖** បាទៗ សូមអរគុណ។ ចុះទាក់ទងទៅនឹងជីវិតរបស់-- នៅទីប្រជុំជនវិញ តើបក្សកុម្មុយនីស្តកម្ពុជាមានបំណងចង់កែប្រែទៅជាយ៉ាងណាដែរ?

**ឆ៖** ខ្ញុំមិនដឹងទេៗ ឃើញតែចូលមកភ្នំពេញមក អស់រលីង អស់មនុស្សពីភ្នំពេញ។ ប្រមូលទៅស្រែ។ សរុបមកខ្ញុំអាចវិភាគ ហើយឆ្លើយបានថា គេប្រមូលកម្លាំងទាំងអស់ដែលមិនជាប់ស្រែឱ្យទៅជាប់ស្រែ។ តាមគំរូនៃកងផលិតធំ តាថាយ។ អ្នកណាធ្វើស្បូត្រក៏គេប្រមូលយកទៅស្រែ គ្រូបង្រៀនក៏គេប្រមូលយកទៅស្រែ ពេទ្យក៏គេប្រមូលយកទៅស្រែ ធ្វើស្រែទាំងអស់គ្នា។ ដូច្នេះជម្លៀសប្រជាជនពីក្រុងភ្នំពេញ ទីមួយ ពេលជម្លៀសហ្នឹងមានចលនាសម្រិតសម្រាំងហើយ អ្នកសល់ពីសម្រិតសម្រាំងយកទៅធ្វើស្រែ។

[១១:១៧:៤១]

**ស៖** បាទ អំមិញទាក់ទងទៅនឹងការកែប្រែជីវិតនៅទីប្រជុំជន។ ចុះទាក់ទងនឹងជីវិតដែលនៅជនបទវិញ តើយ៉ាងម៉េចដែរ?

**ឆ៖** និយាយអំពីជីវិតនៅជនបទ ទីមួយនិយាយពីជីវភាពសេដ្ឋកិច្ច។ សហករណ៍នេះ គេចាត់ជាពិសោធនៅឆ្នាំ១៩៧២ នៅព្រះវិហារ ខេត្តព្រះវិហារ។ ដល់ឆ្នាំ១៩៧៣ គេចាត់តាំងទូទៅសហករណ៍កម្រិតខ្ពស់នៅតំបន់រំដោះ។ ហើយអាហ្នឹងគេមិនផ្សព្វផ្សាយ អាហ្នឹងមូលដ្ឋានគ្រឹះនៃកុម្មុយនីស្តនិយមសង្គមនិយមអីទេ គេថា យើងពេលក្នុងសង្គ្រាមចែកគ្នារស់ រួមដៃគ្នាតស៊ូទៅ។

[១១:១៨:៣៩]

ហើយដល់ក្រោយ១៧ មេសា ខ្ញុំជឿថាមានឯកសារមួយ ថ្ងៃ២០ ឧសភា ប៉ុន្តែឯកសារនេះខ្ញុំអត់ដែលបានឃើញ។ ថ្ងៃឧសភា ១៩៧៥-- ថ្ងៃ២០ ឧសភា ១៩៧៥ គេពង្វាតវិសាលសហករណ៍កម្រិតខ្ពស់ហ្នឹង ពីតំបន់រំដោះឱ្យទូទៅប្រទេស។ នេះខាង ខាងនៃសេដ្ឋកិច្ចជីវភាព។ ឯចំណែក កម្មករដែលជម្លៀសទៅពីភ្នំពេញ គេដឹកយកមករោងចក្រ។ ហ្នឹងម្យ៉ាង។ ក៏ប៉ុន្តែខាងសិក្សាធិការរំសាយចោលសាសនាគេផ្សឹកលោកសង្ឃអស់។ ខ្ញុំជឿថា តាមការស្រាវជ្រាវតាមដានរបស់ខ្ញុំហូរហែមកមានរាប់

សិបឆ្នាំហើយ គណៈដឹកនាំសង្ឃ តាំងពីមេគុណខេត្ត រហូតដល់សង្ឃរាជ ត្រូវគេកម្ទេចបាត់អស់ទៅហើយ។ ហ្នឹងខាងសាសនាគេលុបបំបាត់។ មូស្លីម ខាងចាម អ៊ីស្លាម យើងយកឯកសារថ្ងៃ៣០ វិច្ឆិកា ១៩៧៥ ដែល សោ ភឹម គាត់រាយការណ៍មក ប៉ុល ពត, នួន ជា ពីរឿងជម្លៀសចាមទៅជនបទ ហើយ កែ ពក មិនព្រមទទួល។ ក្នុងនុ៎ងជម្លៀសប្រជាជនទាំងខ្មែរទាំងចាមពីដងទន្លេ និងពីតាមបណ្ដោយព្រំដែនយកទៅឧត្តរ និងពាយ័ព្យ។ ខ្ញុំមិននិយាយពីខ្មែរទេ ខ្ញុំនិយាយពីអ៊ីស្លាម មូស្លីម យកមូស្លីមទៅពង្រាយក្នុងសហករណ៍ ដើម្បីអី? ដើម្បីឲ្យសហគមន៍ចាមហ្នឹងវាពង្រាយនៅក្នុងសហករណ៍ហ្នឹង បំបាត់ភាសា បំបាត់សាសនា បំបាត់អីឲ្យរលាយទៅជាខ្មែរ។ នេះចំពោះបញ្ហាសាសនា។ ឯៗចំណែកវត្តអារាមរបស់យើងគេរើចោល យកដែកធ្វើវិហារហ្នឹង។ ដូច្នេះ នៅជនបទគឺអ៊ីចឹង។

សរុបមក គ្មានសាសនា ទាំងអស់គ្នារស់នៅក្នុងសហករណ៍ វាយសម្រុកទាំងពោះគ្រហែត។ មធ្យោបាយផលិតកម្មទាំងអស់ទៅជារបស់បក្ស។ របបហូបចុកមួយថ្ងៃពីរកំប៉ុងអង្ករ កម្លាំងស្រួចកម្លាំងលេខមួយមួយកំប៉ុងកន្លះ នេះប្រជាជន។ គ្មានសាសនា គ្មានជំនឿ គ្មានគុណម៉ែគុណឪទេ អង្គការអ្នកមានគុណ។ នេះ ខ្ញុំសូមសរុបប៉ុណ្ណឹង។ នេះជាការសរុបបណ្ដើរៗរហូតមកដល់ថ្ងៃនេះទេ ខ្ញុំសរុបឃើញអ៊ីចឹង។

**ស៖** បាទ តើលោកដឹងទេថា--

[១១:២១:៣៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរលោក លោកស្រីទាំងអស់។ សូមអធ្យាស្រ័យដែលខ្ញុំធ្វើការរំខាន សាក្សីបាននិយាយថា តាមការស្រាវជ្រាវរបស់គាត់នោះគឺថា គាត់ទើបតែ ឆ្លើយមកថា គាត់នេះ គាត់បានសិក្សា។ តើចម្លើយដែលយើងទទួលបានពីការសិក្សាស្រាវជ្រាវពីគាត់ ហើយឬមេធាវី ឬក៏គាត់បានរៀបចំសម្រាប់សវនាការដែលបាន-- របស់គាត់-- ឯកសារដែលគាត់បានអានមុននឹងគាត់មកចូលកាន់សាសនាគ្រិស្តនេះ ឬក៏ក្រោយមកនោះ ថាតើបានមកដោយការចងចាំដោយឯករាជ្យ ឬក៏យ៉ាងម៉េច? ដោយសារថាគាត់ថាគាត់បានអាន ហើយឥឡូវនេះគាត់ផ្ដល់សក្ខីកម្មដោយគាត់និយាយអំពីចំណេះដឹងដែលគាត់បានដឹងនៅពេលនោះ។ តែខ្ញុំគិតឃើញថា ចំណេះដឹងនេះ

ទើបដឹងនៅពេលក្រោយនោះទេ។ ដូច្នេះដើម្បីជាការកត់ត្រាក្នុងប្រតិចារឹកនោះ ថាតើគាត់-- ចម្លើយនេះគាត់ដឹងនៅពេលនោះ ឬក៏ចម្លើយដែលគាត់ទើបនឹងរៀនសូត្រក្រោយៗ ហើយយកមកផ្សំផ្គុំគ្នាឆ្លើយក្នុងពេលនេះ។

ដូច្នេះ ខ្ញុំទាមទារថា តើការសិក្សាស្រាវជ្រាវអ្វីខ្លះ គាត់បានធ្វើ? ពីព្រោះចម្លើយកាលពីម្សិលមិញ និងថ្ងៃនេះ ហើយប្រហែលជាថ្ងៃក្រោយទៀត គឺមិនមែនយោងទៅលើការចងចាំដោយឯករាជ្យរបស់គាត់នោះទេ។ ប្រហែលជាការសិក្សាស្រាវជ្រាវរបស់គាត់អំពីដំណើររឿងនេះ ហើយគាត់ទើបគាត់យកមកផ្គុំគ្នាឆ្លើយ។ សូមអរគុណ។

[១១:២៣:១៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ចំណុចទាក់ទងទៅនឹងការតាំងសំណួរទៅលើសាក្សី គឺសាក្សីរូបនេះឆ្លើយថា គាត់បានរៀនសូត្រអំពីអង្គហេតុទាំងនេះ ពីការសិក្សាស្រាវជ្រាវរបស់គាត់ យើងទើបនឹងឮនៅថ្ងៃនេះ។ ហើយជាក់ស្តែងណាស់ គឺសហការីរបស់ខ្ញុំ គឺគាត់សួរទៅលើអង្គហេតុទាំងអស់នេះ ដើម្បីចង់ដឹង ថាតើអង្គហេតុអ្វីខ្លះ គាត់បានដឹងអំពីការកត់សម្គាល់របស់គាត់ និងការសិក្សារៀនសូត្ររបស់គាត់។ ហើយជាការពិតណាស់ អង្គជំនុំជម្រះគឺថាតួនាទីរបស់គាត់ គឺបណ្តុះបណ្តាលគោលនយោបាយ ហើយគាត់សិក្សារៀនសូត្រអំពីឯកសារកម្ពុជាប្រជាធិបតេយ្យមុនឆ្នាំ១៩៧០ ឯណោះ។ ដូច្នេះ ចំណេះដឹងនេះមានសារៈសំខាន់ណាស់ ដែលថាសាក្សីរូបនេះគាត់អាចនិយាយជាមួយនឹងអាជ្ញាធរមួយចំនួនអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១១:២៤:៣០]

គាត់បានលើកឡើងច្បាស់ហើយថា គាត់បានរៀនគោលនយោបាយទាំងអស់នេះតាមរយៈការរៀនសូត្ររបស់គាត់ និងតាមរយៈតួនាទីរបស់គាត់នៅម-១៣ និងនៅស-២១។ ហើយក៏ច្បាស់ផងដែរថា គាត់រៀនសូត្រគោលនយោបាយនេះតាមរយៈការចូលរួមរៀនសូត្រដោយផ្ទាល់។ ហើយដូចដែលមេធាវីការពារក្តីលើកឡើងថា ប្រហែលជាគាត់អាចដឹងអំពីឯកសារផ្សេងទៀត ប្រហែលជាដឹងតាមរយៈសវនាការរបស់គាត់ផ្ទាល់០០១ នោះ ឬក៏សិក្សារៀនសូត្រពីឯកសារដទៃទៀត។ នេះតួនាទីរបស់ភាគី

ដែលត្រូវសួរ ដើម្បីចង់ដឹងថាតើគាត់ដឹងពីបទពិសោធន៍របស់គាត់បានប៉ុន្មាន ហើយគាត់បានរៀនសូត្រពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយផ្ទាល់បានប៉ុនណា? និងគាត់បានដឹងរយៈពេលក្រោយប៉ុនណា? ដូច្នេះ ភាគីអាចសួរសំណួរទាំងអស់នេះបាន។ ហើយបើថាសាក្សីគាត់ឆ្លើយមិនបានពេញលេញនោះទេ មេធាវីការពារក្តីក៏អាចតាំងសំណួរមកសាក្សីរូបនេះបានដែរ។ ហេតុដូច្នេះឯងបានជាគាត់ថា គឺគាត់គឺជាសាក្សីមួយដែលអាចនឹងនិយាយបានច្រើន រៀបរាប់អំពីអង្គហេតុនេះបានច្រើនតាមរយៈចំណេះដឹងរបស់គាត់នេះ។

ដូចហើយអ្នកដទៃទៀតក៏ធ្វើការកត់សម្គាល់ទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដូចជាការរៀនសូត្រអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ការជំទាស់នេះ គឺគាត់អាចនឹងជំទាស់បាន ហើយគាត់អាចនឹងសាកសួរដើម្បីស្វែងរកពិតបាន។ សូមអរគុណច្រើន។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៦:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សំណួរបន្តទៅទៀតទាក់ទងនឹងអ្វីដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះ តើលោកដឹងបញ្ហាទាំងអស់នេះដោយរបៀបណាដែរ? លោកអាចជម្រាបជូនបានទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំសូមសង្ខេបបញ្ហានេះ។ បញ្ហាខ្លះវាជាសភាពការណ៍ពិត ដែលកើតមានជំនាន់នុ៎ង តែយើងពន្យល់មិនទាន់កើត ព្រោះយើងរស់នៅក្នុងផ្នែកមួយការយល់ដឹងរបស់យើងទាប។ ឧទាហរណ៍៖ របបអង្គរពីរកំប៉ុង។ សភាពការណ៍នេះវាពិត ទូទាំងប្រទេសដឹងឮរឿងហ្នឹង ក៏ប៉ុន្តែការយល់ដឹងយើងវានៅនឹងត្រឹមស-២១ ទេ។ គិតតែរឿងឯណោះ។ ហើយដល់មក ក្រោយមកយើងសរុបមើលទៅឃើញហើយ។ ដូច្នេះសក្ខីកម្មនេះវាឈរលើមូលដ្ឋានពិត អើប៉ុន្តែការយល់ដឹងវាវិវត្តន៍។ បើយើងនិយាយតែពីពេលហ្នឹង យកការយល់ដឹងពេលហ្នឹងមកនិយាយ។ ខ្ញុំគិតថា ដូចជាគ្មានស្អីនឹងឆ្លើយជូនជាតិប្រជាជនថា

ពេលនុ៎ង ជាតិប្រជាជនកម្ពុជា វាវេទនាយ៉ាងណា ដោយសារបក្សកុម្មុយនីស្តកម្ពុជាទេ។ ដូច្នេះ សភាពការណ៍ទីនោះវាពិតអ៊ីចឹង។

[១១:២៨:១៩]

សភាពការណ៍ទីពីរ កម្មេចថ្នាក់ដឹងនាំសង្ឃ តាំងពីមេគុណខេត្តរហូតទៅដល់សង្ឃរាជ។ យើងនៅអមលាំងឯណោះទេ ប៉ុនគេកម្មេចឯភ្នំពេញ យើងម៉េចទៅដឹង? ដល់ក្រោយមកយើងឮដំណឹងមួយដល់ក្រោយមកទៀត យើងចេះតែតាមដានទៅទៀត បានយើងសរុបបាន។ សរុបបានដោយសារការិយាល័យសហាថៅក្រមស៊ើបអង្កេតចុះទៅខាងតាកែវ។ ទៅយកមនុស្សដែលគេចាប់ផ្សឹកមក ហើយនុ៎ងមានថៅអធិការមួយអង្គបាត់ខ្លួន ខ្ញុំគិតវិភាគសព្វគ្រប់ អ៎! លោកសង្ឃគេចាប់ផ្សឹកអស់ហើយ វិហារគេកម្មេចចោលអស់ហើយ។ ហ្នឹងគឺយើងដឹងបន្តិចៗព្រោះការយល់ដឹងរបស់យើង វង់ប្រតិបត្តិការរបស់យើងវាតូចចង្អៀត។ ហើយយើងយកសភាពការណ៍ពិតដែលយើងប្រមូលបានដើម្បីសរុប។

ដូច្នេះសេចក្តីសន្និដ្ឋានទាំងអស់នេះ វាឈរទៅលើសភាពការណ៍ពិត ដើម្បីមានមតិ។ មតិធ្វើម៉េចដើម្បីស្អី? ដើម្បីរកសេចក្តីពិតអំពីទុកវេទនារបស់ប្រជាជនកម្ពុជា។ ខ្លួនយើងខុសទៅហើយ យើងរកអាស្អីដែលខុសទៅលើប្រជាជនយើង ដើម្បីសុំទោសប្រជាជនយើង។

នេះខ្ញុំសូមបញ្ជាក់អំពីបញ្ហាដែលខ្ញុំវិភាគ។ យកព្រឹត្តិការណ៍ពិតមកវិភាគៗហើយសន្និដ្ឋានក្នុងគោលបំណងមួយមួយច្បាស់លាស់។ ស្វែងរកមូលហេតុដែលប្រជាជនកម្ពុជារងទុក្ខ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ បាទ ជាថ្មីម្តងទៀត សូមអធ្យាស្រ័យដែលខ្ញុំរំខាន។ គឺ យោងតាមចម្លើយរបស់គាត់នេះ គឺខ្ញុំសូមត្រឡប់ទៅវិញ គឺថាសហព្រះរាជអាជ្ញាគាត់និយាយថា តើសាក្សីនេះសំខាន់ប៉ុនណានេះ? អាចសំខាន់ អាចមិនសំខាន់ក៏ថាបាន។ គាត់និយាយអំពីការ ចំណេះដឹងដោយផ្ទាល់ខ្លួន សាក្សីរូបនេះបានលើកឡើង និងបានទទួលសារភាពថា គាត់វែកញែកអ្វីដែលគាត់បានដឹងនាពេលនោះ និងអ្វីដែលគាត់បានរៀនសូត្រ និងដឹងនៅពេលក្រោយ។ ឧបមាថា គាត់មិនមែនជាសាក្សីដាក់បន្ទុកនោះទេ គាត់ជាសាក្សីរបស់អង្គជំនុំជម្រះតែម្តង។ ដូច្នេះ ថាតើគាត់ត្រូវនិយាយថាគាត់បានដឹងអ្វីពិតប្រាកដនៅពេលនោះ និយាយតែអ្វីដែលគាត់បានដឹងពិតប្រាកដនៅពេលនោះ។

ដូច្នេះដើម្បី បើសិននៅពេលថា អាចនឹងយកសម្ដីរបស់សាក្សីនេះថាជាសាក្សីជំនាញ គឺ-- ប៉ុន្តែ ដោយសារគាត់ដឹងនូវពេលក្រោយ នៅពេលគាត់យកព័ត៌មានពីសៀវភៅ ប៉ែន យៀវនិន របស់ ឆេនដ័ល័រ ឬ ក្រេក អេតឆេសាន់ គឺថាខ្ញុំសូមជំទាស់។ ដូច្នេះ ខ្ញុំសូមសំណូមពរដល់លោកប្រធាន និង អង្គជំនុំជម្រះថា មូលដ្ឋានគ្រឹះច្បាស់លាស់មែននោះ គឺគាត់បានដឹងអ្វីពីមូលដ្ឋានគ្រឹះពីមុនមកនោះ។ ហើយជំហានបន្ទាប់ បានយើងសួរគាត់ ថាតើគាត់បានអានអ្វី? ហើយបន្ទាប់ពី ៧៩ គាត់បានអានអ្វីខ្លះ? គាត់បានទទួលព័ត៌មានអ្វីខ្លះ? ហើយគាត់បានរៀនពីមេធាវីរបស់គាត់អ្វីខ្លះដែរ? នោះព័ត៌មានទាំងអស់ នេះ ទើបយើងយកទៅដាក់បញ្ចូលជាមួយគ្នា។ មិនមែនជាដំណើររឿងដែលគាត់រៀបរាប់អំពីការចងចាំ របស់គាត់នោះគឺថា គាត់ចាត់ទុកថា ដូចជាអ្នកនិពន្ធ ឬក៏អ្នកសិក្សាស្រាវជ្រាវ ឬក៏យោងទៅលើឯកសារ ៥០ទំព័រ ដែលគាត់បានដាក់មកនោះទេ។

[១១:៣២:១៧]

ទីមួយ គាត់ត្រូវតែលើកនូវអ្វីដែលគាត់បានដឹងជាមូលដ្ឋានពីមុន និងអ្វីដែលគាត់បានដឹងនៅពេល ក្រោយ។ មិនមែនបញ្ជាក់ថា ហាក់បីដូចជាគាត់ថា គាត់ដឹងព័ត៌មានអ្វីទាំងអស់នោះទេ។ បើថាគាត់បាន ដឹងដោយសារពាក្យចចាមអារ៉ាម ឬក៏អ្វីៗនោះ គឺមិនមែនយ៉ាងដូច្នេះទេ។ អ៊ីចឹង យើងចង់ដឹងតែអ្វីដែល គាត់បានដឹងនាពេលនោះ អ្វីដែលគាត់ពិតជាបានដឹង បានឃើញ បានឮ និងបានធ្វើដោយផ្ទាល់ខ្លួននៅ ពេលនោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

បានខ្ញុំសូមលោកលើកឡើងសង្ខេបទេ។ ខ្ញុំគាំទ្រមេធាវីការពារ-- សំណើរបស់មេធាវីការពារក្ដី របស់លោក អៀង សារី គឺថា អស់ពីដួងចិត្តតែម្ដង។ យើងកំពុងសួរសាក្សីរូបនេះ ហាក់បីដូចជាសួរទៅ អ្នកជំនាញ មិនមែនសាក្សីទេ។ ខ្ញុំបានតាមដានស្ដាប់សាក្សីរូបនេះ សាក្សីរូបនេះបានលើកឡើងថា បើ សិនណាសួរខ្ញុំ អ្វីដែលខ្ញុំដឹងនៅពេលនេះ គឺខ្ញុំមិនអាចដឹងទាំងអស់នោះបានទេ ពីព្រោះវាចង្អៀត វាតូច ណាស់។ ដូច្នេះ បើដូច្នេះមែន យើងមិនមានអ្វីដែលត្រូវសួរសាក្សីនេះ ច្រើនតទៅទៀតទេ។

ដូច្នេះ ខ្ញុំគាំទ្រទៅដល់យុទ្ធសាស្ត្ររបស់មេធាវីការពារក្ដី ក្រុម អៀង សារី ហើយយើងខ្ញុំសំណូម ពរថា ឲ្យសួរសាក្សីរូបនេះឲ្យបានជាក់លាក់ ថាតើអ្វីដែលពិតជាគាត់បានដឹងនៅពេលនោះ នៅក្នុងអំឡុង

ពេលនោះ?

[១១:៣៣:៥៧]

សាក្សីមេធាវីការពារក្តី ក្រុម អៀង សារី ក៏បានថា គាត់លើកឡើងថា គាត់និយាយពីអ្វីដែលគាត់បានដឹងនាពេលក្រោយមកវិញនោះទេ។ យើងខ្ញុំសូមសំណូមពរឲ្យសួរទៅលើបទពិសោធន៍ផ្ទាល់របស់សាក្សីរូបនោះ នាពេលនោះតែម្តង។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ទីមួយ គឺខ្ញុំយល់ឃើញថាមានការលើកឡើងដោយយល់ច្រឡំតាមរយៈមេធាវីការពារក្តី អៀង សារី ទីមួយគឺថា សាក្សីរូបនេះលើកឡើងថា គាត់មិនអាចកំណត់នូវអ្វីដែលគាត់បានរៀន ពីអ្វីដែលគាត់រៀន ពីអ្វីដែលគាត់កត់សម្គាល់នាពេលនោះបានទេ។ សាក្សីរូបនោះមិនបាននិយាយថាដូច្នេះទេ។ ទីពីរ កំហុសទីពីរនោះគឺ សហព្រះរាជអាជ្ញាបានចាត់ទុកសាក្សីរូបនេះ គឺថាចាត់ទុកសាក្សីរូបនេះ ដូចជាអ្នកជំនាញ គឺយើងមិនបានចាត់ទុកដូច្នេះទេ។ យើងបាន-- មិនបាននិយាយថាសាក្សីនេះជាអ្នកជំនាញទេ គ្រាន់តែថាគាត់ជាមនុស្សម្នាក់ ដែលគាត់មានព័ត៌មានច្រើន។ ហើយការយល់ច្រឡំទីបី ប្រហែលជាការធ្វើ-- ការលើកឡើងបែបនេះ គឺវាមិនត្រឹមត្រូវមិនយុត្តិធម៌នោះទេ។ ដូច្នេះប្រសិនណាជាគាត់ឲ្យនិយាយតែអ្វីដែលគាត់បានរៀននៅស-២១ អ្វីដែលគាត់បានដឹងបាននៅពេលនេះមិនឲ្យគាត់និយាយក្រៅពីរង្វង់ស-២១ នោះ។ នោះគឺថាជាតាមដែលខ្ញុំដឹង គឺយើងត្រូវតែឲ្យគាត់និយាយអ្វីដែលគាត់បានដឹងមុនឆ្នាំ៧៥។ ហើយដូចអង្គជំនុំជម្រះបានដឹងហើយ មេធាវីការពារក្តីរបស់ នួន ជា និយាយថាគាត់អត់មានអាចនិយាយអ្វីបានក្រៅពីរង្វង់ស-២១ នោះទេ។ បើលើកឡើងបែបនេះ គឺជាការខុសទាំងស្រុងតែម្តង។ គាត់បានបង្រៀនគោលនយោបាយនៅពេលនោះ គាត់បានជួបជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងអំឡុងពេលនោះ ហើយអ្វីដែលគាត់អាចផ្តល់ជូនអង្គជំនុំជម្រះនេះបាននោះ គឺគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ នេះជាតួនាទីរបស់គាត់ និងបទពិសោធន៍ចាំបាច់ៗដែលគាត់បានទទួលការបណ្តុះបណ្តាលពីសំណាក់មេធាវីដឹកនាំ ពីថ្នាក់ដឹកនាំជាន់ខ្ពស់។ នេះគឺជាតួនាទីរបស់គាត់ ដែលយើងត្រូវសួរយកសក្ខីកម្មរបស់គាត់។ បើមិនឲ្យសួរដូច្នេះ គឺថាជាគួរឲ្យអស់សំណើចណាស់។

[១១:៣៦:៤៧]

សាក្សីរូបនេះ គឺជាសាក្សីមួយចាត់ទុកថាសំខាន់បំផុត ដែលអាចនឹងរៀបរាប់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពីព្រោះយ៉ាងហោចណាស់ គាត់ធ្លាប់បានបង្រៀនគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលបួនឆ្នាំ។ ការដែលលើកឡើងថា វាមានសារៈសំខាន់ណាស់ដែលយើងត្រូវតែសួរសាក្សីរូបនេះក្នុងរង្វង់តែអ្វីដែលគាត់បានដឹង បានរៀននៅក្នុងអំឡុងពេលនោះ។ សហព្រះរាជអាជ្ញាយល់ស្រប ហើយបានទើបសំណួរមកក្រោយៗមកទៀតនោះ គឺសួរសាក្សីឱ្យ-- ឆ្លើយចម្លើយរបស់គាត់ក្នុងរង្វង់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងបទពិសោធន៍របស់នាពេលនោះតែម្តង។ ហើយយោងទៅលើអត្ថបទសិក្សាស្រាវជ្រាវផ្សេងៗ គឺថាយើងនឹងអាចយោង យើងសួរទៅគាត់ទាក់ទងទៅនឹងឯកសារទាំងឡាយ ដូចជាសៀវភៅ ឬក៏ឯកសារក្រោយផ្សេងៗទៀត ដែលគាត់បានដឹងនាពេលក្រោយមក។

ជាការពិតហើយ សាក្សីរូបនេះ មានតួនាទីសំខាន់ក្នុងការដែលផ្តល់ទៅដល់យថាភាពនៃឯកសារមួយចំនួន ក៏ដូចជាគោលនយោបាយមួយចំនួន ដែលគាត់មិនបានឃើញ។ ពីព្រោះថា នៅពេលនោះគាត់អាចនឹងឆ្លើយថា តើពាក្យពេចន៍នេះ គោលនយោបាយបែបនេះ វាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលគាត់បានរៀន និងអ្វីដែលគាត់បានបង្រៀនដែរ ឬក៏អត់នោះ?

ចំណុចនេះមិនមែនជាលក្ខណៈងាយស្រួលពេកនោះទេ គឺយើងអាចនឹងឱ្យគាត់ឆ្លើយតែអ្វីដែលគាត់បានរៀនអំពីគោលនយោបាយនាពេលនោះ ក៏ដូចជាអ្វីដែលបានពីបទពិសោធន៍ផ្ទាល់របស់គាត់ហើយ បានយើងសាកសួរតទល់ជាមួយគាត់ទៀត ចង់ដឹងថាតើវាត្រឹមត្រូវដែរ ឬក៏អត់នោះ?

សូមអរគុណច្រើន។

[១១:៣៨:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីជម្រាបជូនអំពីមតិយោបល់ដែលជំទាស់គ្នានៅក្នុងរឿងស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានពិភាក្សាសម្រេច ហើយបានកត់សម្គាល់ឃើញនូវការជំទាស់នេះ ទាំងអស់នេះហើយ អង្គជំនុំជម្រះក៏បានស្នើសុំឲ្យមានការសង្កត់ធ្ងន់។ ទីមួយគឺថាសាក្សីនេះគឺសួរគាត់ពាក់ព័ន្ធទៅនឹងការដឹងឮ រួមទាំងឯកសារមួយចំនួនដែលគាត់បានដឹងឮនៅក្នុងរបបនេះតែម្ដង ហើយសក្ខីកម្មរបស់សាក្សីរូបនេះ នៅពេលដែលត្រូវចេញសាលក្រម គឺថាយើងនឹងត្រូវយកទៅពិចារណា និងត្រូវយកទៅពិនិត្យ និងពិភាក្សាដេញដោលដោយគ្រប់ភាគីទាំងអស់។

តើលោកប្រធាន លោកប្រធានមានចង់លើកឡើងអំពីអ្វីទៀតដែរទេ?

[១១:៤៤:១៤]

**ប្រធានអង្គជំនុំ៖**

មិនមានទេ។ លោកចៅក្រម ហ្សង់ម៉ាក មានទេ?

សូមអញ្ជើញ ឌុច មានការអីទៅ?

**លោក កាំង ហ្គេកអ៊ាវ៖**

ខ្ញុំសូមជម្រាបទិដ្ឋភាពខ្លះ នៃសក្ខីកម្មរបស់ខ្ញុំ។ ឥឡូវទិដ្ឋភាពវាមានពីរ។ ប្រជាជនកម្ពុជាទូទាំងប្រទេសនិយាយថាបក្សកុម្មុយនីស្តកម្ពុជានិយាយថា បក្សកុម្មុយនីស្តកម្ពុជាបង្អត់បាយប្រជាជន។ ក៏ប៉ុន្តែសក្ខីកម្មរបស់ថ្នាក់ដឹកនាំខ្លះថា អ្អឺ! យើងចែកគ្នាហូបទៅ។ សក្ខីកម្មរបស់ខ្ញុំ ខ្ញុំនិយាយថា បក្សកុម្មុយនីស្តកម្ពុជាមាននយោបាយមួយរឹតត្បិតការហូបចុករបស់ប្រជាជន ដោយឈរលើឯកសារបក្សជាមូលដ្ឋានតែម្ដង។ ដូច្នេះខ្ញុំសូមអានឯកសារនុ៎ង គឺឯកសារ D00677--

**ប្រធានអង្គជំនុំ៖**

ឌុចៗ ឥឡូវនេះលោកចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ ក្នុងនាមជាសាក្សី យើងបានប្រាប់តាំងពីដើមហើយ។ សាក្សីមានកាតព្វកិច្ចឆ្លើយតបទៅនឹងសំណួរដែលសួរ។ ដូច្នេះមុននឹងឆ្លើយត្រូវស្ដាប់ឲ្យច្បាស់លាស់នូវសំណួរដែលភាគីពាក់ព័ន្ធក្នុងរឿងក្ដីនេះ មានសិទ្ធិសួរលោក។ ប្រសិនបើសួរគ្រាន់តែឲ្យឆ្លើយមកថា បាទ ឬក៏ទេ នោះ គឺអាចធ្វើឆ្លើយតែត្រឹម បាទ ឬក៏ទេ បានហើយ លើកលែងតែសំណួរដឹកមុខដែលអង្គជំនុំជម្រះនឹងហាមឃាត់ ឬក៏ភាគីដទៃទៀតនឹងជំទាស់ អង្គជំនុំជម្រះនឹងសម្រេចអំពីបញ្ហានេះ។

[១១:៤៦:០៦]

បញ្ហាទីពីរ ក្នុងនាមលោកជាសាក្សី លោកមិនអាចឆ្លើយដោយឲ្យលទ្ធផលជាការវិភាគវាយតម្លៃអត្តនោម័តិរបស់សាក្សីបានទេ។ ហេតុការណ៍ដែលបានកើតឡើងដែលលោកបានដឹង លោកបានឃើញ លោកបានឮ និងបទពិសោធន៍ផ្ទាល់របស់លោកដែលបានជួបប្រទះក្នុងអំឡុងពេលនៃអង្គហេតុដែលពាក់ព័ន្ធនឹងការធ្វើលើកយកមកធ្វើសវនាការ ហើយភាគីសួរគឺលោកឆ្លើយតបទៅនឹងសំណួរនោះ ដោយគិតពិចារណាដូចយើងបានជម្រាប។ លើកលែងតែសំណួរដែលគេឲ្យអត្ថាធិប្បាយ ឬក៏ឲ្យរៀបរាប់ នោះមានលក្ខណៈវែង។ អ៊ីចឹងចំណុចផ្សេងទៀត គឺមិនគប្បីប្រើប្រាស់នូវបញ្ហាអីផ្សេងទៀតនោះទេ ដោយឡែកបញ្ហាអម្បាញ់មិញនេះ គឺមានបញ្ហាពីរដំណាក់កាល។

[១១:៤៧:០៨]

ដំណាក់កាលមួយ ដែលយើងបាននិយាយរួចហើយ។ ដំណាក់កាលមួយទៀត គឺឆ្លងកាត់បទពិសោធន៍របស់លោកដែលមកនៅទីនេះ នៅក្នុងអំឡុងពេលធ្វើសំណុំរឿង ០០១ កន្លងមក លោកបានមើលសំណុំរឿង មើលអីច្រើន។ នោះជារឿងសំណួរដែលនឹងអាចពាក់ព័ន្ធក្រោយ មិនមែនជាសំណួរអាទិភាពទេ គឺសំណួរ និងចម្លើយអាទិភាព គឺរឿងហេតុទាំងឡាយដែលលោកបានដឹង បានឮ បានឃើញ និងបទពិសោធន៍របស់លោកផ្ទាល់ឆ្លងកាត់នៅក្នុងរបប ប៉ុល ពត តាំង-- ចាប់តាំងពីដើមទីដែលលោកចូលបដិវត្តក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០កន្លងមកនេះ ព្រោះវាពាក់ព័ន្ធជាមួយនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ ហើយបន្ទាប់មកទៀត គឺលំដាប់ផ្សេងទៀតនេះ គឺមកពាក់ព័ន្ធជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកទៀត គឺតួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយនិងបញ្ហាចុងក្រោយនេះ គឺបញ្ហា ដែលបញ្ហាបន្ទាប់មកទៀត គឺបញ្ហាទំនាក់ទំនងការងាររវាងថ្នាក់លើថ្នាក់ក្រោមអីអ៊ីចឹងទៅ។ នេះជាគោលការណ៍។

[១១:៤៨:១៤]

ហើយប្រហែលការសួរនាំនេះ ក៏បានមានចំនួន មួយចំនួនក៏បានចូលទៅក្នុងរឿងហើយ ប៉ុន្តែមួយចំនួនទៀតវាចេញឆ្ងាយ។ អ៊ីចឹងទេ គឺសូមលោករក្សាស្ថានភាពមួយ គឺត្រងត្រាប់ចាំស្តាប់សំណួរ ហើយសូមឆ្លើយចំពោះចម្លើយណាដែល-- សំណួរណាសួរបែបអត្ថាធិប្បាយ សូមលោកធ្វើអត្ថាធិប្បាយក្នុងកម្រិតមួយដែលមិនខ្លីពេក ប៉ុន្តែមិនវែងពេកដែរ ពីព្រោះសវនាការច្រើនរឿងក្តី។ រឿងអង្គហេតុដែលកើតឡើងតាំងពីទសវត្សរ៍ឆ្នាំ៥០ នៃការតស៊ូរហូតដល់ឆ្នាំ៧៩ មិនមែនជារឿងធម្មតាទេ។ និយាយមិនដឹងជាប៉ុន្មានថ្ងៃទេនឹងចប់នោះ បើអ្នកពូកែនិយាយហ្នឹង អាចនិយាយមួយជីវិតនិយាយមិនចប់ផង។ អ៊ីចឹងគឺ

កម្រិតត្រឹមតែសំណួរដែលពាក់ព័ន្ធ ព្រោះសំណួរយើងបានកំហិតហើយ ឲ្យភាគីគឺយកចិត្តទុកដាក់ទៅលើអង្គហេតុទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះកំណត់លើកយកមកឲ្យធ្វើសវនាការសំណុំរឿង ០០២/០១ និយាយជារួម និងដោយឡែក គឺវាមានបែងចែកជាភាគទៀត។

[១១:៤៩:២៥]

វគ្គមួយ កន្លងមក ហើយនិងឥឡូវនេះកំពុងតែធ្វើវគ្គពីរ ប៉ុន្តែដោយសារសាក្សី វាអាចមិនចៀសវាងក្នុងការកោះហៅច្រើនដង អង្គជំនុំជម្រះគិតថាសាក្សីណាដែលដឹងរឿងរ៉ាវច្រើន គឺឲ្យសួរមួយចប់តែម្តងនៅក្នុងសំណុំរឿង០០២/០១ គឺវគ្គដំបូងនៃអង្គជំនុំជម្រះដែលបានបំបែកយកមកធ្វើសវនាការ។ ប្រហែលជាលោក កាំង ហ្កេកអ៊ាវ យល់ហើយបញ្ហា។ អ៊ីចឹងចាំស្តាប់នូវសំណួរ ហើយឆ្លើយតបនេះក្នុងនាមជាសាក្សី។

សូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាបន្តសំណួរ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងសូមលោកឆ្លើយនូវអ្វីដែលលោកបានដឹង បានឮ ហើយសូមសំអាងតែលើអ្វីដែលជាឯកសាររបស់បក្ស កុំសំអាងទៅលើឯកសារផ្សេង។ ហើយអ៊ីចឹង ចង់ដឹងថាលោកយល់ដឹងអំពីបញ្ហាទាំងអស់នេះតាមរយៈអីខ្លះ? ដូចជា លោកអានទង់បដិវត្តទាំងអស់ ឬក៏យ៉ាងម៉េច? ហើយលោករៀនពីទង់បដិវត្តហ្នឹងបានយ៉ាងម៉េចដែរលោក? សូមលោកជួយជម្រាប។

[១១:៥១:១២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

គោរពលោកប្រធាន។ គេមិនដែលយកឈើពុក ឈើរលួយ ឈើស្អុយមកឆ្លាក់ធ្វើព្រះ មកទេសនាឲ្យពុទ្ធបរិស័ទនោះទេ។ សូមជម្រាប។ សូមអរគុណ ខ្ញុំសូមមានមតិតែប៉ុណ្ណេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១១:៥១:៥១]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំយល់ថា អន្តរាគមន៍របស់ខ្ញុំហាក់ដូចជាយឺតបន្តិចហើយ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសូមជម្រាបថា លោក ឌុច ពេលនេះត្រូវបានទទួលស្គាល់ថាមានលក្ខណៈជាសាក្សី ហើយមិនត្រូវបានបដិសេធរបស់គាត់ទេ។ ដូច្នេះគាត់មានសិទ្ធិពេញលេញនៅក្នុងការឆ្លើយក្នុងលក្ខណៈជាសាក្សី។ ដូច្នេះមិនត្រូវមានការមានមតិណា ដែលជាការវាយប្រហារទៅលើសាក្សីទេ។ សូមលោក-- សូមអរគុណលោកប្រធាន។

[១១:៥២:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក នួន ជា សូមលោកមានការអត់ធ្មត់ ហើយត្រងត្រាប់ស្ដាប់នូវសក្ខីកម្មរបស់ ឌុច ដែលជាសាក្សីរបស់អង្គជំនុំជម្រះកំណត់យកមកធ្វើសវនាការដេញដោល។ ហើយតាមការប៉ុនប៉ងរបស់លោក គឺព្យាយាមនៅក្នុងការតទល់ចំពោះសាក្សីនេះ។ ដើម្បីអាចតទល់បានលោកត្រូវតែក្ដាប់ឲ្យបាននូវសំណួរនិងចម្លើយទាំងអស់ ដើម្បីតទល់ចុងក្រោយ នៅពេលដែលដល់វេនមេធាវីរបស់លោកសួរចោទឆ្លើយជាមួយនឹងសាក្សីរូបនេះ នោះនឹងដល់វេនលោក ដើម្បីអង្គជំនុំជម្រះនឹងទុកឱកាសឲ្យលោកក្នុងការតទល់។ ចំពោះថា តម្លៃនៃភស្តុតាង ទម្ងន់នៃភស្តុតាងដែលផ្ដល់ដោយសាក្សីរូបនេះយ៉ាងណានោះ គឺវាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ដែលអង្គជំនុំជម្រះនឹងវាយតម្លៃភស្តុតាងទាំងអស់នៅចំពោះមុខខ្លួនដោយឥតស្សរចិត្តនៅក្នុងរឿងក្ដីនេះ។

[១១:៥៣:៥៤]

ឌុច មិនមែនមកផ្ដល់សក្ខីកម្មនេះដោយចិត្តឯងនោះទេ គឺអង្គជំនុំជម្រះមិនត្រឹមតែកោះហៅទេ បង្គាប់ឲ្យយកខ្លួនមក បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះទៀតផង។ គឺយើងប្រធានអង្គជំនុំជម្រះសាលាដំបូងជាអ្នកកោះហៅ ជាអ្នកបង្គាប់ឲ្យយកសាក្សីរូបនេះមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្តសំណួរ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ តើលោកសិក្សាស្វែងយល់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងយ៉ាងណាខ្លះ នៅក្នុងអំឡុងពេលនុ៎ង?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** សំណួរនេះទូលាយពេក។

**ស៖** ឥឡូវខ្ញុំចូលឲ្យស៊ីជម្រៅបន្តិច តើ--

**ឆ៖** បែក បំបែក។ សំណួរអំមិញទូលាយពេក។

**ស៖** តើលោកបានសិក្សាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងតាមរយៈសៀវភៅអ្វីខ្លះរបស់បក្ស? ក៏ដូចជាអានទស្សនាវដ្ដីទង់បដិវត្ត តើមានដែរទេ?

**ឆ៖** ទស្សនាវដ្ដីទង់បដិវត្ត មាន។ ឯកសារសម្ងាត់របស់បក្ស មាន។ ទាំងពីរហ្នឹង។

**ស៖** ទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្ត តើលោកអានប៉ុន្មានដែរ អានទាំងអស់អត់ទេ?

**ឆ៖** ខ្ញុំសូមជម្រាបដោយត្រង់ថា "ទស្សនាវដ្ដីទង់បដិវត្ត" នេះ វាមានតួនាទីសំខាន់ណាស់ក្នុងការដែលខ្ញុំរៀនសូត្រមាគ៌ារបស់បក្ស ដែលលេខាបក្សសរសេរ។ ដំបូងខ្ញុំឃើញ "ទស្សនាវដ្ដីទង់បដិវត្ត" នេះនៅមន្ទីរស្រុកចម្ការលើ។ កាលណោះនៅជាឈ្មោះ "ទង់ក្រហម"។ ពេលនោះអត្ថបទមានតែមួយទេ មួយលេខមានតែមួយអត្ថបទ ឈ្មោះថា "ប្រវត្តិតស៊ូនយោបាយ១១ឆ្នាំ របស់ប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់បក្ស"។ ក្រោយឆ្នាំ១៩៧០ ខ្ញុំធ្វើជាប្រធាន ម-១៣ ខ្ញុំចាប់ផ្ដើមទទួល "ទង់បដិវត្ត" លែងឈ្មោះ "ទង់ក្រហម" ហើយ ប្រែឈ្មោះ "ទង់បដិវត្ត"។ ជាទៀងទាត់រាល់ខែ ហើយខំរៀនខ្លាំងណាស់ខ្លាចជ្រុះ។ ដូច្នេះ ខែណាក៏ដោយក៏ខ្ញុំបានអានបានសិក្សារៀនសូត្រ។ ទិដ្ឋភាពការយល់ដឹងរបស់ខ្ញុំទូលាយដែរ កាន់តែពង្រីកឲ្យទូលាយ។

[១១:៥៧:១៧]

ខ្ញុំសូមនិយាយអំពីបញ្ហាខ្លះគ្រួសៗ "ទស្សនាវដ្ដីទង់បដិវត្ត" ឆ្នាំ៧១ និយាយអំពីការបះបោររបស់ឃុត ឧត្តមរង្សរតនា។ និយាយអំពីចលនា សកម្មភាពរបស់បក្សក្នុងការបង្ក្រាបចលនា ឃុត ឧត្តមរង្សរតនា នេះ។ នេះជាបញ្ហាមួយទៅ។ មួយទៀត ដែលខ្ញុំសុំជូនជាការចាប់អារម្មណ៍ដែរ ប៉ុល ពត គាត់

សរសេរអំពីតួនាទីរបស់អ្នកនិពន្ធបដិវត្តន៍។ គាត់ថា អ្នកនិពន្ធបដិវត្តន៍ត្រូវសរសេរទៅតាមគោលនយោ-បាយជាយុទ្ធវិធីរបស់បក្សក្នុងរយៈកាលនីមួយៗ។ ខ្ញុំក៏ចងចាំទៅ។ ខ្ញុំប្រៀបធៀបទៅនឹងសេចក្តីសរសេររបស់ ម៉ៅ សេទុង ទៅផ្សេងទៅ នេះគឺនិយាយអំពីតួនាទីរបស់អ្នកនិពន្ធបដិវត្តន៍។

នៅក្នុងឆ្នាំ១៩៧៣ ហ្នឹងដែរ ប៉ុល ពត អប់រំថា វៀតណាមគឺ ឡេ យន់ ដឹកគិត-- ឡេ យន់ គិតគូរបក្សតែមួយ កងទ័ពតែមួយ។ បានន័យថា ពេលនោះ ប៉ុល ពត អប់រំបក្សទាំងមូលថា "ឡេ យន់ចាត់ទុកកម្ពុជា ជាសម្ព័ន្ធឥណ្ឌូចិនដែលមានយួនជាម្ចាស់"។

[១១:៥៨:៥៣]

**ស៖** បាទ សូមអរគុណលោក។ អ៊ីចេះ តើលោករៀននយោបាយ-- គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកមានបានរៀននៅកន្លែងដូចជា វគ្គបណ្តុះបណ្តាលផ្សេងៗនៅក្នុងពេលនោះដែរទេ?

**ឆ៖** ខ្ញុំជម្រាបហើយ។ គោលនយោបាយរបស់បក្ស ទីមួយឯកសារបក្ស ខ្ញុំបានជម្រាបហើយឯកសារស្តីខ្លះ។ ក្រោយឆ្នាំ១៩៧១ សង្គ្រាមប្រជាជន, យុទ្ធវិធីសង្គ្រាមឈ្លប, គោលនយោបាយរបស់បក្ស, សីលធម៌១២ប្រការ ហើយទន្ទឹមហ្នឹង ក្នុងមួយឆ្នាំលេខាភាគហៅខ្ញុំទៅរៀនអំពីទស្សនៈសភាពការណ៍ អំពីគោលជំហរចាត់តាំង អំពីជំហរគោលនយោបាយសតិអារម្មណ៍។ រាល់ឆ្នាំ មិនដែលខាន។

[១២:០០:០៨]

**ស៖** បាទ សូមអរគុណ។ លោកប្រធាន តើគួរបន្តទៀត ឬក៏សម្រាកសិនបាទ?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមនឹងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាសដើម្បីពិសាអាហារថ្ងៃត្រង់។ សម្រាកពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ។

អនុរក្សាមន្ទីរឃុំឃាំងឲ្យនាំសាក្សីទៅ កាំង ហ្កេកអ៊ាវ ទៅកាន់បន្ទប់សម្រាកសម្រាប់សាក្សីហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទពីររូប នួន ជា ហើយនិង ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោម ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តនូវការតាំងសំណួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ លោកបានជម្រាបជូនអង្គសវនាការរួចហើយថា នៅពេលដែលលោកធ្វើការនៅម-១៣ គឺលោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាប្រចាំអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដែលបានធ្វើឡើងមួយឆ្នាំម្តង។ តើលោកនៅចាំទេថា វគ្គបណ្តុះបណ្តាលនោះធ្វើឡើងម្តងៗហ្នឹងរយៈពេលប៉ុន្មានថ្ងៃដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** មិនលើសពីកន្លះខែទេ រួមទាំងខុទ្ទេសនាមផង បទខុទ្ទេសនាមផង រួមទាំងឆ្លងជីវទស្សន៍និងប្រវត្តិរូបផង មិនលើសពីកន្លះខែ។

[១៣:៣៥:១១]

**ស៖** តើខាងណាខ្លះចូលរួមក្នុងវគ្គបណ្តុះបណ្តាលនុ៎ង បទខុទ្ទេសនាមនុ៎ង?

**ឆ៖** នៅភូមិភាគពិសេស ដូចមានតែនេះទេ ជាមួយ វន វ៉េន មានតែពួកមន្ទីរ។ កងទ័ពដូចមិនឃើញ។ ខ្ញុំភ្លេច វង្វេងអស់ហើយ។

**ស៖** លោកបានលើកឡើងហើយផងដែរថា លោកបានជួបជាមួយ វន វ៉េត ហើយនិង សុន សេន ជាប្រចាំផងដែរ ដើម្បីរាយការណ៍ពីបញ្ហាមួយចំនួន ហើយនៅពេលដែលលោកនៅម-១៣ នុ៎ង

ថាតើនៅពេលនោះ វន វ៉េត ឬក៏ សុន សេន ហ្នឹងដែលប្រាប់លោក ឬក៏ពិភាក្សាអីជាមួយលោកអំពីគោលនយោបាយរបស់បក្សដែលទេ ពេលនុ៎ង?

[១៣:៣៦:២១]

**ឆ៖** រឿងពិភាក្សាក្នុងពេលខ្ញុំរាយការណ៍ពីរឿងខ្សែខ្មាំង អត់មានពិភាក្សាទេ ខ្ញុំរាយការណ៍ហើយ គាត់សម្រេច។

**ស៖** តើពេលនោះដែលមានបានជជែកជាមួយគាត់ ឬក៏គាត់បានប្រាប់លោកអ្វីពីគោលនយោបាយរបស់បក្សដែរទេ?

**ឆ៖** រឿងរាយការណ៍ការងារនគរបាលមិនទាក់ទង មិនៗច្រឡូកច្រឡំគ្នានឹងគោលនយោបាយរបស់បក្សទេ ដាក់ដោយឡែក។

**ស៖** ម្សិលមិញលោកក៏បានលើកឡើងផងដែរថា ការងាររបស់លោកនៅម-១៣ ហ្នឹងក៏មានការទទួលខុសត្រូវខាងការងារអប់រំអំពីគោលនយោបាយរបស់បក្សដែរ ដើម្បីណែនាំ-- ដើម្បីបង្ហាត់បង្ហាញដល់បុគ្គលិករបស់លោក។ ថាតើការបង្រៀន ការណែនាំរបស់លោកហ្នឹង គឺដើម្បីនានាឲ្យបុគ្គលិករបស់លោកទាំងអស់ហ្នឹងយល់ដឹងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរទេ?

**ឆ៖** ពិតជាដើម្បីឲ្យយល់ដឹងពីគោលនយោបាយ និងមាគ៌ានយោបាយរបស់បក្ស។

[១៣:៣៧:៣៩]

**ស៖** ហើយលោកក៏បានជម្រាបជូនអង្គសវនាការផងដែរថា អំឡុងពេលដែលធ្វើការនៅមន្ទីរស-២១ លោកក៏បានចូលរៀនវគ្គបណ្តុះបណ្តាលជាប្រចាំឆ្នាំជាមួយ សុន សេន ផងដែរ។ ថាតើការរៀនវគ្គនយោបាយនោះធ្វើឡើងប៉ុន្មានថ្ងៃដែរ? ហើយរៀនពីអ្វីខ្លះដែរនៅពេលនោះ លោកចាំទេ?

**ឆ៖** វគ្គនយោបាយដែល សុន សេន គាត់បង្រៀន រាល់ឆ្នាំ ជាទូទៅគឺមិនលើសពីកន្លះខែដែរ។ ហើយឯកសារខ្ញុំឃើញបង ម៉ម ណៃ គត់បានច្បាស់លាស់ល្អគួរសម គឺនៅក្នុងសំណុំរឿងឯកសារ ក.ណ.ហ ១៦៦។

**ស៖** បាទ អរគុណ។ ចាប់ពីឆ្នាំ១៩៧៥ ជាបន្តបន្ទាប់មកទៀតនោះ តើលោកបានចូលរៀនអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចដែលលោកនៅៗម-១៣ ដែរទេ?

**ឆ៖** សូមទោស ខ្ញុំឆ្លើយអំមិញច្រឡំហើយ។ ក.ណ.ហ កំណត់ហេតុរបស់បង ម៉ម ណៃ ហ្នឹងគឺឯកសារចាប់តាំងពីថ្ងៃ២៥ ខែមិថុនា ឆ្នាំ១៩៧៥ មកទេ គឺក្រោយ៧៥។ ដូច្នេះមុន៧៥ អត់មាន

ឯកសារសល់ទេ ក៏ប៉ុន្តែមួយឆ្នាំៗមុនដំបូងចូលទៅដល់ទស្សនៈសភាពការណ៍ ខ្លាំងយ៉ាងម៉េច? ចាញ់យើងយ៉ាងម៉េច? យើងឈ្នះយ៉ាងម៉េច? ត្រៀមស្អីតទៅទៀត? ហើយសតិអារម្មណ៍ធ្វើយ៉ាងម៉េច? ចាត់តាំងធ្វើយ៉ាងម៉េច? ប៉ុនន៉ុង រាល់ឆ្នាំ។

[១៣:៣៩:៣១]

**ស៖** តើលោកអាចជម្រាបបានទេថា ម៉ម ណៃ ហ្នឹងគាត់ជានរណាដែរ?

**ឆ៖** ម៉ម ណៃ ជាសាក្សីម្នាក់មកផ្តល់នៅនេះ។ ជាបុគ្គលិកម្នាក់ ចាស់ទុំនៅស-២១។

**ស៖** ខ្ញុំសូមលើកឡើងអំពីសំណួររបស់ខ្ញុំម្តងទៀត ថាចាប់ពីឆ្នាំ១៩៧៥ ជាបន្តបន្ទាប់មកហ្នឹង លោកបានចូលរៀនវគ្គនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចកាលដែលលោកនៅ ម-១៣ ដែរទេ?

**ឆ៖** ដូចគ្នា។

**ស៖** ហើយមុនពេលសម្រាកព្រឹកមិញនេះ លោកបានលើកយោងអំពីឯកសារមួយដែលសិក្សា- - ដែលលោកបានសិក្សាអំពីគោលនយោបាយរបស់បក្ស ហើយដែលក្នុងនោះ លោកលើកឯកសារដែលមានឈ្មោះថា "ឯកសារសម្ងាត់របស់បក្ស"។ តើឯកសារសម្ងាត់របស់បក្សហ្នឹង ជាឯកសារអ្វីទៅលោក?

**ឆ៖** ដែលហៅថា "ឯកសារសម្ងាត់របស់បក្ស" នោះ។ ដែលហៅថា ឯកសារសម្ងាត់របស់បក្សហ្នឹង គឺ ទង់បដិវត្តនេះ ក៏ជាឯកសារសម្ងាត់របស់បក្ស។ គេប្រើបានតែក្នុងចំណោមបក្ខជន។ ប៉ុន្តែឯកសារទង់បដិវត្តនេះ វាចេញប្រចាំខែ។ ឯកសារផ្សេងទៀត គេចេញម្តង គឺជាយុទ្ធសាស្ត្រតែម្តង។

**ស៖** ឯកសារសម្ងាត់របស់បក្ស ដែលចេញម្តងខែហ្នឹង តើគេយកទៅចែកចាយឲ្យអ្នកណាខ្លះ?

**ឆ៖** ទង់បដិវត្ត ទោះបីក្រោយ៧៥ហើយ ក៏មានតែបក្ខជនទេ ដែលមានសិទ្ធិរៀនសូត្រ។ សម្ព័ន្ធយុវកក មិនទាន់មានសិទ្ធិទេ។

[១៣:៤២:០៩]

**ស៖** ទាក់ទងទៅនឹងការសិក្សាស្វែងយល់របស់លោក ទៅនឹងអំពីគោលនយោបាយរបស់បក្ស តើមានវិធីអ្វីផ្សេងទៀត ក្រៅពីអ្វីដែលលោកបានសិក្សាស្វែងយល់ ដែលលោកបានលើកឡើងហ្នឹងមុនដែលទេ នៅពេលនោះ?

**ឆ៖** ការប្រជុំជីវភាពក៏ជាវិធីមួយសិក្សាស្វែងយល់ជាប់នឹងជាក់ស្តែងដែរ យកទ្រឹស្តីទៅភ្ជាប់នឹងជាក់ស្តែង។ នេះជាវិធីមួយ។

**ស៖** ទាក់ទងទៅនឹងឯកសារសម្ងាត់របស់បក្ស តើលោកអាចរៀបរាប់បានទេ ថាឯកសារនោះប្រភេទអ្វីខ្លះទៀតទៅ មានច្រើនប្រភេទទេ?

**ឆ៖** ខ្ញុំបានរៀបរាប់ជូនរួចហើយ អង្កាល់ដែលខ្ញុំទៅរៀនវគ្គសម្ងាត់នោះ។ រៀនអំពីមាគ៌ានយោបាយជាយុទ្ធសាស្ត្រ អំពីគោលនយោបាយជាយុទ្ធវិធីប្រមូលកម្លាំង លក្ខន្តិកៈបក្សឆ្នាំ១៩៦០ សតិអារម្មណ៍អង្គការវិន័យ របៀបទិតៀន និងស្វ័យទិតៀនអីចេះផងមិនដឹង។ មោទកភាព ខុសនិងត្រូវ អាហ្នឹងជាឯកសារដែលគេចេញម្ដងរហូត។ ហើយដល់ក្រោយមក ឃើញអាឯកសារចេញម្ដងរហូតហ្នឹង គឺឯកសារ "សង្គ្រាមប្រជាជន" "យុទ្ធវិធីសង្គ្រាមឈ្លប" "គោលនយោបាយមួយចំនួនរបស់បក្ស" ហើយនិង "សីលធម៌បដិវត្តន៍"។ ហើយក្រៅពីនោះ គឺមានវគ្គសិក្សាប្រចាំឆ្នាំហ្នឹងឯង ហើយនិងទង់បដិវត្ត។

[១៣:៤៤:១៩]

**ស៖** ឯកសាររបស់បក្សហ្នឹង មានចែងពីអ្វីខ្លះទៅនៅក្នុងឯកសារហ្នឹង?

**ឆ៖** ទូលាយណាស់ ពិបាកឆ្លើយ ទូលាយ។ សំណួរលោកទូលាយ។ ឥឡូវ សូមចែកសំណួរហ្នឹង ឲ្យល្អិត ស្រួលឆ្លើយ។

**ស៖** ចង់បញ្ជាក់ថា នៅក្នុងឯកសារសម្ងាត់របស់បក្ស នៅក្នុងឯកសារនុំង តើមាននិយាយពីអ្វី? ឧទាហរណ៍ថា គោលនយោបាយរបស់បក្ស? មនោគមន៍វិជ្ជារបស់បក្សអីហ្នឹង តើមាននិយាយពីអ្វីទេ?

**ឆ៖** ខ្ញុំបានជម្រាបព្រឹកមិញ ល្អិតដែរ។ ឯកសារជាគ្រឹះដែលអនុម័តម្ដងរហូតមួយជីវិតបក្ស គឺមាគ៌ានយោបាយជាយុទ្ធសាស្ត្រ អនុម័តឆ្នាំ១៩៦០។ ហើយបន្ទាប់មកទៀត មាគ៌ាប្រមូលកម្លាំងរណសិរ្ស-- យុទ្ធវិធីប្រមូលកម្លាំងរណសិរ្សធំទូលាយ ហើយលក្ខន្តិកៈបក្សគេប្រែពីសន្និបាតមួយទៅសន្និបាតមួយ។ លក្ខន្តិកៈបក្សដែលខ្ញុំបានឃើញបីជំនាន់ហើយ គឺលក្ខន្តិកៈបក្ស១៩៦០ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ដែលយើងប្រើប្រាស់រាល់ថ្ងៃនេះ។ ហ្នឹងគឺគេប្រែបានពីសន្និបាតមួយទៅសន្និបាតមួយ។ ក្រៅពីនោះទង់បដិវត្តចែកចេញប្រចាំខែ។

**ស៖** សូមលោកជួយជម្រាបឲ្យកាន់តែច្បាស់បន្តិច អំពីគោលបំណងរបស់ឯកសារទង់បដិវត្តហ្នឹង តើមានគោលបំណងអ្វីដែរ?

[១៣:៤៦:១៣]

**ឆ៖** ទង់បដិវត្តជាភាសា ជាការអប់រំរបស់លេខាបក្ស ដល់បក្សទាំងមូលប្រចាំខែ។ ខាងសតិ

អារម្មណ៍លេខាយល់ឃើញថា អប់រំស្អី ខាងនយោបាយលេខាយល់ឃើញថាអប់រំអី ខាងសតិអារម្មណ៍លេខាយល់ឃើញអប់រំអី លេខាជាអ្នកសរសេរ។ បក្ខជនផ្សេងទៀតជាអ្នកសិក្សា ខំពាក់ព័ន្ធកសាងខ្លួន។

**ស៖** លោកក៏បានជម្រាបជូនអង្គសវនាការរួចហើយដែរ ថាលោកបានបង្រៀនបុគ្គលិករបស់លោកនៅ ស-២១ ហើយលោកនៅចាំទេ ថាបុគ្គលិកដែលលោកបង្រៀននោះមានទាំងអស់ប៉ុន្មាននាក់ដែរ?

**ឆ៖** បើយកវគ្គសិក្សាមកបង្រៀន បើយកឯកសារវគ្គសិក្សាដែលខ្ញុំបានរៀនពីមេខ្ញុំមក យកទៅបង្រៀនប្រមូលៗនៅភ្នំពេញ ហើយនិងប្រមូលកម្មាភិបាលពីព្រៃសយកមករៀន។ ច្រើនដែរ ម្តងប្រហែល៥០នាក់។ ហើយច្រើនរៀននៅកន្លែងមួយជាវិហារចាស់របស់ពួកគ្រីស្ទាននេះ ឈ្មោះវិហារបាត់ទ្រីហ៊ឹម។ បើបង្រៀនជាពួកអ្នកសួរចម្លើយគ្នាប្អូនដប់នាក់មិនដល់ផង។

[១៣:៤៨:១៤]

**ស៖** តើការបង្រៀននេះ ធ្វើឡើងញឹកញាប់ទេនៅពេលនុ៎ង?

**ឆ៖** បើបង្រៀនពួកសួរចម្លើយបង្រៀននិយាយគ្នាញឹកញាប់ដែរ។ ញឹកប៉ុនណា ស្អីប៉ុនណា ខ្ញុំឃើញកំណត់ហេតុបង ម៉ម ណៃ សរសេរបានច្រើនណាស់នៅហ្នឹង ក.ហ-- ក.ណ.ហ ១៦៦ ហ្នឹង។

**ស៖** ឥឡូវខ្ញុំចូលមកតសំណួររបស់ខ្ញុំបន្តទៀត ទាក់ទងទៅនឹងមនោគមន៍វិជ្ជា តាមរយៈការគ្រប់គ្រងបែបណារបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង ចង់ឲ្យសង្គមកម្ពុជាប្រែក្លាយទៅជាយ៉ាងម៉េចដែរលោកដឹងទេ?

[១៣:៤៩:១៩]

**ឆ៖** មុនឆ្នាំ១៩៧០ ជាទូទៅមានចម្រៀងមួយ រំដោះប្រជាជនប្រឆាំងចក្រពត្តិសក្តិភូមិនាយទុនប្រតិកិរិយា។ អ្នកស្រែត្រូវតែមានស្រែធ្វើ។ ហើយដល់ក្រោយឆ្នាំ១៩៧៥ មាគ៌ាមានពីរ កសាងប្រទេសការពារប្រទេស។ ហ្នឹងខ្ញុំសូមសង្ខេបប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ តើលោកដឹងទេថា បក្សកុម្មុយនីស្តកម្ពុជាហ្នឹងគាំទ្រឲ្យមានការប្រើហិង្សាឬប្រើកម្លាំង ដើម្បីសម្រេចបាននូវគោលនយោបាយរបស់ខ្លួនដែរទេ នៅពេលនុ៎ង?

**ឆ៖** ហ្នឹងវាជានិន្នាការមួយនៅលើសកលលោកហើយ។ ដែលហៅថា សេរីនិយម គឺដើរតាមសេចក្តីសម្រេចរបស់មហាសន្និបាតលើកទី២០ របស់បក្សកុម្មុយនីស្តសហភាពសូវៀត គេមិនប្រើកម្លាំងទេ។ ឯចំណែកអ្នកដែលគេហៅថា អ្នកបដិវត្តន៍ម៉ាក្ស-ឡេនីន ពិតប្រាកដហ្នឹង គឺប្រើកម្លាំង។

[១៣:៥១:០០]

**ស៖** ហើយថាតើមានការអនុញ្ញាតឲ្យមានការធ្វើ ការបែងចែកនយោបាយនៅក្នុងប្រទេសដែរទេ?

**ឆ៖** នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាមិនមានទេ។

**ស៖** ចុះទាក់ទងទៅនឹងវប្បធម៌ផ្សេងៗ តើបក្សកុម្មុយនីស្តកម្ពុជាហ្នឹងគាំទ្រឲ្យមានទេក្នុងសង្គមកម្ពុជាហ្នឹង?

**ឆ៖** គេអនុវត្តនយោបាយពីរ។ ទីមួយ វប្បធម៌ផ្សេងៗគេមិននិយាយដល់ អត់និយាយឲ្យដល់ទេ។ ពុទ្ធសាសនាក៏គេមិននិយាយឲ្យដល់ គ្រិស្តសាសនាក៏គេមិននិយាយឲ្យដល់ គេគិតតែធ្វើម៉េចសាមគ្គីរំដោះប្រទេសជាតិ។ នេះបញ្ហាដែលខំបំពាក់បំប៉នសាមគ្គីរំដោះប្រទេសជាតិ បម្រើវណ្ណៈកម្មករកសិករ។

[១៣:៥២:០២]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។ លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវខ្ញុំឈានចូលទៅដល់ប្រធានបទមួយទៀត គឺទាក់ទងទៅនឹងគោលនយោបាយនៃការផ្លាស់ទីលំនៅរបស់ប្រជាជន និងការអនុវត្ត។

**សួរដោយលោក សេង ប៊ុនឃាង៖**

ឥឡូវខ្ញុំលើកឡើងនូវគោលនយោបាយជាក់លាក់ដែលលោកបានដឹង ហើយដោយខ្ញុំមិនលើកអំពីស៊ីជម្រៅដល់ការអនុវត្តទេ ហើយជាដំបូង ខ្ញុំលើកអំពីគោលនយោបាយនៃការជម្លៀសប្រជាជនដោយបង្ខំ។

**ស៖** ក្នុងអំឡុងពេលដែលលោកនៅភូមិភាគពិសេស មុនឆ្នាំ១៩៧៥ ដូចដែលលោកបានជម្រាបជូនអង្គសវនាការកាលពីម្សិលមិញថា តើលោកបានដឹង ឬបានឃើញទេ មានប្រជាជនត្រូវបានគេជម្លៀសពីភូមិ ឬក៏តំបន់ផ្សេងៗទៀតទៅកាន់កន្លែងផ្សេងទៀតនៃតំបន់រំដោះហ្នឹងដែរទេ?

[១៣:៥៣:០០]

**ឆ៖** សូមនិយាយបញ្ហានេះ ជាពីរចំណែក។ ម្យ៉ាងទៀតគេអប់រំ ការអប់រំ ហើយបន្ទាប់មកទៀតនិយាយពីការឃើញ។

ការអប់រំ គេអប់រំនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត អំពីគុណប្រយោជន៍នៃការជម្លៀសប្រជាជនឲ្យផុតពីពេលដែលខ្មាំងបុកចូល នៅខាងបារាយណ៍។ ធ្វើឲ្យខ្មាំងវាលង់ គ្មានប្រជាជននៅក្បែរ វាលង់។ នេះគេនិយាយប៉ុណ្ណឹង។ ដល់ពេលខដុង្គឈ្នះ ដូចខ្ញុំបានជម្រាបពីព្រឹកអ៊ីចឹង មេខ្ញុំបញ្ជាឲ្យ ម-១៣ នេះបញ្ជូនមនុស្សមួយចំនួនទៅពោធិ៍សាត់ ហើយខ្ញុំយកភស្ដុតាងអ្នកដែលខ្ញុំបញ្ជូនទៅដែរហ្នឹង គឺសាក្សី KW-30។ ដូច្នេះខ្ញុំឃើញរឿងជម្លៀសប្រជាជនហ្នឹងតាំងពីនុំងមក។

**ស៖** តាមអ្វីដែលលោកដឹង ថាតើប្រជាជនដែលគេជម្លៀសហ្នឹងមានជម្រើសក្នុងការមិនចាកចេញពីភូមិ ឬក៏ពីកសិដ្ឋានរបស់ខ្លួនដែរទេ?

[១៣:៥៤:០៧]

**ឆ៖** ផ្សារខដុង្គគ្មានកសិដ្ឋានទេ ប៉ុន្តែប្រជាជនទាំងអស់មិនអាចបដិសេធនៅក្រាញនៅនុំងបានទេ ត្រូវតែទៅ។

**ស៖** តើលោកដឹងបញ្ហានេះដោយរបៀបណាដែរ?

**ឆ៖** ចុះបើឡានគេមកចាំយកពួកនែ៎! មនុស្សមួយចំនួនចេញពី ម-១៣ ទៅពោធិ៍សាត់។ មេបញ្ជាឲ្យយកអ្នកនេះខ្លះ អ្នកនោះខ្លះៗទៅពោធិ៍សាត់។ សុន សេន គាត់បញ្ជា ហើយក្នុងហ្នឹងមានដោយទាំងមនុស្សម្នាក់គឺ KW-30 ហ្នឹង។

**ស៖** តាមអ្វីដែលលោកបានដឹងថា តើមានអ្វីកើតឡើងចំពោះអ្នកដែលមិនព្រមចាកចេញនោះដែលបក្សកុម្មុយនីស្ដកម្ពុជាបានរៀបចំកន្លែងទុក ដើម្បីឲ្យពួកគេទៅហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងទេ ជាក់ស្ដែងមិនដឹង ហើយក៏មិនបានតាមដានសួរព័ត៌មានពីបញ្ហាហ្នឹងដែរ។

**ស៖** តើលោកដឹងទេ ថានៅ-- តើលោកដឹងទេនៅនោះ តើគោលនយោបាយនេះត្រូវបានបន្តអនុវត្តការជម្លៀសហ្នឹងរហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើដឹងទេ?

**ឆ៖** មុនដំបូងខ្ញុំឃើញ ក្រោយ១៧ មេសា បន្តិច បួនប្រាំថ្ងៃខ្ញុំឃើញប្រជាជនទៅរពុយ។ ខ្ញុំស្មានថា មានអ្នកស្ម័គ្រចិត្តទៅភូមិកំណើតរបស់ខ្លួនវិញ ដល់ក្រោយមកចូលមកដល់ភ្នំពេញអស់រលីង។ ហើយក៏ក្ដាប់បានព័ត៌មានខ្លះដែរនៅពេលនោះ ថាប្រជាជនជម្លៀសត្រូវគេសម្រិតសម្រាំង បែងចែក ហើយយកទៅសម្រិតសម្រាំង កន្លែងបែងចែក គឺនៅវត្តកន្សែងសំ។ វត្តធំបំផុតមួយរបស់ស្រុកអមលាំងពីមុន អំ ស្រុកថ្ពងពីមុន។ ហើយរណ្ដៅកប់សាកសពពួកជនជម្លៀសនៅក្បែរវត្តកន្សែងសំនុំង។

[១៣:៥៦:៣៣]

**ស៖** ខ្ញុំឮលោកប្រើពាក្យថា "សម្រិតសម្រាំង" តើមានន័យយ៉ាងណាដែរពាក្យថា "សម្រិតសម្រាំង" ហ្នឹង?

**ឆ៖** សម្រិតសម្រាំង គឺចាប់យកសមាសភាពមួយចំនួនណាដែលគេមិនជឿទុកចិត្ត យកទៅកម្ទេច។

**ស៖** តាមអ្វីដែលលោកដឹងនៅពេលនោះ ថាតើគេបានរៀបចំ និងបង្កើតគោលនយោបាយនេះជាដំបូងគេ? នៅពេលណា? ហើយអ្នកណាជាអ្នកបង្កើត?

**ឆ៖** ឲ្យដឹងច្បាស់ គឺអត់ទេ។ ក៏ប៉ុន្តែមិនជឿថា អ្នកខាងក្រោមខាងធ្វើទេ។ គឺលេខា និងអនុលេខាបក្សហ្នឹងតែម្ដងជាអ្នកសម្រេច។

[១៣:៥៧:២៤]

**ស៖** បាទ អរគុណ។ នៅមុនពេលដែលលោកមកដល់ទីក្រុងភ្នំពេញ ក្នុងខែមិថុនា ឆ្នាំ១៩៧៥ តើលោកបានដឹងជាមុនទេ ថាទីក្រុងត្រូវបានគេជម្លៀស?

**ឆ៖** ខ្ញុំមិនស្មានថាទាំងអស់ទេ ដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង មិនស្មានតែទាំងអស់ទេ។ ចូលមកដល់អស់ នៅសល់តែយុទ្ធជន យុទ្ធនារី។

**ស៖** ចុះលោកបានដឹងពីគម្រោងនៃការជម្លៀសនេះដែរទេ?

**ឆ៖** អត់ដឹងទេ អត់បានដឹងទេ។

**ស៖** ចុះមូលហេតុវិញ? តើលោកដឹងទេ?

**ឆ៖** មូលហេតុនៃជម្លៀស មិនច្បាស់។ គ្រាន់តែក្រោយមកក្ដាប់បាន ពេលដែលខ្ញុំបើកវគ្គរៀនសូត្រឲ្យពួក-- អ្អេ! ពេលបើកវគ្គរៀនសូត្រអី គេផ្លងជីវទស្សន៍ឲ្យពួក ស-២១ ដែលមានកំណើតនៅខាង៧០៣។ ពួកនោះពាក់ព័ន្ធទៅពេលដែលជម្លៀសប្រជាជនទុំង ចេញពីភ្នំពេញហ្នឹងចេញពីភ្នំពេញហ្នឹងមានប្រើហិង្សា។ គ្រាន់តែដឹងប៉ុណ្ណឹង។

**ស៖** ចុះនៅតាមរយៈដែលលោកបានស្នាក់នៅជាមួយមេដឹកនាំកម្មាភិបាល ឬក៏មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅអំឡុងពេលដែលលោកស្នាក់នៅស្ថានីយរថភ្លើង តើលោកមានដឹងព័ត៌មានអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះដែរទេ?

[១៣:៥៩:២៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្ដងទៀត ពីរឿងខ្ញុំស្នាក់នៅស្ថានីយរថភ្លើង។ ស្ថានីយរថភ្លើងនេះ វាមិនមែន

ជាផ្ទះដែលមេខ្ញុំគាត់សម្រាន្ត គាត់ស្នាក់នៅធ្វើការងារទេ។ ជាកន្លែងទទួលភ្ញៀវរបស់សេនាធិការ។ ដូច្នេះគ្មានពេលនឹងជួបគាត់ញឹកញាប់ទេ ទាល់តែគាត់ចង់ឲ្យជួប បានៗគាត់អញ្ជើញមកជួប។

**ស៖** គាត់នៅ-- តើលោកមានដឹងទេថា នរណាគេជាអ្នកអនុវត្តឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហ្នឹង? ហើយតើលោកឃើញដូចម្ដេចដែរពេលហ្នឹង?

**ឆ៖** ខ្ញុំអត់មានឃើញ អត់មានដឹងអីទេ ក៏ប៉ុន្តែចូលមកដល់អស់រលីង។ ក៏ប៉ុន្តែអ្នកចូលមកដល់ក្រុងភ្នំពេញមុនគេគឺយោធា។

**ស៖** អ៊ីចឹងនៅពេលដែលលោកមកដល់ទីក្រុងភ្នំពេញវិញគឺអស់តែម្ដង សូម្បីតែទាហាន លន់ នល់ ឬក៏មន្ត្រីរបស់សាធារណរដ្ឋ លន់ នល់ ក៏អត់មានដែរ?

**ឆ៖** អត់មានទេ។ ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិច កម្មករក៏ជម្លៀសទៅដែរ ក៏ប៉ុន្តែបក្សឲ្យ ចេង អន ទៅប្រមូលកម្មករចូលមកភ្នំពេញវិញ មកប្រកបការងារ បម្រើការងារនៅរោងចក្រវិញ។ ប្រមូលចប់នៅថ្ងៃ៣១ ខែឧសភា ឆ្នាំ១៩៧៥។

[១៤:០១:៥៣]

**ស៖** តើលោកមានដឹងទេថា មានអ្វីកើតឡើងចំពោះទាហាន ឬក៏មន្ត្រីសាធារណរដ្ឋខ្មែរហ្នឹងនៅពេលជម្លៀសនោះ តើមានអ្វីកើតឡើងដែរ ក្រោយឆ្នាំ៧៥ ឬក៏អំឡុងឆ្នាំ៧៥ នោះ?

**ឆ៖** ឯកសាររបស់កងពល១៣ សន្តិសុខកងពល១៣ ដែលទុកមកជាកេរដំណែលមកឲ្យស-២១ នេះ មានឃើញការចាប់ខ្សែ ឡុង បូរ៉េត ចាប់មន្ត្រីរាជការ ចាប់ទាហានចាប់អីច្រើន។ ពួកនុំងសុទ្ធបញ្ជីកម្មេច សុទ្ធតែពួកនុំង។ ដូច្នេះ វាច្បាស់ណាស់ថា គេប្រមូលពួកនុំងយកទៅកម្ទេច។

**ស៖** មុននេះបន្តិចលោកបានជម្រាបជូនអង្គសវនាការថា លោកត្រូវបានគេប្រាប់នៅឯមន្ទីរ ស-២១ ថាប្រជាជនត្រូវបានគេជម្លៀសដោយបង្ខំ។ សូមលោករៀបរាប់អំពីបញ្ហាទាំងនេះ?

**ឆ៖** នៅពេលដែលរៀនវគ្គដំបូងហ្នឹង ដល់ចេញពីវគ្គទៅ ខ្ញុំ ហើយនិងមិត្ត សុខ ក្រុងភ្នំពេញប្រធានកម្លាំងបង្កប់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្រុងភ្នំពេញនេះ ដឹកនាំធ្វើជីវទស្សន៍ មួយខ្សែរបស់ ស-២១ កងពល៧០៣ មួយទៀត ខ្សែរបស់ក្រុងភ្នំពេញ។ ខ្ញុំដឹកនាំធ្វើជីវទស្សន៍ជាមួយមិត្ត សុខ។ នៅពេលពាក់ព័ន្ធហ្នឹងហើយដែល ស៊ឹម ម៉ែល ហៅ ម៉ាន នុំងគាត់ពាក់ព័ន្ធ អំពីគាត់ប្រើហិង្សាទៅលើប្រជាជននៅពេលជម្លៀស ដេញមិនចេញៗបាញ់បញ្ឆិតពីលើក្បាល។ គាត់ប៉ានពាក់ព័ន្ធត្រឹមតែប៉ុននុំងបាញ់បញ្ឆិតទៅលើក្បាល។ ក៏ប៉ុន្តែទន្ទឹមនុំង សូមសង្កេតមួយទៀត កងពល៧០៣របស់ខ្ញុំហ្នឹង និយាយ

អំពីកងឈ្លបពិសេសរបស់ លន់ នល់ ដឹកនាំដោយ ហែម កេតដារ៉ា ទម្លាក់គ្រាប់បែកពីលើផ្ទះមក មកកម្ទេចកងពល៧០៣ៗ ដេញទៅចាប់ រឹបអូសបានអាវុធដូចជាបីឡានៗកង់បួន ដូច្នេះវាមានព្រឹត្តការណ៍ហ្នឹង។ ក៏ប៉ុន្តែព្រឹត្តការណ៍ដែលគួរតែនិយាយគឺ យុទ្ធជនរបស់បក្សកុម្មុយនីស្តកម្ពុជាជម្លៀសប្រជាជនដោយប្រើអំពើហិង្សា។ ហើយការដែលខ្ញុំខំលើកពីរឿងកងកុម្ម៉ង់ដូពិសេសរបស់ ហែម កេតដារ៉ា នេះ។ គ្រាន់តែចង់បញ្ជាក់ថា ជម្លៀសប្រជាជនវាអត់រណបនឹងសភាពការណ៍កងកុម្ម៉ង់ដូពិសេសរបស់ ហែម កេតដារ៉ា ហ្នឹងទេ វាដាច់ដោយឡែកពីគ្នា។ នេះសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** តើនៅៗពេលដែលគេប្រាប់លោកនៅមន្ទីរស-២១ ហ្នឹង គេប្រាប់ថាមានបញ្ហាអ្វីខ្លះទៀតទេកើតឡើង ទាក់ទងនឹងការជម្លៀសហ្នឹង?

**ឆ៖** ក្រោយមកទៀត ប្រហែលជាក្នុងខែ១១ ពេលនោះ ខ្ញុំចូលកាន់ការជាអនុប្រធាន ខាងទទួលភារៈខាងសួរចម្លើយហើយ ដឹកនាំគេសួរចម្លើយ។ ឈ្មោះ យូ ប៉េងគ្រី ហៅ ម៉ុន នេះទៅខ្សឹបប្រាប់ខ្ញុំថា ណាត នេះជាមហាមនុស្សឈ្លាសវៃ សម្តេចសង្ឃ ហួត តាត បរាជិក និយាយត្រឹមតែប៉ុននុ៎ងហើយខ្ញុំដេញសួរចុះឡើងៗទៅ បានធ្លាយដំណឹងម្នាក់ទៀត គឺសាស្ត្រាចារ្យ ខៀវ កុមារ ពីដើមគាត់ជាសមាជិកបក្សម្នាក់ដែរ តែគេជម្លៀសតាមដងផ្លូវទៅ តាមផ្លូវលេខបួន។ នេះខ្ញុំដឹងអ៊ីចឹង ស៊ើបៗទៅដឹងអ៊ីចឹង។

[១៤:០៦:៤៧]

**ស៖** តើពេលនោះ គេមានប្រាប់លោកអំពីវិធីនៃការជម្លៀសថា តើយ៉ាងម៉េច អីយ៉ាងម៉េចដែរទេ?

**ឆ៖** ឮតែ ស៊ឹម ម៉ែល ហៅ ម៉ាន និយាយថា ពេលដែលដេញប្រជាជនឲ្យចេញហ្នឹង មិនមែនមិនដឹងសោះទេ គេថាចេញៗអាមេរិកាំង។ គេនិយាយអ៊ីចឹង ហ្នឹងមែន។ អ្នកណាមិនចេញ ស៊ឹម ម៉ែល ថាគេ-- ខ្ញុំបាញ់ បង ខ្ញុំបាញ់។ ខ្ញុំសូមបញ្ជាក់បន្ថែមមួយម៉ាត់ទៀត ជម្លៀសប្រជាជនឯកសារមានហើយ ជាផែនការត្រៀមឈ្នះរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯចំណែកកងកុម្ម៉ង់ដូរពិសេសរបស់ ហែម កេតដារ៉ា ជាផែនការត្រៀមចាញ់របស់ លន់ នល់។ បានជាខ្ញុំនិយាយថា ដាច់ពីគ្នា មិនរណបគ្នាទេ។

**ស៖** តើនៅពេលនោះ គេមានប្រាប់លោកទេ ថាមានអ្វីកើតឡើងចំពោះអ្នកដែលគេអត់ព្រមចេញតាមបញ្ជានុ៎ង?

**ឆ៖** ដូចអត់មានអ្នកណានិយាយទេ គ្មានទេ។ ខ្ញុំមិនបានដេញដោលសួរ តែក៏គ្មាននរណាបាន

និយាយប្រាប់ខ្ញុំដែរ មានតែម្នាក់គត់ គឺ យូ ប៉េងគ្រី ហ្នឹងនិយាយខ្សឹបប្រាប់ខ្ញុំពីសម្តេចសង្ឃ ហួត តាត មានប្រពន្ធប្អូន។

[១៤:០៨:២២]

**ស៖** ទាក់ទងទៅនឹងការជម្លៀសនេះដែរ តើនៅពេលនោះ លោកមានបានដឹងទេថា ឧទាហរណ៍ ដូចជាមាននៅ មនុស្សដែលនៅមន្ទីរពេទ្យ តើគេជម្លៀសដែរ ឬក៏គេទុកឲ្យនៅទីនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ ចូលមកដល់ភ្នំពេញថ្ងៃ២០ ៗទៅហើយ ហើយខ្ញុំចូលទៅរៀន មកដល់ភ្លាម រៀបចំខ្លួនហើយ ចូលទៅរៀន។

**ស៖** តើលោកបានដឹងអំពីថា តើគេអនុញ្ញាតឲ្យអ្នកដែលត្រូវគេជម្លៀសនុំងត្រឡប់មកភ្នំពេញវិញដែរទេ?

**ឆ៖** គ្មានទេៗ មានតែកម្មករ ដែលបក្សឲ្យ ចេង អន ដើរទៅដឹកប្រមូលកម្មករយកមកចូលរោងចក្រវិញ។

**ស៖** ចុះលោកដឹងទេថាមានអ្វីកើតឡើង បើសិនជាពួកគេត្រូវត្រឡប់មកវិញដោយគ្មានការអនុញ្ញាតនោះ?

**ឆ៖** មិនដឹងទេ ខ្ញុំមិននិយាយស្មានទេ ប៉ុនមិននិយាយឲ្យចំគឺថាមិនដឹងតែម្តង។

[១៤:០៩:៤៦]

**ស៖** នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យតើលោកបានដឹងទេថា មូលហេតុអំពីនៃការជម្លៀសនៅពេលនោះ តើមូលហេតុអីដែរ?

**ឆ៖** អត់បានគិត អត់បានពិចារណាទេ។ និយាយឲ្យចំពោះពេលនុំង គឺអត់បានគិត អត់បានពិចារណាទេ។ រហូតមកដល់ ៧មករា ហើយក៏ខ្ញុំមិនទាន់បានពិចារណាបញ្ហាហ្នឹងដែរ។

**ស៖** តើមាន-- លោកមានដឹងទេថា ការជម្លៀសនុំង ប្រើអស់រយៈពេលប៉ុន្មានដែរ នៅពេលនុំង លោកដឹងទេ?

**ឆ៖** ខ្ញុំមិនដឹងទេ។

**ស៖** ចុះ លោកបានដឹងអំពីថាតើមូលហេតុក្រៅពីលោកនិយាយអំមិញថា មានការទម្លាក់គ្រាប់បែក តើមានមូលហេតុអីផ្សេងទៀតទេ ដែលគេតម្រូវប្រជាជនចាកចេញពីទីក្រុងភ្នំពេញ?

**ឆ៖** មូលហេតុទម្លាក់គ្រាប់បែកហ្នឹង ជាមូលហេតុប្រឌិដ្ឋករទេណា។ វាមិនដឹងជាប្រឌិដ្ឋរឿង

អីទៀត។ ប៉ុន្តែមូលហេតុសំខាន់មក ដែលគេប្រឌិដ្ឋនេះគឺអាមេរិកទម្លាក់គ្រាប់បែក។ ចេញសិន១ ពីរបី ថ្ងៃទៀត ត្រឡប់មកវិញ ហ្នឹងគឺជាមូលហេតុដែលគេប្រឌិដ្ឋភរ។

**ស៖** ចុះ លោកមានដឹងមូលហេតុពិតប្រាកដដែរទេ?

[១៤:១១:១៦]

**ឆ៖** ខ្ញុំមិនដឹង។ ជម្រាបត្រង់ មិនដឹង ៗថាផែនការត្រៀមឈ្នះ នេះអ៊ីចឹង អត់ទេ។ ទោះបីជាឯកសាររៀន ថានេះជាផែនការត្រៀមឈ្នះរបស់យើង គឺជម្លៀសប្រជាជន ហើយនិងនាំពួកជនបរទេសឲ្យចេញទៅក្រៅប្រទេស មានសរសេរនៅក្នុងឯកសារ នៅក្នុងឯកសារ ក.ណ.ហ អំមិញ ១៦៦ ហ្នឹងមើលទៅឃើញហើយ។ ក៏មិនជាបានគិត ជាចាក់ជម្រៅ ដឹងហើយយើងឈ្នះ យើងឈានដល់ទៅបដិវត្តន៍សង្គមនិយមហើយ។

**ស៖** បាទ អរគុណ។ អ៊ីចឹង បានន័យថា តើការជម្លៀសហ្នឹង មានផែនការគ្រោងទុកជាមុនដែរទេ លោកដឹងទេ បញ្ហាហ្នឹង?

**ឆ៖** គ្រោងទុកមិនមាន ខ្ញុំមិនដឹងទេ។ ប៉ុន្តែគេពិតជាគ្រោងទុក ឯកសារហ្នឹងបញ្ជាក់ច្បាស់។ តែមិនមែនជាចៃដន្យទេ គឺជាការគ្រោងទុកជាផែនការ ត្រៀមឈ្នះរបស់យើង។

**ស៖** ទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំ ដែលកើតឡើងនៅកន្លែងផ្សេង១ នៃកម្ពុជាបន្ទាប់ពីជម្លៀសទីក្រុងភ្នំពេញ។ តើលោកបានដឹងអ្វី ទាក់ទងទៅនឹងការជម្លៀសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកដឹង បានដឹងអ្វីផ្សេងទៀតដែរទេ ទាក់ទងការជម្លៀសហ្នឹង?

[១៤:១៣:០៤]

**ឆ៖** ខ្ញុំមិនដឹងទេ ជម្រាបដោយត្រង់។ ក្រោយមក បានឃើញឯកសារមួយ គឺសារលេខ១៥ របស់ សោ ភឹម សរសេរមក ប៉ុល ពត និង នួន ជា អំពីបញ្ហាជម្លៀសប្រជាជនចេញពីដងទន្លេ ហើយនិងតាមព្រំដែន។

**ស៖** តើឯកសារនុ៎ងនិយាយអ្វីខ្លះទៀតទៅ? ហើយឯកសារនោះ លោកឃើញនៅពេលណាដែរ?

**ឆ៖** ឃើញនៅពេលសវនាការនេះ។ នៅសវនាការសំណុំរឿងលេខ០០១។

**ស៖** ចុះ នៅពេលដែល-- នៅតាមដែលលោកដឹងនៅពេលនោះ។ តើលោកដឹងទេថា ប្រជាជនដែលត្រូវគេជម្លៀសហ្នឹង គឺជម្លៀសទៅខាងណាដែរ? ទៅភូមិភាគណា? ទៅផ្នែកណាមួយនៃប្រទេស

កម្ពុជា?

**ឆ៖** ខ្ញុំឃើញជម្លៀសទៅ ដូចទាំងអស់ គ្រប់ទិសទីតែម្ដង។ ខ្ញុំសូមរំឭករឿងមួយ មិត្តភក្តិខ្ញុំដែលរៀនជាមួយគ្នានោះ ខ្ញុំជិះកង់ជួប ត្រូវគេជម្លៀសបែកប្រពន្ធ។ ជួបខ្ញុំយំរហាម ប្រពន្ធទៅផ្សេង វាទៅផ្សេង។ ដល់ក្រោយមក ខ្ញុំស៊ើបដំណឹងពីរឿងលោកគ្រូ ខៀវ កុមារ គាត់ជាអតីតបក្ខជនម្នាក់ឆ្លាតស្លូត។ ដឹងថា គេជម្លៀសទៅតាមផ្លូវលេខ៤ ដូច្នេះ មិនធ្លាក់ទៅបស្ចិម គឺធ្លាក់ទៅនិរតី។ គាត់ស្លាប់ហើយ។ ដូចបាត់ដំណឹងគាត់រហូត។ ដូច្នេះ សរុបមកវិញ ជម្លៀសហ្នឹងមិនកំណត់ ទៅគ្រប់ទិសទី។

[១៤:១៥:០២]

**ស៖** តើលោកដឹងដោយរបៀបណាថាមានការជម្លៀសប្រជាជនទៅគ្រប់ទិសទីហ្នឹង?

**ឆ៖** ដូចខ្ញុំរាយការណ៍ជម្រាបលោកសហព្រះរាជអាជ្ញាអំមិញអ៊ីចឹង ឃើញជាក់ស្ដែងជួបពីរនាក់មួយតាមផ្លូវលេខ៥ ឧដុង្គ។ មួយទៀត ខ្ញុំស៊ើបដំណឹងទៅ ដឹងថាលោកគ្រូ ខៀវ កុមារ ទៅតាមផ្លូវលេខ៤។

**ស៖** តើលោកដឹងថាមានការជម្លៀសពីភូមិភាគកណ្ដាល និងភូមិភាគនិរតីទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យទេនៅចន្លោះឆ្នាំ៧៥ និង៧៦ហ្នឹង លោកមានដឹងទេ?

**ឆ៖** មិនដឹងទេ។

**ស៖** នៅពេលនោះ តើលោកដឹងទេថា --

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមជំទាស់ប្រហែលជាមួយនាទីទេ។ ខ្ញុំមិនចង់ជំទាស់ទេ។ ខ្ញុំមិនពេញចិត្តធ្វើដូច្នេះទេ ប៉ុន្តែការសួរនេះគឺថាច្បាស់ហើយថា សហព្រះរាជអាជ្ញាគឺគាត់ហាក់បីដូចជាសួរគឺដោយនាំមុខដើម្បីចង់បានចម្លើយតែម្ដង។ ហើយព័ត៌មានដែលគាត់ដឹងនោះ គឺថាគាត់បានផ្ដល់នាំមុខដល់-- ចម្លើយចុងក្រោយជាឧទាហរណ៍ច្បាស់ហើយ។ ខ្ញុំមិនដឹងថាវានឹងបង្ហាញដល់ការពិតយ៉ាងម៉េចនោះទេ ក៏ប៉ុន្តែគាត់បាននិយាយយ៉ាងវែងអំពីការជម្លៀសប្រជាជន រួចហើយគាត់សួរសំណួរនាំមុខដើម្បីធ្វើម៉េចមិនឲ្យមានការឆ្លើយថាទេ ឬក៏អីពីជន ពីសាក្សីនោះទេ។

[១៤:១៦:៥៣]

ដូច្នេះ ខ្ញុំសូមជំទាស់ការសួររបៀបនេះ គាត់អាចសួរសំណួរដែលងាយៗ។ គាត់កំពុងតែសួរនាំមុខសាក្សីហើយ ដោយបានបង្ហាញថាតើនៅទីណា? ពេលណា? អ្វី? ហើយអ្នកឯងដឹងអី? ដឹងដោយ

របៀបណា? រួចបន្ទាប់មកគឺថា គាត់លោកដឹងថាគេជម្លៀសប្រជាជនពីតំបន់នេះទៅតំបន់នេះទេ? សំណួរបែបនេះ គឺជាការសំណួរហាក់បីដូចចិញ្ចឹមសាក្សី។ មានន័យថា សំណួរចង់ដៅនាំមុខបានចម្លើយពីសាក្សីតែម្តង។ អ៊ីចឹងក្នុងករណីបែបនេះ គឺថាខ្ញុំ-- ហើយខ្ញុំក៏យល់ឃើញថា ឯកសារនេះក៏ដូចជាយើងកំពុងតែអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល។ ដូច្នេះ គួរតែសួរតែអ្វីដែលគាត់បានដឹង និងជួបប្រទះពិតប្រាកដ មិនសួរអ្វីដែលគាត់បានដឹងអំពីការអាននោះទេ។ ដូច្នេះខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ។

សូមអរគុណ។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន។ ឥឡូវខ្ញុំសូមសួរសំណួរឡើងវិញ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើលោកបានដឹងទេថា-- សូមលោករៀបរាប់អំពីការជម្លៀសប្រជាជនដែលទៅគ្រប់ទិសទីហ្នឹង តើយ៉ាងម៉េចខ្លះដែរ?

**ឆ៖** ដូចខ្ញុំរាយការណ៍ជូនលោកសហព្រះរាជអាជ្ញាហើយ ដែលខ្ញុំបានឃើញ គឺអង្កាល់ដែលខ្ញុំនៅអមលាំង ខ្ញុំឃើញមនុស្សទៅរពុយៗ ហើយមានកន្លែងគេសម្រិតសម្រាំងបែងចែកយកមួយចំនួនទៅកម្ទេច យកមួយចំនួនទៀតបញ្ចូលក្នុងសហករណ៍។ ខ្ញុំយល់សភាពការណ៍នេះ វាមិនមែនកើតឡើងនៅតែអមលាំងទេ។ រឿងអីក៏ដោយ ប្រតិបត្តិមួយកន្លែងវាមានលក្ខណៈទូទៅ។ ទីពីរទៀត ដោយមនោសញ្ចេតនារបស់ខ្ញុំចំពោះលោក ខៀវ កុមារ ខ្ញុំចេះតែតាមដានសួរដឹងរឿង ដឹងវ៉ាវគេជម្លៀសគាត់ទៅតាមផ្លូវលេខ៤។

[១៤:១៩:០៨]

ហើយមួយរឿងទៀតពួកម៉ាកខ្ញុំ ត្រូវគេជម្លៀសបែកប្រពន្ធ។ ពួកម៉ាកខ្ញុំហ្នឹងគាត់រៀនបានជាប់លីស្សង់ខាងគីមី ហើយដល់ទៅជម្លៀសបែកប្រពន្ធជួបខ្ញុំតាមផ្លូវពី ណ៎ែ! នេះតាមផ្លូវលេខ៥ ជិតឧដុង្គ។ ពេលនោះខ្ញុំចេញពីអមលាំងមក។ ដូច្នេះវាៗគ្រប់ទិសទី គឺដោយសារខ្ញុំឃើញបញ្ហានេះ។

**ស៖** បន្ទាប់ពីការចាកចេញរបស់ប្រជាជននៅទីក្រុងភ្នំពេញ តើលោកបានដឹងអំពីការជម្លៀសប្រជាជនទៅផ្នែកផ្សេងៗទៀតដែរឬទេ?

**ឆ៖** ជម្លៀសប្រជាជនចេញពីកំពង់ធំ ខ្ញុំមានព័ត៌មានខ្លះពីប្អូនថ្លៃខ្ញុំដែលធ្វើការងារនៅទីនោះឈ្មោះ កៅលី ថុងហួត។ វាមកជាប់នៅនឹង ស-២១ ដែរ វាប្រាប់ខ្ញុំពីការជម្លៀសនៅក្រុងកំពង់ធំ ចេញ

ទៅជនបទ។ នេះខ្ញុំដឹងច្បាស់លាស់។

**ស៖** តើលោកអាចជម្រាបបានទេថា តើគាត់និយាយពីអ្វីខ្លះ?

**ឆ៖** និយាយអំពីការជម្លៀសហ្នឹង គេមានបែងចែកហើយស្រេច។ អ្នកណាដែលគេឲ្យជិះឡាន គឺគេយកទៅកម្ទេច។ អ្នកណាដែលគេឲ្យដើរ គឺអ្នកនុំងរស់ ប្រភេទមនុស្សដែលគេទុកឲ្យរស់។ និយាយប៉ុណ្ណឹង។

[១៤:២១:០៣]

**ស៖** តើលោកមានដឹងទេថា ប្រជាជនប្រភេទណាខ្លះដែលមានក្នុងការជម្លៀសហ្នឹង?

**ឆ៖** អានេះនិយាយជាការវិភាគ ជាការសរុបតាមការយល់ឃើញទេ--

**ស៖** សូមៗ! កាត់លោកបន្តិចថា សូមលោកឆ្លើយនូវអ្វីដែលលោកបានដឹង បាទ។

**ឆ៖** យើងនិយាយពីដឹង ដឹងយ៉ាងម៉េច? ដឹងដោយសារឯកសារនៅ ស-២១ ដែលគេកម្ទេច។ ដឹងដោយសារមនុស្សអស់ចេញពីភ្នំពេញ ដូច្នេះមនុស្សទាំងអស់ត្រូវតែជម្លៀស។

**ស៖** តើលោកបានដឹងទេ នៅពេលហ្នឹងថាហេតុអីបានជាមានការជម្លៀសនុំង?

**ឆ៖** មូលហេតុដែលជម្លៀស គេមិនប្រាប់យើងទេ។ ក្នុងឯកសារដែលខុទ្ទេសនាម គេថានេះជាផែនការត្រៀមឈ្នះ។ បដិវត្តន៍យើងលោតផ្លោះ រំលងបដិវត្តន៍ប្រជាធិបតេយ្យចូលដល់បដិវត្តន៍សង្គមនិយម។

**ស៖** ចុះលោកដឹងទេថា គេជម្លៀសហ្នឹង ជម្លៀសយកទៅខាងណាដែរ?

**ឆ៖** ជម្លៀសនេះតាមពិត គឺយកទៅជនបទ។ ហើយឯកសារដែលខុទ្ទេសនាមជំនាន់នុំង គឺប្រជាជនថ្មី ទៅនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនចាស់។ ឯកសារ ក.ណ.ហ ដែលខ្ញុំនិយាយហ្នឹងមានចារទុកហើយ បទខុទ្ទេសនាមជំនាន់នុំង។ ចំណងជើងឯកសារទីមួយហ្នឹងឈ្មោះថា "វិភាគជ័យជម្នះរបស់យើង"។ ពិនិត្យជ័យជម្នះរបស់យើង។ បង ម៉ម ណៃ គាត់សរសេរពាក្យហើយ គាត់ចុច។ នេះជាភស្តុតាងនៃការដែលខ្ញុំនិយាយនេះ។

**ស៖** ចុះលោកបានដឹងទេថា តើគេជម្លៀសហ្នឹង ជម្លៀសធ្វើយ៉ាងម៉េចទៅ?

**ឆ៖** ដេញឲ្យដើរ ដេញប្រជាជនឲ្យដើរ រែកពន់ស្អីៗទៅរប៉ាត់រប៉ាយទៅ។

**ស៖** តើមាន-- លោកបានដឹងទេថាមានកម្មាភិបាលរបស់ខ្មែរក្រហមហ្នឹង ដើរតាមឬក៏យ៉ាងណាដែរ?

**ផ៖** មិនច្បាស់ទេ ក៏ប៉ុនអាចចៀសមិនរួចពីយុទ្ធជនខ្លះទៅតាមទេ ចៀសពុំរួចទេ។ ដេញថែម អីថែម ដែលណែនាំទៅ ចៀសមិនរួច។ ក៏ប៉ុន្តែបើឲ្យឃើញ ឲ្យដឹងឮគេនិយាយ ខ្ញុំអត់បានដេញដោល សួរល្អិតរឿងហ្នឹងទេ។ ប៉ុន្តែនិយាយថាឲ្យចៀស គឺចៀសមិនរួចទេ។

**ស៖** ចុះគេមានប្រាប់ដែរទេថា ប្រជាជនដែលត្រូវជម្លៀសចេញហ្នឹង អាចទៅកាន់ទីកន្លែងណា ដែលពួកគេចង់ទៅបានដែរទេ?

**ផ៖** មិនច្បាស់ទេ មិនដឹងទេ។ ប៉ុន្តែរឿងដែលចង់ទៅហ្នឹង ឥឡូវខ្ញុំសូមលើកឧទាហរណ៍ ពួកម៉ាកខ្ញុំមួយមកទៀតចុះ គ្នាប្រហែលស្លាប់ហើយ ឈ្មោះ អៀ សៀងចេង។ បែកប្រពន្ធ ចង់រត់មក តាមរកប្រពន្ធវិញ ខ្ញុំអង្វរថា កុំអាលអ្ហា! ជួយធ្វើស្រែឲ្យបានស្រូវស៊ីសិន ដល់បានស្រូវដាក់ជង្រុកហើយ សឹមអ្នែងសុំច្បាប់គេទៅតាមរកប្រពន្ធ។ ដូច្នេះ វាមិនមែនបានតាមចិត្តយើងដែលចង់ទៅនេះ ចង់ទៅ នោះទេ។ ដូច្នេះសភាពការណ៍ហ្នឹង វាបញ្ជាក់អ៊ីចឹង។

**ស៖** តាមអ្វីដែលលោកបញ្ជាក់អំមិញហ្នឹង គឺមានន័យថា តើគេអនុញ្ញាតឲ្យមានអ្នកដែល ជម្លៀសហ្នឹងទៅជាក្រុមជាមួយក្រុមគ្រួសាររបស់គេ ឬក៏អត់ទេ?

**ផ៖** អត់ទេ បែកប្រពន្ធ បែកកូន ពួកម៉ាកខ្ញុំវាបែកប្រពន្ធវា បែកកូនវា។ វាទាំងពីរនាក់ជា សាស្ត្រាចារ្យមធ្យមសិក្សាមធ្យមភូមិ។ ដល់ជម្លៀសពេលនុ៎ង វាអត់នៅផ្ទះ គេជម្លៀសប្រពន្ធទៅបាត់ វា មកដល់គេជម្លៀសវាទៅទិសផ្សេង។

**ស៖** ចុះលោកដឹងដែរទេថាចំពោះការជម្លៀសហ្នឹងមានអ្នកចាំទទួល ឬក៏អីដែរទេនៅពេលនុ៎ង?

[១៤:២៥:៥៧]

**ផ៖** បើយើងយកសភាពការណ៍អមលាំងមកវិភាគ យើងឃើញជម្លៀសហ្នឹងទៅដល់អមលាំង នុ៎ង បានគេប្រមូលកត់ឈ្មោះ សួរអំពីមុខរបរ ហើយគេចែក។ ដូច្នេះ អាចជាគេមាននាំមុខទៅ មួយចំនួននេះទៅត្រង់នេះ មួយនោះទៅត្រង់នោះ។ យើងយកតែបញ្ហាមួយហ្នឹងមកគិត យើងអាចយល់ បានថាអ៊ីចឹង។

**ស៖** អ្នកដែលទទួល តើអ្នកនុ៎ងមានការណែនាំពីណាមកទេ? លោកបានដឹងទេចំណុចហ្នឹង?

**ផ៖** ធម្មតាមិនដែលកម្មាភិបាលណាប៊ានធ្វើ ដោយគ្មានការណែនាំរបស់បក្សពីខាងលើទេ។ កម្មាភិបាលខាងក្រោមមិនដែលប៊ានធ្វើស្អីល្មើសនឹងការណែនាំពីខាងលើទេ។ តែប៊ានល្មើស ប៉ះពាល់ ដល់អាយុជីវិត បើបក្សខាងលើមិនសម្រេច កំបុតក។ នេះខ្ញុំសូមលើកឧទាហរណ៍មួយទៀត គឺ ណាត

ត្រូវបក្សសង្ស័យដោយសាររឿងគាត់ចាប់មនុស្សដោយគ្មានបញ្ជាពីលើ។

[១៤:២៧:១៩]

**សៈ** តើលោកបានដឹងទេថា នៅពេលដែលប្រជាជនដែលគេជម្លៀសនោះ ទៅដល់គោលដៅមួយហើយ គេយកទៅធ្វើអ្វីទៀត? យកទៅត្រង់ណា? ដាក់ធ្វើអីទៀត តទៀត?

**ឆះ** ខ្ញុំបានជម្រាបហើយ អ៎! ខ្ញុំបាននិយាយរួចហើយ។ នៅក្នុងសិក្ខាកថារបស់ខ្ញុំថា ប្រជាជននៅពេលជម្លៀសហ្នឹង វាមានចលនាកម្មេច។ ក្រោយពីកម្មេច គេយកប្រជាជនថ្មីហ្នឹងទៅដាក់ឲ្យនៅក្នុងសហករណ៍ ក្រោមការគ្រប់គ្រងរបស់ប្រជាជនចាស់។ ទាំងអស់គ្នាស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាបក្សសហករណ៍ ហើយធ្វើការបង្កបង្កើនផល លត់ដំខ្លួនតទៅ។ នេះវាមានដំណើរទៅអ៊ីចឹង។ ជំនាន់នោះវាមានលេចចេញពាក្យមួយម៉ាត់ "ប្រជាជន ១៧ មេសា" រឿងនេះប្រជាជនយើងនៅចងចាំ។ ពាក្យ "ប្រជាជន ១៧មេសា"ហ្នឹង គឺមកពីប្រជាជនថ្មីយើង គ្នាទៅនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនចាស់។

[១៤:២៨:៣១]

**សៈ** តើនៅពេលនុ៎ង លោកបានដឹងដែរទេថា តម្រូវការម្ហូបអាហារ ឬកម្លាំងពលកម្មហ្នឹង ប្រជាជនជម្លៀសហ្នឹងទទួលយ៉ាងម៉េចដែរ?

**ឆះ** ពេលជម្លៀស គឺខ្ញុំមិនដឹងទេ ពេលណាអត់បាយ ពេលណាដែល-- ប៉ុន្តែទៅដល់ទិសដៅបញ្ចូលទៅក្នុងសហករណ៍ហើយ របបហូបចុកមានការកំណត់ពីថ្នាក់ខាងលើ។ កម្លាំងលេខមួយ គឺក្នុងប្រជាជន មួយកំប៉ុងកន្លះ។ កម្លាំងកំពុង ស្រូច កំពុងរើសម្រុក ពីរកំប៉ុងម្នាក់។ ហើយពេលនោះ កុំនិយាយខ្ញុំមិនដឹងអីសោះ ខ្ញុំដឹង ម្តាយខ្ញុំគាត់អញ្ជើញមកភ្នំពេញ ខ្ញុំរាយការណ៍ប្រាប់មេថា "អ្នីបង! នៅខាងស្មោងឯណោះ គេបង្អត់បាយប្រជាជន"។ ដំបូងមេខ្ញុំគាត់ឆ្លើយថា "មកពីមិត្ត-- មកពីយើងចាប់ខ្មាំងវាមិនទាន់អស់ អាខ្មាំងហ្នឹងវាបង្អត់បាយប្រជាជន"។ ដល់ក្រោយពួកនិរតីទៀតទៅ ខ្ញុំរាយការណ៍ទៀត មេខ្ញុំមិននៅស្ងៀម មិនប៉ានឆ្លើយតាមទូរស័ព្ទមកខ្ញុំវិញ។ ខ្ញុំរាយការណ៍ទាំងពីរលើកតាមទូរស័ព្ទ។ នេះជាសភាពការណ៍ជាក់ស្តែងដែលខ្ញុំស្តាប់បាន ម្តាយខ្ញុំផ្ទាល់តែម្តង ហើយឯកសារខ្ញុំអានព្រឹកមិញជូន ហើយលេខប៉ុន្មានៗ ដែលកំណត់របបក្នុងកងទ័ពពីរកំប៉ុង។

**សៈ** បាទ អរគុណ។ តើលោកបានដឹងទេទាក់ទងទៅនឹងអំឡុងពេលនៃរបបកម្ពុជាប្រជាធិប-តេយ្យ ឬក៏មុនខែមេសា ឆ្នាំ១៩៧៥ ហ្នឹង តើបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានគោលនយោបាយអ្វីទាក់ទង

ទៅនឹងការធ្វើពលកម្ម ការដ្ឋានការងារអីដែរទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរទេ។

**ស៖** ខ្ញុំសួរឡើងវិញ។ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច ឬក៏មុនឆ្នាំ-- ខែមេសា ឆ្នាំ១៩៧៥ តើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមានអ្វីខ្លះដែលទាក់ទងទៅនឹងការដ្ឋានការងារ ឬក៏សហករណ៍ហ្នឹង?

[១៤:៣១:០៣]

**ឆ៖** ខ្ញុំបានជម្រាបហើយថា សហករណ៍ដំបូងគេធ្វើជាពិសោធនៅខាងព្រះវិហារ ឆ្នាំ១៩៧២ ដល់ក្រោយមកគេពង្រីកទូទាំងតំបន់រំដោះ ហ្នឹងជាសហករណ៍កម្រិតខ្ពស់នៅក្នុងតំបន់រំដោះតែម្តង។ ហើយសហករណ៍នេះ វាមានពន្លកវាតូចតាំងពីសម័យដំបូងតាំងពីឆ្នាំ១៩៥៦ ម្ល៉េះ មកពីក្រុមប្រវាស់ដៃ ហើយនិងសមាគមស្រូវ។ ហើយដល់ក្រោយ ១៧ មេសា នេះមានឯកសារមួយ ប៉ុន្តែឯកសារហ្នឹងខ្ញុំអត់ទាន់បានឃើញទេចុះ ថ្ងៃទី២០ ឧសភា ១៩៧៥។ ពង្វាតវិសាលភាពសហករណ៍កម្រិតខ្ពស់ហ្នឹងទូទាំងប្រទេស ដូច្នេះប្រជាជនជម្លៀសទៅបញ្ចូលទៅក្នុងសហករណ៍ហ្នឹងឯង។ ដូច្នេះទូទាំងប្រទេសធ្វើកម្លាំងពលកម្ម ធ្វើពលកម្មទាំងអស់គ្នា កម្មករក៏ធ្វើពលកម្ម កសិករក៏ធ្វើពលកម្ម យុទ្ធជនយុទ្ធនារីគាត់ធ្វើស្រែ។ ពួកកងទ័ពមជ្ឈិមធ្វើស្រែនៅជុំវិញភ្នំពេញ ទាំងគេទាំងខ្ញុំ ធ្វើស្រែទាំងអស់គ្នា។ ដូច្នេះ បញ្ហានយោបាយពលកម្ម គឺទៅអ៊ីចឹង។

**ស៖** យោងទៅតាមគោលនយោបាយនេះ តើលោកដឹងទេថា អ្នកណាជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិនៅក្នុងសហករណ៍?

**ឆ៖** លេខាសហករណ៍នេះ និយាយដោយឡែកក្នុងសហករណ៍នីមួយៗ គឺវាសាខាបក្សសហករណ៍។ វាដឹកនាំទាំងអស់ ទាំងឈ្លបភូមិឃុំ ទាំងបក្ខជន យុទ្ធជន ដឹកនាំសម្រុក ដើម្បីជំរុញការផលិតឲ្យស្ទុះលឿន គ្រប់ការងារសំខាន់ៗគេតែងចាត់តាំងយុវកក ឬបក្ខជនម្នាក់ឲ្យទៅចុះទៅជាប់។ នេះជាវិធានការទីមួយ។ វិធានការទីពីរ ពេលហ្នឹងគេផ្តល់របបជាកម្លាំងស្រួច ម្នាក់ម៉ៃពីរកំប៉ុង។

[១៤:៣៣:៣១]

ដូច្នេះ មានកម្មាភិបាលដែលចុះទៅជាប់។

**ស៖** បាទ អរគុណ។ បើប្រៀបធៀបជាមួយនឹងព្រៃស ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះ តើមានសហករណ៍ណាផ្សេងទៀតដែរលោក? លោកដឹងទេបញ្ហានេះ?

**ឆ៖** បើនិយាយអំពីព្រៃស រូបភាពបង្កបង្កើនផល វាជា ដូចគ្នានឹងសហករណ៍ ក៏ប៉ុន្តែបើនិយាយអំពីសមាសភាពនេះ វាមិនមែនជាប្រជាជនទេ វា-- គេហៅថាអនុប្រជាជន ពាក់កណ្ដាលប្រជាជន។ អ្នកឯងមិនសិទ្ធិកាន់អាវុធធ្វើកងទ័ពទេ មិនមានសិទ្ធិឡើងចូលយុវកក ឡើងចូលអីហ្នឹងគេទេ ដែលខំលត់ដំកសាងខ្លួន។ នេះនិយាយពីសិទ្ធិ។ ដូចគ្នានឹងប្រជាជនជម្លៀសទាំងអស់ដែរ ប្រជាជនជម្លៀសក៏អីចឹងដែរ។

**ស៖** តើលោកដឹងទេថា តើហេតុអីបានជាចាត់ទុកអីចឹង?

**ឆ៖** អ្ហឺ!អាហ្នឹងជាបុព្វហេតុរបស់បក្សហើយ បុព្វហេតុវណ្ណៈហើយ។ ហ្នឹងជាបុព្វហេតុវណ្ណៈហើយ។ យើងមើលនៅក្នុងលក្ខន្តិកៈ ប្រឆាំងបដិវត្តន៍អនុធន នាយទុន។ ដូច្នេះ នាយទុនសក្តិភូមិកុំឲ្យងើបក្បាលឡើងរួច គឺយកមនុស្សទៅលត់ដំនៅក្នុងសហករណ៍នេះឯង។ ឲ្យប្រជាជនចាស់គោរពគ្រប់គ្រងប្រជាជនថ្មី។

**ស៖** អីចឹងមានន័យថា អ្វីដែលលោករៀបរាប់អម្បាញ់មិញហ្នឹងគឺជា "បុព្វហេតុវណ្ណៈ" ឬក៏មានអ្វីផ្សេងពីទៀតដែរទេ ថាពាក្យថា "បុព្វហេតុវណ្ណៈ" ហ្នឹង?

**ឆ៖** "បុព្វហេតុវណ្ណៈ" គឺធ្វើម៉េចឲ្យវណ្ណៈកម្មករទាំងអស់ទូទាំងប្រទេសកសាងឲ្យទៅវាវណ្ណៈកម្មករកសិករ នេះមួយ។ "បុព្វហេតុវណ្ណៈ" ហ្នឹង គឺឲ្យវណ្ណៈកសិករកាន់កាប់រដ្ឋអំណាចរបស់ខ្លួនឲ្យបានពេញដៃពេញជើង។ តាមរយៈការដំឡើងឋានៈ វណ្ណៈកម្មករ កសិករក្រ កណ្ដាល ថ្នាក់ក្រោមឲ្យកាន់កាប់សហករណ៍ ឲ្យកាន់កាប់ភូមិឃុំ ស្រុក តាមរយៈការបញ្ចូលកម្មករ កសិករឲ្យកាន់កាប់កងទ័ពឲ្យកាន់រដ្ឋអំណាចគ្រប់ផ្នែក។

[១៤:៣៦:២៨]

**ស៖** តើមានមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាណា ដែលប្រាប់លោកអំពីគោលនយោបាយនេះដែរទេ?

**ឆ៖** គោលនយោបាយនេះ វាមិនអីជាលាក់កំបាំងទេ ប៉ុន្តែយើងច្រើនតែមិនយល់។ វាមានសរសេរនៅក្នុងលក្ខន្តិកៈបក្ស វាមានសរសេរនៅក្នុងរដ្ឋធម្មនុញ្ញទៅទៀត។ រដ្ឋធម្មនុញ្ញជាឯកសារមួយចំហ សម្រាប់ផ្សាយទូទាំងប្រទេស ហើយទូទាំងសកលលោក។ លោកមើលចុះក្នុងមាត្រា១ រដ្ឋកម្ពុជាជារដ្ឋរបស់វណ្ណៈកម្មករ កសិករ របស់កម្មករកសិករ និងពលករផ្សេងទៀតទាំងអស់។ កម្មសិទ្ធិ-- មធ្យោបាយផលិតកម្មទាំងអស់ជាៗកម្មសិទ្ធិសមូហភាព។ វាសរសេរច្បាស់អីចឹង ប៉ុន្តែយើងច្រើនមិន

បានគិត។

**ស៖** សូមលោកជួយបញ្ជាក់ឲ្យច្បាស់បន្តិចទៀតទាក់ទងទៅនឹង ថាតើអ្នកណាខ្លះដែលគេឲ្យទៅធ្វើការនៅក្នុងសហករណ៍ហ្នឹង?

**ឆ៖** ក្នុងឋានៈជាពលករ ក្នុងសហករណ៍ជាកងផលិត គឺទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មីទាំងអស់គ្នា។ ហើយបើអ្នកទៅដឹកនាំ គឺបក្ខជន និងយុវកករបស់គេ។ គេអ្នកដឹកនាំ។

[១៤:៣៨:២៥]

**ស៖** ទាក់ទងទៅនឹងព្រៃស ដែលនៅក្នុងសម័យខ្មែរហ្នឹង គឺតើព្រៃសហ្នឹង គេបង្កើតឡើងក្នុងគោលបំណងអ្វីដែរ? លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ?

**ឆ៖** ព្រៃសនេះ វាជាកេរដំណែល ដែល សុន សេន គាត់បង្កើតឡើងសម្រាប់ប្រមូលផ្តុំយុទ្ធជនដែលមានបញ្ហា មិនដាក់បញ្ចូលទៅក្នុងមន្ទីរនគបាលវែស្សរថម្តើយ ហើយកម្ទេចទេ ទុកឲ្យនៅលត់ដំកសាងខ្លួន ដោយពលកម្ម។ ក្រោយមក ប្រហែលជាមានការណែនាំពីបង ប៉ុល ផង។ សុន សេន បានឲ្យមនុស្សខាងកងពល១៧០ នេះ មកព្រៃសមួយរយៈ ដើម្បីឲ្យខំលត់ដំកសាងខ្លួន ហើយគាត់នឹងបានបញ្ជូនខាងរថក្រោះ។ ក៏ប៉ុន្តែដល់ក្រោយមក គាត់ប្រាប់ខ្ញុំថា អ្ហ៎!អស់ហើយ របេះម្តងមួយៗ។ ដូច្នេះព្រៃសនេះ បង្កើតឡើងដើម្បីនឹងអប់រំយុទ្ធជនដែលមានបញ្ហា ដែលគេមិនប៉ានទាន់បញ្ជូនក្នុងមន្ទីរនគបាលឲ្យខំកសាងខ្លួន។ នេះគោលគំនិតដើមរបស់វា។ ហើយសាកល្បងអប់រំនេះ ដើម្បីបញ្ចូលទៅក្នុងកងទ័ព ខ្ញុំឃើញបរាជ័យទៅមិនរួច ខាងលើក៏មិនប៉ានឲ្យមកទៀត។

[១៤:៤០:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំសាក្សីទីកាន់បន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០នាទី ដល់ម៉ោង ១៥:០០នាទី)*

[១៥:០១:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំអ្វើស!

គោរពលោកប្រធាន ខ្ញុំ-- មកណោះមក រហូតដល់ថ្ងៃនេះ សុខភាពខ្ញុំមិនអាចទទួលបានតទៅទៀតទេ ដូច្នោះ ស្នើសុំសម្រាក។ សូមលោកប្រធានៗ អនុញ្ញាត។ ខ្ញុំខំណាស់ដែរ តែទៅមិនរួច។

**ប្រធានអង្គជំនុំ៖**

ទៅសម្រាកនៅឯណា? ចុះទៅសម្រាកនៅឯណា?

**លោក នួន ជា៖**

ឯក្រោមលោកប្រធាន។ ខាងក្រោមនេះ។

[១៥:០២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ ប៉ុន្តែតម្រូវឲ្យមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា និង ឬផ្ដិតស្នាមម្រាមដៃ ជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោតរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលសវនាការចុងបញ្ចប់នេះ។ ហើយបង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទអាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

នាំទៅចុះ!

*(ជនជាប់ចោទចាកចេញពីបន្ទប់សវនាការ)*

[១៥:០៣:៣២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ។ ខ្ញុំបាទម្តងថា ប្រហែលជាមានការយល់ច្រឡំគ្នាខ្លះៗ។ គឺថាកូនក្តីរបស់ខ្ញុំបានជម្រាបតុលាការ ថាគាត់មិនអាចចូលរួមដោយមានប្រសិទ្ធភាពនៅក្នុងដំណើរការនីតិវិធីនេះ។ ទោះបីថាគាត់សម្រេចថា ទៅជាន់ក្រោមដើម្បីថាឈប់សម្រាកក៏ដោយ ក៏វា-- ក៏ទាក់ទងទៅនឹងសាក្សីសំខាន់មួយនេះ គាត់នឹងមិនបោះចោលបង់នូវសិទ្ធិក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនីតិវិធីនេះឡើយ។ បានន័យថា ទោះបីនៅក្នុងអង្គតុលាការក៏ដោយ ទោះបីនៅខាងក្រោមក៏ដោយ។ ដូច្នេះ ខ្ញុំស្នើថា លោកប្រធានមេត្តាសម្រេចពន្យារសវនាការនេះ ទៅស្អែកព្រឹកវិញ ដើម្បីឲ្យកូនក្តីរបស់ខ្ញុំអាចចូលរួមដោយមានប្រសិទ្ធភាពនៅក្នុងដំណើរការនីតិវិធីនេះ។ សូមអរគុណ។

[១៥:០៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៧:៣៩]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានសម្រេចរួចហើយ។ បន្ទាប់មកគឺ សំណើសុំបន្ថែមទៀតរបស់មេធាវីការពារក្តីរបស់ នួន ជា លោកមេធាវីអន្តរជាតិឃើញថាសំណើនេះមិនស្របគ្នាទេ រវាងសំណើផ្ទាល់របស់ជនជាប់ចោទ នួន ជា ហើយនិងសំណើរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា។ មួយគឺស្នើសុំទៅខាងក្រោម បានន័យថា ទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយតាមប្រព័ន្ធសោតទស្សន៍ដែលបានរៀបចំទុករួចហើយ។ ចំណែកឯមេធាវីការពារក្តី គឺសូមឲ្យផ្អាកកិច្ចដំណើរការសវនាការសម្រាប់ម៉ោងចុងក្រោយនេះ។

[១៥:០៨:៣៤]

ដើម្បីឲ្យបញ្ហានេះច្បាស់លាស់ អង្គជំនុំជម្រះបង្គាប់ឲ្យលោកគ្រូពេទ្យប្រចាំការនៅទីនេះ ទៅពិនិត្យបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា ភ្លាមៗឥឡូវនេះ ហើយរាយការណ៍មកអង្គជំនុំជម្រះជាបន្ទាន់ ដើម្បីឲ្យអង្គជំនុំជម្រះពិចារណាសម្រេចអំពីបញ្ហានេះ ថាតើត្រូវបន្ត ឬក៏ត្រូវផ្អាកសវនាការនៅបន្តិចទៀតនេះ។

*(មេធាវីការពារក្តី, លោក ម៉ៃខល ផេសមិន, ចាកចេញពីបន្ទប់សវនាការ)*

[១៥:០៩:៤៧]

**ប្រធានអង្គជំនុំ៖**

លោក ដាវ អានសាន តាមមើលត្រួតពិនិត្យមើលព័ត៌មានមើល មេធាវីចេញអំមិញ ទៅណា? បើគាត់ទៅ អត់អនុញ្ញាតឲ្យគាត់ចូលទៅពិនិត្យ ទៅច្រិមច្រុមជាមួយនឹងខាងវេជ្ជបណ្ឌិតទេ ឲ្យវេជ្ជបណ្ឌិតគេពិនិត្យឯករាជ្យរបស់គេនៅក្នុងការបំពេញបេសកកម្មវិជ្ជាជីវៈរបស់គេ។

រាយការណ៍មកឲ្យយើងភ្លាមណ៎ា!

*(ក្រឡាបញ្ជីចាកចេញពីបន្ទប់សវនាការ)*

[១៥:១២:២២]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ផេសមិន ប្រសិនបើលោកទៅពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការនៃការបំពេញភារកិច្ចរបស់វេជ្ជបណ្ឌិតក្នុងការពិនិត្យបញ្ហាសុខភាពរបស់ជនជាប់ចោទដោយឯករាជ្យ។ ប្រសិនបើមានព័ត៌មាន មានបញ្ហាអី ដែលជ្រៀតជ្រែកក្នុងការកិច្ចការបំពេញវិជ្ជាជីវៈនោះ គឺលោកនឹងមានបញ្ហា។

*(ក្រឡាបញ្ជីចូលមកកាន់បន្ទប់សវនាការវិញ និងរាយការណ៍ជូនប្រធានអង្គជំនុំ)*

[១៥:១២:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៧:៥៩]

*(មេធាវីការពារក្តី, លោក ម៉ៃខល ផេសមិន, ចូលក្នុងបន្ទប់សវនាការវិញ)*

[១៥:១៨:១០]

**ប្រធានអង្គជំនុំ៖**

ដោយអង្គជំនុំជម្រះកក់សម្គាល់ឃើញថា លោកមេធាវីអន្តរជាតិ ផេសមិន ការពារក្តីឲ្យលោក នួន ជា គាត់បានធ្វើដំណើរចាកចេញពីអង្គ-- បន្ទប់សវនាការទៅដល់បន្ទប់ដែលគ្រូពេទ្យទទួលខុសត្រូវលើបញ្ហាពិនិត្យសុខភាពរបស់ជនជាប់ចោទដោយផ្ទាល់ ដែលជាសកម្មភាពជ្រៀតជ្រែកដល់វិជ្ជាជីវៈរបស់គ្រូពេទ្យ។ ដូច្នេះ លទ្ធផលថ្ងៃនេះចាត់ទុកថាមិនអាចមានតម្លៃនៅក្នុងការប្រើប្រាស់ដើម្បីជាមូលដ្ឋានឲ្យអង្គជំនុំជម្រះពិចារណាសម្រេចបានទេ។ ហើយម្យ៉ាងទៀតលោក ផេសមិន គឺគាត់បានចាកចេញពី

បន្ទប់នេះទៅកាន់កន្លែងពិនិត្យ គ្រូពេទ្យពិនិត្យសុខភាពជនជាប់ចោទ ដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ។

ដូច្នេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសម្រេចផ្អាកសវនាការត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគី និងសាធារណជនផងដែរថា កិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច នឹងបន្តធ្វើនៅថ្ងៃស្អែក ទី២១ ខែមីនា ឆ្នាំ២០១២។ ដោយឡែក ថ្ងៃព្រហស្បតិ៍ ទី២២ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ ដោយមូលហេតុកិច្ចការជាច្រើនដែលអង្គជំនុំជម្រះត្រូវពិភាក្សាសម្រេច។

[១៥:២០:១៧]

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅកាន់មន្ទីរឃុំឃាំង ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយ-- ប្រសិនបើមករហ័សគឺសូមផ្អាក សម្រាកនៅក្នុងបន្ទប់រង់ចាំសម្រាប់សាក្សីសិន ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះឲ្យបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:២១ នាទី)*